ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គបុរេជំនុំជម្រះ**
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 15-Dec-2017, 12:14
CMS/CFO: Sann Rada

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**
**<u>ជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ</u>**

លេខ: ០០៤/១/០៧-០៩-២០០៩/អវតក/កសចស(អបជ៥០)

**<u>អសាធារណៈ</u>**

**ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧**

**ម៉ោង ០៩: ៥៧នាទី**

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន (ប្រធានអង្គបុរេ)
ចៅក្រម អូលីវីយេ បូវ៉ាល្លេត៍
*(Judge Olivier BEAUVALLET)*
ចៅក្រម ន័យ ថុល
ចៅក្រម កាំង ជីន បាក់
*(Judge Kang Jin BAIK)*
ចៅក្រម ហួត វុទ្ធី

**ក្រឡាបញ្ជី៖**

លោកស្រី រស់ បូផាណា
លោកស្រី អែលសា ឡេវ៉ាវ៉ាស័រ
*(Mr. Elsa LEVAVASSEUR)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicholas KOUMJIAN)*
លោក សេង ប៊ុនឃាង
លោក កូមេន ខេននី *(Mr. Coman KENNY)*

**ជនត្រូវចោទ៖**

លោកស្រី អ៊ឹម ចែម

**មេធាវីការពារជនត្រូវចោទ៖**

លោក ប៊ិត ស៊ាងលឹម
លោក វ៉ាន ហ្សកដាហ្ស *(Mr.Wayne JORDASH)*
កញ្ញា ហ្ស៊ូល្យាន រ៉ូមី *(Ms. Julianne ROMY)*
កញ្ញា អាស្ត្រីដ ប៉ុងស៊ូលេ
*(Ms. Astrid PONSOLLE)*
លោក លៀម ម៉ាក អានឌ្រូ
*(Mr. Liam MacAndrews)*
លោកស្រី វី ណូយែល

សាធារណៈ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក សំ សុគង់

លោកស្រី លីម៉ា ង្វៀន *(Lyma NGUYEN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី សួ សុទ្ធាវី

អត្ថាធិប្បាយៈ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ប្រាក់ គឹមសាន (ប្រធានអង្គបុរេ) | ខ្មែរ |
| លោក សំ សុគង់ | ខ្មែរ |
| លោកស្រី លីម៉ា ង្វៀន | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក កូមេន ខេននី | អង់គ្លេស |

អាណាព្យាបាល (watermark)

# កិច្ចដំណើរការនីតិវិធី

[០៩:៥៧:០៦]

**ប្រធានអង្គបុរេ៖**

ប្រកាសបើកសវនាការជាអសាធារណៈ!

ជាកិច្ចចាប់ផ្ដើមសូមអញ្ជើញលោកមេធាវី ឬលោកស្រីមេធាវីដើមបណ្ដឹងឡើងថ្លែងសេចក្ដីសន្និដ្ឋានរបស់ខ្លួន។

*(សម្រាករយៈពេលខ្លី)*

បាទៗ! សូមអញ្ជើញលោកមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីឡើងធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួន។

សូមអញ្ជើញ!

**លោក សំ សុគង់៖**

អង្គបុរេជំនុំជម្រះជាទីគោរព! ខ្ញុំឈ្មោះ សំ សុគង់ ខ្ញុំបង្ហាញខ្លួនក្នុងនាមដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤ ផ្នែកទី១ ខ្ញុំសូមអរគុណអង្គបុរេជំនុំជម្រះដែលបានអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលរងផលប៉ះពាល់ក្នុងសំណុំរឿងនេះ មានឱកាសធ្វើសេចក្ដីសន្និដ្ឋានស្ដីពីតួនាទីរបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា។ សេចក្ដីសន្និដ្ឋានរបស់យើងខ្ញុំនៅក្នុងថ្ងៃនេះផ្ដោតត្រឹមសំណួរថាតើសហចៅក្រមស៊ើបអង្កេតនៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួនដែលថា អ៊ឹម ចែម ពុំស្ថិតក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក នោះសម្រេចដោយមានកំហុស និងមិនសម មិនមានហេតុផលអំពីតួនាទីរបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដែរ ឬយ៉ាងណា ដែលវាហួសពីដែនអំណាចតុលាការនេះ។ ការបកស្រាយនៅក្នុងដីកាដំណោះស្រាយអំពីច្បាប់ អ.វ.ត.ក ដោយដកចេញអំណាចតុលាការកម្ពុជានៅក្នុងការបើកសវនាការលើរឿងក្ដីប្រឆាំងទៅនឹងពលរដ្ឋខ្លួនឯងចំពោះព្រឹត្តិការណ៍ណាមួយដែលបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ គឺផ្ទុយនឹងគោលការណ៍អធិបតេយ្យភាពកម្ពុជាហើយ។ ក្នុងនាមជារដ្ឋអធិបតេយ្យមួយ ព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិកំណត់បទប្បញ្ញត្តិច្បាប់ និងសកម្មភាពរបស់ប្រជាពលរដ្ឋខ្លួន។ ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតលើឯក-សារបង្កើត អ.វ.ត.ក គឺផ្ទុយទៅនឹងកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងការផ្ដល់សំណងជូនជនរងគ្រោះនៃឧក្រិដ្ឋកម្មឃោរឃៅនៅក្រោមច្បាប់របស់ផងខ្លួនផងដែរ។ ដីកាដំណោះស្រាយមិនតម្រូវឲ្យធ្វើការវាយតម្លៃអំពីតួនាទីរបស់តុលាការក្នុងស្រុកក្នុងការកំណត់យុត្តាធិការបុគ្គលនៃ អ.វ.ត.ក លើករណី អ៊ឹម

ថែម ក្នុងនោះទេ។ ទោះបីជាយ៉ាងនេះក្តី ដោយសារបញ្ហាចោទនេះត្រូវបានលើកឡើងនាពេលនេះ ដូច្នេះ វាមានសារៈសំខាន់ចំពោះកូនក្តីរបស់យើងខ្ញុំ ដែលជាអ្នកដាក់ពាក្យប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយវាក៏ជាបញ្ហាដែលប៉ះពាល់ដល់កេរដំណែលរបស់តុលាការនេះផងដែរ។ ដូច្នេះយើងខ្ញុំសូមគោរពស្នើសុំលោកប្រធាន ក៏ដូចជាចៅក្រមប្រឹក្សាជាតិ និងអន្តរជាតិ សម្រេចលើកំហុសនៃសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើបញ្ហានេះក្នុងដីកាដំណោះស្រាយដែលត្រូវប្តឹងឧទ្ធរណ៍មកនេះ។ ខ្ញុំនឹងធ្វើសេចក្តីសន្និដ្ឋានជូនលោកប្រធាន ក៏ដូចជាចៅក្រមជាតិ និងអន្តរជាតិ អំពីបញ្ហាអធិបតេយ្យភាពកម្ពុជានាពេលបន្តិចទៀតនេះ ហើយសហភាតារបស់ខ្ញុំលោកស្រី លីម៉ា ង្វៀន នឹងលើកឡើងនូវទឡ្ហីករណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីការបកស្រាយសន្ធិសញ្ញា និងប្រវត្តិនៃការចរចាកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ផងដែរ។

ការវិភាគនៅក្នុងដីកាដំណោះស្រាយ លើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ក្នុងផ្នែកទី១ (សូមទោស) ក្នុងផ្នែកទី២.១ ធ្វើឡើងក្នុងគោលបំណងរារាំងដាច់ខាតមិនឲ្យតុលាការកម្ពុជាអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មណាមួយ ឬឧក្រិដ្ឋកម្មទាំងអស់ដែលបានប្រព្រឹត្តនៅក្នុងចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ទោះបីជារឿងក្តីនោះស្ថិតនៅក្នុងដែនសមត្ថកិច្ចមានកំណត់នៃ អ.វ.ត.ក ក៏ដោយ។ អំណាចតុលាការកម្ពុជាក្នុងការបើកសវនាការលើរឿងក្តីប្រឆាំងនឹងបុគ្គលដែលមិនស្ថិតនៅក្រោមវិសាលភាពនៃយុត្តាធិការមានកំណត់នៃ អ.វ.ត.ក គឺជាបញ្ហាដែលត្រូវសម្រេចដោយតុលាការកម្ពុជាខ្លួនឯង មិនមែនដោយ អ.វ.ត.ក ជាអ្នកសម្រេចនោះទេ។

ការបកស្រាយយុត្តាធិការនៃអ.វ.ត.ក ក្នុងលក្ខណៈមួយដែលដកហូតតុលាការកម្ពុជានូវអំណាចរបស់ខ្លួនក្នុងការចោទប្រកាន់ជនណាម្នាក់ពីសម័យខ្មែរក្រហម និងជាការជ្រៀតជ្រែកសិទ្ធិអធិបតេយ្យរបស់ប្រទេសកម្ពុជាក្នុងការចោទប្រកាន់ពលរដ្ឋរបស់ខ្លួន ចំពោះអំពើដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងទឹកដីរបស់ខ្លួន នៅពេលការជ្រៀតជ្រែកបែបនេះមិនមានចេតនាធ្វើឡើងនៅក្រៅវិសាលភាពនៃការប្រគល់ភារកិច្ចមានកំណត់ជូន អ.វ.ត.ក។ ច្បាប់និងកិច្ចព្រមព្រៀង អ.វ.ត.ក គឺជាលទ្ធផលនៃការពិភាក្សារយៈពេលជាច្រើនឆ្នាំ ហើយដែលក្នុងភាសាច្បាស់លាស់អំពីដែនកំណត់នៃយុត្តាធិការ អ.វ.ត.ក សេចក្តីសម្រេចណាមួយដែលកម្រិតអំណាចតុលាការកម្ពុជា មិនគួរបកស្រាយបានឡើយ ប្រសិនបើគ្មានបទប្បញ្ញត្តិណាមួយដែលច្បាស់លាស់ ផ្ទុយពីនេះទេ។

នៅក្នុងនោះដែរ យើងមានឯកអគ្គរាជរដ្ឋ ដេវីដ សេហ្វ័រ ដែលជាភាគីចរចាបង្កើត អ.វ.ត.ក

បានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃអធិបតេយ្យភាពកម្ពុជាចំពោះរាជរដ្ឋាភិបាលកម្ពុជាក្នុងអំឡុងពេលកិច្ចពិភាក្សា។ ក្នុងអំឡុងពេលចរចា ឯកអគ្គរាជរដ្ឋ សេហ្វ័រ បានសង្កត់ធ្ងន់ថា ការចោទប្រកាន់ចារីខ្មែរក្រហមថ្នាក់ក្រោមគឺជាបញ្ហាសម្រាប់រដ្ឋាភិបាលកម្ពុជាជាអ្នកសម្រេចនៅក្រោយការបង្កើត អ.វ.ត.ក។ ឯកអគ្គរាជទូតពុំប្រឈមនឹងគំនិតខ្វែងយោបល់គ្នាលើចំណុចនេះទេ អាស្រ័យហេតុនេះ វាមិនមានហេតុផលទេដែលអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាមានចេតនាឲ្យ អ.វ.ត.ក ដកយុត្តាធិការទាំងអស់ចេញពីតុលាការកម្ពុជាលើរយៈកាលនៃសកម្មភាពព្រហ្មទណ្ឌ ពីព្រោះអំណាចនេះតែងតែទុកជូនរដ្ឋាភិបាលកម្ពុជា និងតុលាការកម្ពុជាជាអ្នកសម្រេច។

ដូច្នេះការបកស្រាយនៅក្នុងដីកាដំណោះស្រាយ អំពីច្បាប់ និងកិច្ចព្រមព្រៀង អ.វ.ត.ក វានាំឲ្យមានលទ្ធផលមិនសមហេតុផល ធ្វើឲ្យបាត់បង់អធិបតេយ្យភាពកម្ពុជា ដោយសារវាជាការដកហូតសិទ្ធិស្នូលរបស់កម្ពុជាក្នុងការចាត់ចែងសកម្មភាពនៅលើទឹកដីរបស់ខ្លួន និងអំពើដែលត្រូវប្រព្រឹត្តដោយពលរដ្ឋរបស់ខ្លួន ដោយគ្មានការយល់ព្រមជាក់លាក់ពីកម្ពុជាលើករណីនេះឡើយ។ យើងកត់សម្គាល់ថាមេធាវីការពារក្តីបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួនថាមេធាវីការពារក្តីព្រមទទួលយក និងឯកភាពជារួមជាមួយនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា មានតែតុលាការក្នុងស្រុកប៉ុណ្ណោះដែលអាចកំណត់ជាស្ថាពរលើវិសាលភាពនៃយុត្តាធិការរបស់ខ្លួន ចំពោះឧក្រិដ្ឋកម្មនៃយុគសម័យខ្មែរក្រហម (សេចក្តីសម្រេចរបស់មេធាវីការពារត្រង់កថាខណ្ឌទី៦)។ ដីកាដំណោះស្រាយទទួលស្គាល់ថា ការបកស្រាយទៅយុត្តាធិការរបស់ អ.វ.ត.ក ក្នុងលក្ខខណ្ឌបែបនេះ គឺស្មើនឹងការផ្តល់និទណ្ឌភាពចំពោះអតីតខ្មែរក្រហមទាំងមូល។ ការបកស្រាយដែលបានផ្តល់និទណ្ឌភាពចំពោះចារីជាខ្មែរក្រហមទាំងអស់បែបនេះ គឺផ្ទុយនឹងកាតព្វកិច្ចសន្ធិសញ្ញារបស់កម្ពុជា និងរំលោភសិទ្ធិរបស់ជនរងគ្រោះនៅក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ កម្ពុជាមានកាតព្វកិច្ចផ្តន្ទាទោស និងបញ្ជូនជនណាម្នាក់ដែលប្រព្រឹត្តការរំលោភធ្ងន់ធ្ងរនៅក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ អនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាប្រឆាំងនឹងទារុណកម្មដែលកាតព្វកិច្ចនេះ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់នៅក្នុងសំណុំរឿង០០២ ផងដែរ។ ការព្រមព្រៀងណាមួយដែលអាចហាមឃាត់ចំពោះការផ្តន្ទាទោសបុគ្គលទាំងឡាយណាដែលបានរកឃើញនៅក្នុងទឹកដីកម្ពុជា ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៃការធ្វើទារុណកម្ម អំពើប្រល័យពូជសាសន៍ ឬការរំលោភធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺរំលោភលើលក្ខខណ្ឌនានានៅក្នុងសន្ធិសញ្ញានេះ ដើម្បីផ្តន្ទាទោស ឬបញ្ជូនខ្លួនជនទាំង

នោះចំពោះការប្រព្រឹត្តបទល្មើសទាំងនោះហើយ។

ការលើកលែងទោសដល់ចារីទាំងអស់ ក៏រំលោភសិទ្ធិរបស់ជនរងគ្រោះ នៅក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ធានាចំពោះការ -- ចំពោះប្រជាពលរដ្ឋរបស់ខ្លួននូវសិទ្ធិក្នុងការប្ដឹងបរិហារ ប្ដឹងតវ៉ា និងប្ដឹងទាមទារសំណងជួសជុលការខូចខាតដែលបណ្ដាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ និងទទួលស្គាល់អំណាចស្នូលរបស់តុលាការដើម្បីការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋផងដែរ។ ការសម្រេចនៅក្នុងដីកាដំណោះស្រាយលើយុត្តាធិការផ្ដាច់មុខរបស់ អ.វ.ត.ក គឺជាការដកហូតពីតុលាការកម្ពុជានៅមុខងារស្នូលទាំងអស់នេះ។

រដ្ឋធម្មនុញ្ញកម្ពុជា ក៏បានដាក់បញ្ចូលយ៉ាងច្បាស់លាស់នូវកាតព្វកិច្ចស្ដីពីសិទ្ធិមនុស្ស រួមទាំងកាតព្វកិច្ចនានារបស់ខ្លួននៅក្រោមកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ អនុសញ្ញាស្ដីពីការការពារបុគ្គលគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ផងដែរ។ ទោះបីជាសហចៅក្រមស៊ើបអង្កេតបានពន្យល់ថា ការរំលោភលើបទដ្ឋានសិទ្ធិមនុស្សមិនអាចតម្រូវឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក៏ដោយ ក៏បទដ្ឋានសិទ្ធិមនុស្សទាំងនេះ តម្រូវឲ្យមានយុត្តិធម៌ដល់ជនរងគ្រោះ និងសិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពផងដែរ។ នៅពេលដែលសិទ្ធិរបស់ពួកគេត្រូវ -- ដូចជា សិទ្ធិរស់រានមានជីវិត សិទ្ធិសេរីភាព និងសិទ្ធិសេរីភាពរួចផុតពីការធ្វើទារុណកម្ម ព្រមទាំងការប្រព្រឹត្តឃោរឃៅ ត្រូវបានរំលោភដោយជាក់លាក់។

ក្នុងករណីដែលកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក ត្រូវបានបកស្រាយតាមមធ្យោបាយមួយដើម្បីហាមឃាត់ការប្ដឹងតវ៉ាណាមួយនៅក្នុងតុលាការជាតិ ការបកស្រាយនេះ គឺជាការរំលោភលើកាតព្វកិច្ច និងសិទ្ធិរបស់ជនរងគ្រោះក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា និងសន្ធិសញ្ញាដើម្បីស្វែងរកឧបាស្រ័យ និងដំណោះស្រាយក្នុងតុលាការជាតិផងដែរ។ លើសពីនេះទៅទៀត ការបង្កើតយុទ្ធសាស្ត្រសម្រាប់និទណ្ឌភាពទូលំទូលាយចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរតាមរបៀបដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយនឹងធ្វើឲ្យអាប់អួរដល់កេរដំណែលរបស់តុលាការនេះ ព្រមទាំងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ជនរងគ្រោះដែលកំពុងតែស្វែងរកយុត្តិធម៌ និងសំណងសម្រាប់ឧក្រិដ្ឋកម្មទាំងអស់នេះ។

ចំពោះបញ្ហាជាបឋម អ.វ.ត.ក អាចនិយាយតែចំពោះយុត្តាធិការរបស់ អ.វ.ត.ក គឺមិនមែន

តុលាការជាតិនោះទេ។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា មិនមានយុត្តាធិការវិនិច្ឆ័យទៅលើសកម្មភាពស្ថាប័នដទៃទេ។ មានន័យថាមិនមានខ្សែរយៈនៃអំណាចរវាង អ.វ.ត.ក និងតុលាការជាតិទេ ប៉ុន្តែការបកស្រាយនៅក្នុងដីកាដំណោះស្រាយទៅលើយុត្តាធិការរបស់ អ.វ.ត.ក បានជំរុញដល់កម្រិតព្រំដែនរវាង អ.វ.ត.ក និង តុលាការជាតិ។ ទោះបីជាកំហុសឆ្គងនេះ គ្មានផលប៉ះពាល់ផ្ទាល់លើតុលាការកម្ពុជាក៏ដោយ ក៏ត្រូវតែមានការកែតម្រូវដែរ ដោយសារកំហុសឆ្គងនេះមានការពាក់ព័ន្ធទៅនឹងការបកស្រាយអំពីយុត្តាធិការបុគ្គលនៃតុលាការនេះ ហើយកំហុសឆ្គងនេះរាប់បញ្ចូលផង ការបកស្រាយខុសអំពីច្បាប់ដែលគ្រប់គ្រងតុលាការនេះផងដែរ។ ប្រសិនបើយើងទុកឲ្យមានកំហុសឆ្គងនេះ នោះគេអាចយកវាទៅប្រើប្រាស់ជាប្រភពច្បាប់គួរឲ្យជឿជាក់បាននៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលអនាគត ដែលអាចប៉ះពាល់ដល់ការទាមទាររបស់ជនរងគ្រោះទាំងឡាយដែលមិនអាចស្វែងរកយុត្តិធម៌ និងដំណោះស្រាយនៅចំពោះមុខ អ.វ.ត.ក បាន។ បញ្ហាថាតើតុលាការកម្ពុជាមាន ឬក៏មិនមានសមត្ថភាពខាងស្ថាប័ន និងសមត្ថភាពខាងផ្លូវច្បាប់ដើម្បីជំនុំជម្រះករណីទាំងនេះដែរឬអត់នោះ គប្បីជាបញ្ហាដែលត្រូវទុកឲ្យរាជរដ្ឋាភិបាលកម្ពុជា និងប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជាមួយនេះ ជាអ្នកសម្រេច។ សហចៅក្រមស៊ើបអង្កេតមិនគប្បីសម្រេចបញ្ហានេះជំនួសពួកគេទេ ជាពិសេសដោយសារមានកំហុសឆ្គងនៅក្នុងការសំអាងហេតុនៅក្នុងសេចក្តីសម្រេច។ លើសពីនេះទៅទៀត ប្រសិនបើសេចក្តីសម្រេចនេះ ត្រូវទុកចោលដោយមិនមាន ការកែតម្រូវនោះទេ វានឹងធ្វើឲ្យអាប់អួរដល់កេរដំណែលរបស់ អ.វ.ត.ក ដោយការបង្ហាញឲ្យឃើញថាមានការគាំទ្រពីតុលាការនេះចំពោះនិទណ្ឌភាពយ៉ាងទូលំទូលាយសម្រាប់ឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត គឺនិទណ្ឌភាពដែលភាគីនានាដែលបានចូលរួមបង្កើត អ.វ.ត.ក នេះមិនមានបំណងធ្វើដូច្នេះឡើយ។ អាស្រ័យហេតុនេះកំហុសអង្គហេតុ និងអង្គច្បាប់ចំពោះការបកស្រាយទៅលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ត្រូវតែយកមកដោះស្រាយនៅក្នុងសារណារបស់យើងខ្ញុំ អ.ប.ជ គឺជាវេទិការដ៏សមស្របតែមួយគត់ សម្រាប់ដោះស្រាយកំហុសនេះ។

បាទ អ៊ីចឹងខ្ញុំបាទសុំឲ្យ -- សុំការអនុញ្ញាតពីលោកប្រធានដើម្បីឲ្យសហភាតាខ្ញុំលោកស្រី លីម៉ា ង្វៀន ដើម្បីធ្វើការ ធ្វើបទបង្ហាញបន្ត។ បាទ សូមអរគុណ។

[១០:១៦:៣៥]

**ប្រធានអង្គបុរេ៖**

បាទ សូមអញ្ជើញលោកស្រី លីម៉ា ង្វៀន ឡើងធ្វើសេចក្តីសន្និដ្ឋានបន្ត។

**លោកស្រី លីម៉ា ង្វៀន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំឈ្មោះថា ង្វៀន ជាសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតទៅលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែលដកចេញនូវយុត្តាធិការតុលាការជាតិនេះ គឺវាប្រឆាំងនឹងអធិបតេយ្យភាពកម្ពុជា និងច្បាប់កម្ពុជា។ គឺថាវាមិនមែនត្រឹមតែប្រឆាំងនឹងអធិបតេយ្យភាពកម្ពុជា និងច្បាប់កម្ពុជានោះទេ វាក៏ផ្ទុយទៅនឹងការបកស្រាយប្រកបទៅដោយហេតុផលនៃច្បាប់បង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងផងដែរ។ ការសម្រេចចិត្តរបស់ -- ការពិចារណាដែលថាច្បាប់ អ.វ.ត.ក ហ្នឹង គឺមិនរាប់បញ្ចូលនូវយុត្តាធិការបុគ្គល ឬក៏យុត្តាធិ-ការបទល្មើសពាក់ព័ន្ធទៅនឹងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក នោះទេ។ ដូចដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើងហើយពាក់ព័ន្ធទៅនឹងការលើកលែងទោស និងការអនុគ្រោះទោស ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហម។ សេចក្តីសន្និដ្ឋានទាំងអស់នេះ គឺពាក់ព័ន្ធទៅនឹងការសម្រេចថាតើ អ៊ឹម ចែម ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬក៏យ៉ាងណា? គឺលើកឡើងថាច្បាប់ទាំងអស់នេះ គឺថាមិនចាំបាច់ ហើយវាខុសទៅនឹងច្បាប់ដោយមូលហេតុដូចខាងក្រោមនេះ។ ទី១ ការបកស្រាយច្បាប់ អ.វ.ត.ក ផ្តាច់មុខដោយសហចៅក្រមស៊ើបអង្កេត គឺមិនមានការគាំទ្រណាមួយនៅក្នុងច្បាប់បង្កើត អ.វ.ត.ក ឬកិច្ចព្រមព្រៀងនោះទេ។ ទី២ ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេត គឺវាផ្ទុយគ្នាទៅនឹងកម្មវត្ថុ និងគោលបំណងនៃឯកសារគ្រឹះទាំងអស់នេះ។ ទី៣ សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតទៅលើច្បាប់នេះ គឺថាវាមានចេតនាច្បាស់ណាស់ពាក់-ព័ន្ធទៅនឹងការចរចាទៅលើប្រវត្តិសាស្ត្ររបស់ អ.វ.ត.ក ជាពិសេសការបង្កើតឲ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ មិនមែនការបង្កើតឲ្យមាននិទណ្ឌភាពដ៏ទូលំទូលាយនោះទេ។ ហើយចុងក្រោយលទ្ធផលនៃការបកស្រាយនេះ វានាំឲ្យមានសញ្ញាណថា អង្គការសហប្រជាជាតិ គឺគេមានការយល់ស្របក្នុងការបង្កើត អ.វ.ត.ក គាំទ្រឲ្យមានការគ្របដណ្តប់ទាំងទៅលើនិទណ្ឌភាពសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ រួមទាំងការរំលោភពីសំណាក់រដ្ឋនោះផងដែរ។ មេធាវីការពារក្តីនៅក្នុងសារណាជាលាយលក្ខណ៍អក្សរខ្លួន សុំឲ្យអង្គជំនុំជម្រះបកស្រាយទៅលើយុត្តាធិការរបស់តុលាការកម្ពុជា ទៅលើឧក្រិដ្ឋកម្មនាសម័យខ្មែរក្រហម។ ដោយសារតែកំហុសអង្គច្បាប់ និងអង្គហេតុយ៉ាងជាក់ស្តែង ដែលប្រព្រឹត្តឡើងសហចៅក្រមស៊ើបអង្កេត នេះគឺជាបញ្ហាស្មុគស្មាញណាស់ ហើយនេះគឺជាសិទ្ធិរបស់អង្គបុរេជំនុំជម្រះក្នុងការអនុវត្តនូវសិទ្ធិអំណាចតាមផ្លូវតុលាការដើម្បីពិនិត្យមើលឡើងវិញទៅលើកំហុសទាំងអស់

នេះ។

ក្នុងនាមឲ្យជនរងគ្រោះ ក៏ដូចដើមបណ្ដឹងរដ្ឋប្បវេណី យើងស្នើសុំឲ្យអង្គជំនុំជម្រះដោះស្រាយនូវអ្វីដែលយើងបានលើកឡើង។ ជាគោលការណ៍ ថានេះជាការជ្រៀតជ្រែកដ៏ធ្ងន់ទៅលើសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការនេះ ក៏ដូចតុលាការដទៃទៀត។ ហេតុដូច្នេះហើយ ថា អ.វ.ត.ក មិនត្រូវដើរតួជំនួសឲ្យតុលាការកម្ពុជាក្នុងការអនុវត្តយុត្តាធិការទៅលើបុគ្គលទាំងឡាយណាដែលមិនស្ថិតនៅក្នុងវិសាលភាពរបស់ អ.វ.ត.ក នោះទេ។

ខ្ញុំនឹងសូមឡើងទៅនិយាយរឿងដ៏ស្មុគស្មាញពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ អ.ប.ជ។ មេធាវីការពារក្ដីបានជំទាស់តវ៉ាថា អង្គបុរេជំនុំជម្រះ គឺជាវេទិកាដ៏សមស្របមួយ។ យើងបាននិយាយថា អង្គបុរេជំនុំជម្រះ គឺជាវេទិកាសមស្របដើម្បីដោះស្រាយទៅលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។ មូលហេតុចម្បង នេះគឺថានេះគឺជាបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងកំហុសផ្លូវច្បាប់ប្រព្រឹត្តឡើងដោយសហចៅក្រមស៊ើបអង្កេត ក្នុងការបកស្រាយទៅលើច្បាប់របស់ អ.វ.ត.ក ស្ដីអំពីយុត្តាធិការផ្នែកបុគ្គល។ អង្គបុរេជំនុំជម្រះ គឺថាត្រូវបានចាត់តាំងដោយច្បាប់ស្ដីអំពីការបង្កើត អ.វ.ត.ក ថាជាតុលាការជាន់ខ្ពស់ដើម្បីសម្រេចទៅលើកំហុសអង្គច្បាប់ ឬអង្គហេតុដោយសារតែការអនុវត្តនូវមុខងារតុលាការរបស់សហចៅក្រមស៊ើបអង្កេត។ សារៈសំខាន់នៃសេចក្ដីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត មិនត្រូវបំផ្លើសនោះទេ ការយល់ឃើញនេះ គឺថា នៅក្នុង*ហ្វូតណូត* គឺផ្នែកទាំងស្រុងនៃដីកាដំណោះស្រាយដែលអាចយកមកអនុវត្តបាន នៅក្នុងកថាខណ្ឌ២៦ ហើយដែលសហចៅក្រមស៊ើបអង្កេតបានរកឃើញអំពីយុត្តាធិការរបស់តុលាការជាតិ ក្នុងការសម្រេចភ្លាមៗពាក់ព័ន្ធទៅលើយុត្តាធិការបុគ្គល ទៅលើ អ៊ឹម ចែម ដែលសេចក្ដីសម្រេចនេះ គឺថាត្រូវបានប្ដឹងឧទ្ធរណ៍។ ហើយការយល់ឃើញទាំងអស់នេះ រដ្ឋកម្ពុជា ក៏ដូចសាធារណជនកម្ពុជា ក៏ដូចជាជនកម្ពុជាដែលជាជនរងគ្រោះ គឺថាមិនត្រូវបានទុកចោលដោយសារតែ អ.វ.ត.ក មានជំហរប្រកាសថា តុលាការជាតិនេះត្រូវបានដកហូតនូវយុត្តាធិការដើម្បីសម្រេចទៅលើឧក្រិដ្ឋកម្មណាមួយ។ អ៊ីចឹងដីកាដំណោះស្រាយនេះគឺថា ត្រូវយកមកដោះស្រាយឲ្យមានហ្មត់ចត់។

មូលហេតុចម្បងមួយនៃសារណារបស់យើងខ្ញុំ គឺថាសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត គឺពាក់ព័ន្ធទៅនឹងការបកស្រាយនេះ។ ខ្ញុំសូមចូលទៅដល់សំអាងហេតុនេះតែម្ដង។ កិច្ចព្រមព្រៀងទីក្រុងវីយែន គឺមានចែងនៅក្នុងមាត្រា១ នៃអនុសញ្ញានេះ ហើយអនុសញ្ញានេះក៏ត្រូវតែបកស្រាយ

ទៅតាមន័យចំៗរបស់វាស្តីអំពីកម្មវត្ថុ និងគោលបំណងតែម្តង ដែលមានយកមកចែងនៅក្នុងកិច្ចព្រមព្រៀងរបស់ អ.វ. -- រវាង អ.វ.ត.ក ហើយវាមិនគ្របដណ្តប់ទៅលើយុត្តាធិការបុគ្គលដែលស្ថិតនៅក្រៅយុត្តាធិការរបស់តុលាការនេះទេ។ ច្បាប់ស្តីអំពីការបង្កើត អ.វ.ត.ក ក៏ដូចជាកិច្ចព្រមព្រៀងនិយាយអំពីការប្រព្រឹត្តទៅលើបុគ្គល ឬឧក្រិដ្ឋកម្មដែលស្ថិតនៅខាងក្រៅយុត្តាធិការរបស់សាលាក្តីនេះ។ ទី២ មិនមានបទប្បញ្ញត្តិណាមួយដែលស្មើនឹងការលើកលែងចោលនូវសិទ្ធិស្របទៅតាមរដ្ឋធម្មនុញ្ញក៏សិទ្ធិអំណាចមានជាមួយស្រាប់របស់តុលាការជាតិដែលមានចែងយ៉ាងច្បាស់នៅក្នុងលិខិតតុបករណ៍ អ.វ.ត.ក ទាំងនេះដែរ។ លើសពីនេះទៅទៀត ការមិនមានលក្ខខណ្ឌជាបឋមណាមួយ ឬក៏ការ យន្តការបញ្ជូននៅក្នុងលិខិតតុបករណ៍នេះ វាគាំទ្រទៅដល់អភ័យឯកសិទ្ធិតែម្តង ហើយក្នុងនោះក៏មានដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈរបស់តុលាការអាដហុកនេះផងដែរ។ ក៏ប៉ុន្តែបទប្បញ្ញត្តិដែលគ្របដណ្តប់ទៅលើតុលាការ អាដហុកនេះ គឺវាគ្របដណ្តប់ទៅលើរូបវន្តបុគ្គលទាំងអស់ ដោយមិនគិតអំពីតុលាការជាតិណាមួយនោះទេ។ ប៉ុន្តែករណីនេះ មិនមែនជាករណីនៅ អ.វ.ត.ក យើងនេះទេ។ ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេត ក៏ផ្ទុយទៅនឹងគោលបំណង និងកម្មវត្ថុនៃលិខិតតុបករណ៍របស់អ.វ.ត.ក នេះដែរ។ ច្បាស់បំផុតនោះ គឺច្បាប់បង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងបានបញ្ជាក់ថា អ.វ.ត.ក ត្រូវបានរៀបចំឡើងឲ្យក្លាយទៅជាតុលាការមួយដែលមានយុត្តាធិការមានកម្រិត និងផ្តាច់មុខទៅលើករណីដែលគ្របដណ្តប់ទៅលើមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិ និងឧក្រិដ្ឋកម្មជាតិដែលបានប្រព្រឹត្តនៅចន្លោះពីថ្ងៃ១៧ មេសា ៧៥ ដល់ ០៦ មករា ៧៩។ ហើយការសម្រេចបែបនេះ វាផ្ទុយទៅនឹងគោលបំណងនៃច្បាប់បង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងតែម្តង។ ជាពិសេសពាក់ព័ន្ធទៅនឹងនិទណ្ឌភាពនៃតួនាទីរបស់អតីតខ្មែរក្រហម ដូចដែលបានសម្រេចឡើងដោយ ស.ច.ស។ សេចក្តីសន្និដ្ឋានប្រកបហេតុផលតែមួយគត់នោះ គឺថាតុលាការកម្ពុជា គឺគ្របដណ្តប់ទៅលើឧក្រិដ្ឋកម្មដែលមិនស្ថិតនៅក្នុងយុត្តាធិការបុគ្គល ឬជាយុត្តាធិការពេលវេលារបស់សាលាក្តីនេះទេ។

បន្ទាប់មកខ្ញុំនិយាយអំពីការចរចា ប្រវត្តិនៃការចរចាបង្កើត អ.វ.ត.ក យើងនិយាយថា ប្រវត្តិនៃការចរចានេះ គឺមិនបានគាំទ្រទៅដល់សេចក្តីសន្និដ្ឋានទៅលើការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេត ជាពិសេសឯកអគ្គរដ្ឋទូត ដេវីដ សេហ្វ័រ ដែលបានដឹកនាំ -- សហរដ្ឋអាមេរិកខិតខំប្រឹងប្រែងបង្កើត អ.វ.ត.ក នៅក្នុងពេលគាត់កាន់តួនាទីជាឯកអគ្គរដ្ឋទូតសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាមចន្លោះពីឆ្នាំ៩៧

ទៅដល់២០០១ ដែលជាមនុស្សម្នាក់ពាក់ព័ន្ធយ៉ាងខ្លាំង ហើយជាពិសេសនៅថ្ងៃទី០៦ កញ្ញា ២០០៧ គឺថា ដេវីដ សេហ្វ័រ គាត់បានបង្ហាញនៅក្នុងកិច្ចព្រមព្រៀងជាមួយសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធទៅនឹងផលប៉ះពាល់នៃ អ.វ.ត.ក។ ខ្ញុំសូមរំឭកឡើងវិញ អំពីការចរចាពាក់ព័ន្ធទៅនឹងយុត្តាធិការបុគ្គលរបស់សាលាក្តីនេះ ដែលជាដំណើរការមួយចំណាយពេលជាច្រើនឆ្នាំ ហើយសេចក្តីថ្លែងការណ៍របស់គាត់ហ្នឹង គឺថាមាននៅក្នុងសំណុំរឿងហើយ គឺសេចក្តីថ្លែងការណ៍ហ្នឹង ខ្ញុំសូមដកស្រង់ចំណុចសំខាន់ៗដែលគាំទ្រទៅដល់សហសារណារបស់យើងខ្ញុំ។ ឯកអគ្គរដ្ឋទូត សេហ្វ័រ បាននិយាយថា ក្នុងការចរចាយើងតែងតែនិយាយអំពីអ្នកដែលស្ថិតនៅខាងក្រោមយុត្តាធិការនេះ គឺមិនមានការបដិសេធអំពីដំណើការជឿនលឿនទៅមុខ ដើម្បីទទួលស្គាល់អំពីការបរាជ័យរបស់តុលាការកម្ពុជា ដើម្បីផ្តន្ទាទោសពួកគេកាលពីអតីតកាលនោះទេ។ ខ្ញុំសូមរំឭកឡើងវិញថា យើងផ្តន្ទាទោសតែចារីដែលជាថ្នាក់ដឹកនាំជាន់ទាបខ្មែរក្រហមនោះទេ។ តើច្បាប់កម្ពុជាពាក់ព័ន្ធដោយរបៀបណា ហើយជាពិសេសសមត្ថភាពរបស់តុលាការជាតិអាចពាក់ព័ន្ធដោយរបៀបណា។ ហើយចំណុចចុងក្រោយគឺថា អ្នកចរចាកម្ពុជា និងអង្គការសហប្រជាជាតិមិនបានលើកឡើងផ្សេងពីនេះទេ។ ឯកអគ្គរដ្ឋទូត ដេវីដ សេហ្វ័រ បានសង្កត់ធ្ងន់ទៅលើបុព្វកថានៃកិច្ចព្រមព្រៀង អ.វ.ត.ក ដោយលើកឡើងថាដើម្បីគោលបំណង គឺដើម្បីបង្កើត អ.វ.ត.ក ហើយធ្វើការផ្តន្ទាទោសស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ។ ហើយចំណុចនេះគឺថាមិនបានយកមកចែងឲ្យបានច្បាស់លាស់នៅក្នុងដីកាដំណោះស្រាយនោះទេ។ នៅពេលដែលមេធាវីការពារក្តីមានបំណងថាការងាររៀបចំជាបឋមក៏ដូចជាការងារជាបន្តបន្ទាប់នោះ គឺថាវាជាយុត្តាធិការរបស់តុលាការជាតិទៅលើសម័យខ្មែរក្រហម។ មេធាវីការពារក្តីមិនបានលើកឡើងអំពីភស្តុតាងដែលថាគ្របដណ្តប់ វាបានគ្របដណ្តប់ទៅលើនិទណ្ឌភាពទាំងនេះនោះទេ។ គោលបំណងរបស់គេ គឺមិនមានបំណងថាឲ្យយកយុត្តាធិការទាំងអស់នេះមកដាក់ជំនួសទៅលើយុត្តាធិការតុលាការជាតិនោះទេ លើកលែងតែករណីមួយ ចំនួនកម្រិត ហើយដោយសារនៅពេលនោះគឺថា សមត្ថភាពតុលាការជាតិក៏មានកម្រិតផងដែរ។ ដូចសហភាតារបស់ខ្ញុំបានយល់ស្របហើយ រដ្ឋជាភាគីគឺកម្ពុជានេះ គឺមិនចង់ឲ្យមានការជ្រៀតជ្រែកទៅលើយុត្តាធិការរបស់តុលាការជាតិនោះទេ។ នៅពេលដែលយើងពិនិត្យទៅលើប្រវត្តិចរចារវាងកម្ពុជា និងអង្គការសហប្រជាជាតិ ពេលនោះយើងឃើញថា អ្វីដែលនៅក្រៅពីយុត្តាធិការនេះគឺថា អាចនឹងផ្តល់យុត្តាធិការទៅឲ្យតុលាការជាតិដែលអាចអ្នកផ្តល់ទៅឲ្យតុលាការជាតិជាអ្នកជំនុំជម្រះ។

ចំណុចសំខាន់មួយដែល ខ្ញុំលើកឡើងនេះគឺថា អង្គការសហប្រជាជាតិនឹងមិនដាក់ទណ្ឌកម្មទៅ

លើសេចក្តីសម្រេចណាមួយបែបនេះនោះទេ។ អ៊ីចឹងការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតនេះ គឺថាអង្គការសហប្រជាជាតិ គឺថាបានយល់ស្រប ហើយមិនផ្តល់ឲ្យនិទណ្ឌភាពក្នុងលក្ខណៈមួយទូលំទូលាយក្រោយពីកើតព្រឹត្តិការណ៍នោះហើយសម្រាប់ឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនោះទេ ហើយអង្គការសហប្រជាជាតិមិនបានចូលរួមនៅក្នុងការផ្តល់ការគាំទ្រណាមួយទៅដល់និទណ្ឌភាពណាមួយនោះទេ ហើយមានឧក្រិដ្ឋកម្មធ្ងន់ៗជាច្រើន ហើយឧក្រិដ្ឋកម្មទាំងអស់នេះបានរំលោភទៅលើច្បាប់អន្តរជាតិ ជាពិសេសពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវ ដែលផ្តល់សំណងទៅដល់ជនរងគ្រោះ អ.វ.ត.ក គឺមានយុត្តាធិការរបស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសេចក្តីសម្រេចស្តីអំពីអសុពលភាពនៃការលើកលែងទោសទៅឲ្យ អៀង សារី តាមរយៈព្រះរាជក្រមលើកលែងទោសមួយ ហើយក៏បានលើកឡើងផងដែរថាការលើកលែងទោសនោះគឺថាវារំលោភទៅដល់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ បន្ថែមទៅលើនេះទៀត លិខិតូបករណ៍អន្តរជាតិ ដូចជា អនុសញ្ញាប្រឆាំងនឹងទារុណកម្ម អនុសញ្ញាទីក្រុងហ្សឺណែវ ហើយអនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ធ្វើការផ្តន្ទាទោសយ៉ាងធ្ងន់។ រដ្ឋជាភាគីនៃសន្ធិសញ្ញាទាំងអស់នេះមិនអាចងាកចេញពីកាតព្វកិច្ចចំពោះការលើកលែងទោសជាផ្លូវការណាមួយ ឬច្បាប់ដែលបានកំណត់ឡើងដើម្បីផ្តល់នូវនិទណ្ឌភាព ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរនោះទេ។ ចំណុចនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងលើកឡើងនៅក្នុងសំណុំរឿង០០២ នៅក្នុងការសម្រេចអំពីព្រះរាជក្រម ឆ្នាំ១៩៩៦ ដែលជាការលើកលែងទោសឲ្យ អៀង សារី។ ជាការរំលោភធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឬក៏ការធ្វើទារុណកម្មដែលវាប្រឆាំងទៅនឹងកាតព្វកិច្ចរបស់កម្ពុជាទាំងស្រុង ក្នុងការផ្តន្ទាទោសឧក្រិដ្ឋកម្មទាំងអស់នេះ ជាពិសេស មាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

ការមិនមានការផ្តន្ទាទោសដោយតុលាការជាតិ វាមិនស្មើគ្នាទៅនឹង មិនមានន័យថា ជាការគាំទ្រទៅដល់ការលើកលែងទោសនោះទេ។ ហើយការយោងទៅលើការមិនមានការផ្តន្ទាទោសដោយតុលាការជាតិនេះចាប់តាំងពីការបង្កើត អ.វ.ត.ក មក ដែលជាការគាំទ្រទៅដល់ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតទៅលើយុត្តាធិការផ្តាច់មុខរបស់ អ.វ.ត.ក។ ការលើកឡើងទោស គឺវាជារឿងមួយដែលមិនចាំបាច់សម្រាប់តុលាការនេះទេ ដោយសារថា កម្ពុជាសព្វថ្ងៃនេះថាតើមានឆន្ទៈនយោបាយ ឬសមត្ថភាពដើម្បីផ្តន្ទាទោសតាមរយៈតុលាការជាតិ តាមរយៈច្បាប់ដែលយើងបានស្នើសុំឲ្យលោក លោកស្រីចៅក្រមធ្វើការវិនិច្ឆ័យនៅក្នុងថ្ងៃនេះតែម្តង។ ការមិនមានការផ្តន្ទាទោសដោយតុលាការជាតិនេះ គឺហើយប្រហែលជាដោយសារតែ អ.វ.ត.ក នេះកំពុងតែប្រតិបត្តិការនៅឡើយ ប៉ុន្តែចំណុចនេះ យើងមិន

ត្រូវ ហើយនិយាយអំពីយុត្តាធិការតុលាការជាតិនៅក្នុងសំណុំរឿងនេះទេ។

ដូច្នេះ អង្គបុរេជំនុំជម្រះត្រូវពិភាក្សាអំពីបញ្ហាច្បាប់ ថាតើការប្រព្រឹត្តកំហុសអង្គច្បាប់ដោយ ក.ស.ច.ស នេះ គឺថាវាមានផលប៉ះពាល់ដល់តុលាការជាតិ និងយុត្តាធិការរបស់ អ.វ.ត.ក យ៉ាងណាដែរ។ ភាគីនៅចំពោះមុខ អ.វ.ត.ក នេះជាការអនុវត្តជាក់ស្ដែង គឺបានទទួលស្គាល់នូវលទ្ធភាពនៃការផ្ដន្ទាទោសដោយតុលាការជាតិចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម។ សាលាដំបូងនេះនៅក្នុងសំណុំរឿង០០២ បានទទួលស្គាល់ថាជាគោលការណ៍ ការផ្ដន្ទាទោសតាមរយៈតុលាការជាតិចំពោះឧក្រិដ្ឋកម្មនាសម័យខ្មែរក្រហមនេះ នៅតែជាលទ្ធភាពមួយទៅតាមផ្លូវច្បាប់ដែលអាចធ្វើទៅបាន។ ហើយចំណុចហ្នឹងវាអាចពាក់ព័ន្ធទៅនឹងការផ្ដន្ទាទោសដោយតុលាការជាតិនៅពេលអនាគត។ ហើយអង្គជំនុំជម្រះសាលាដំបូងក៏បានបដិសេធការផ្ដន្ទាទោសណាមួយដោយតុលាការជាតិ ដោយសារតែភស្តុតាងទាំងអស់នេះកំពុងតែស្ថិតនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក។ ទាំងមេធាវីការពារក្ដីក៏ដូចគ្នា បានទទួលស្គាល់អំពីលទ្ធភាពនៃការផ្ដន្ទាទោសដោយតុលាការជាតិ ដែលបានស្នើសុំឱ្យមានការធានាដូចគ្នានេះដែរសម្រាប់សាក្សីរបស់ខ្លួន។ ភាគីទាំងអស់នៅក្នុងតុលាការនេះ គឺនៅក្នុងការអនុវត្តជាក់ស្ដែងរហូតមកដល់សព្វថ្ងៃនេះ គឺថាព្រះរាជអាជ្ញានៅក្នុងតុលាការជាតិ គឺថាគឺ អាចពិចារណាចំពោះចំណុចនេះបាន ដើម្បីសន្និដ្ឋានទៅដល់សារណារបស់យើងខ្ញុំ គឺថាមិនត្រូវ -- សហចៅក្រមស៊ើបអង្កេតនេះ គឺថាមិនត្រូវរំលោភទៅដល់អធិបតេយ្យភាពរបស់រដ្ឋជាភាគីនោះទេ។ នេះគឺ ចំណុចនេះមិនមែនជាចំណុចចម្រូងចម្រាសទេ សូម្បីតែមេធាវីការពារក្ដីក៏ទទួលស្គាល់ដែរ ថាមានតែតុលាការជាតិទេទើបអាចសម្រេចជាចុងក្រោយចំពោះកម្រិតនៃយុត្តាធិការរបស់ខ្លួន ទៅលើឧក្រិដ្ឋកម្មនាសម័យខ្មែរក្រហម។

សិទ្ធិជាមូលដ្ឋាន ក៏ដូចជាផលប្រយោជន៍របស់ជនរងគ្រោះ ក៏ដូចជាដើមបណ្ដឹងរដ្ឋប្បវេណី គឺយើងបានលើកឡើងយ៉ាងច្បាស់ហើយថា ត្រូវតែដោះស្រាយ ដើម្បីបញ្ហាផលប្រយោជន៍នេះ គឺត្រូវតែឈានទៅដល់ការដោះស្រាយទៅលើចំណុចនេះ ជាពិសេសដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌។

អង្គបុរេជំនុំជម្រះ គឺជាវេទិកាដែលសមស្របតែមួយគត់ដែលត្រូវដោះស្រាយបញ្ហា កំហុសផ្លូវច្បាប់។ យើងស្នើសុំឱ្យលោក លោកស្រីចៅក្រមដោះស្រាយកំហុសទាំងអស់នេះនៅក្នុងដំណោះស្រាយដោយប្រកាសថា តុលាការជាតិកម្ពុជា គឺមានសមត្ថភាពផ្លូវច្បាប់ និងដើម្បីធ្វើការផ្ដន្ទាទោសឧក្រិដ្ឋកម្មសម័យខ្មែរក្រហមដែលត្រូវសម្រេចឡើងដោយព្រះរាជាណាចក្រកម្ពុជា និងដោយតុលាការជាតិ។

ហើយទី២ យុត្តាធិការរបស់ អ.វ.ត.ក មិនអាចយកមកជំនួសសិទ្ធិអំណាចរបស់តុលាការជាតិនេះបានទេ។

ខ្ញុំសូមបញ្ចប់សេចក្តីសន្និដ្ឋានរបស់យើង ដោយសារតែអង្គជំនុំជម្រះ -- អង្គបុរេជំនុំជម្រះបានផ្តល់ពេលវេលាមួយម៉ោងមកឲ្យខាងក្រុមយើងខ្ញុំ ហើយយើងខ្ញុំស្នើសុំថា នឹងប្រើប្រាស់ពេលវេលាដើម្បីធ្វើការឆ្លើយតបណាមួយដែលពេលវេលាដែលនៅសេសសល់ពីរយៈពេលមួយម៉ោង ដែលតុលាការបានផ្តល់មកដល់យើងខ្ញុំ។

**ប្រធានអង្គបុរេ៖**

សំណូមពររបស់លោកស្រីមេធាវី យើងបានថែងនៅក្នុងសេចក្តីជូនដំណឹងរបស់យើងរួចអស់ហើយ យើងបានសម្រេចរួចហើយ ដូច្នេះអត់មានការឆ្លើយឆ្លងលើសេចក្តីសន្និដ្ឋានរបស់លោកស្រីទេបាទ។ អ៊ីចឹងសូមអរគុណបាទ។

ជាបន្តសូមអញ្ជើញសហព្រះរាជអាជ្ញាជាតិឡើងថ្លែងសេចក្តីសន្និដ្ឋានរបស់ខ្លួន។

សូមអញ្ជើញបាទ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណឯកឧត្តមប្រធាន។

សូមគោរពឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃអង្គបុរេជំនុំជម្រះ លោកចៅក្រមក្រុមប្រឹក្សានៃអង្គបុរេជំនុំជម្រះ រួមទាំងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ខ្ញុំឈ្មោះ សេង ប៊ុនឃាង ជាសហព្រះរាជអាជ្ញារង តំណាងឲ្យសហព្រះរាជអាជ្ញាជាតិ ដើម្បីចូលរួមនៅក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍នេះ។

យោងតាមបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានដាក់កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ បានប្តឹងជំទាស់ទៅនឹងដីកាដំណោះស្រាយដែលចេញដោយសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ដែលនៅក្នុងបណ្តឹងឧទ្ធរណ៍នោះ បានលើកឡើងអំពីកំហុសអង្គហេតុ និងកំហុសអង្គច្បាប់របស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយនេះ និងបានលើកឡើងអំពីទឡ្ហីករណ៍មួយចំនួន ព្រមទាំងបានស្នើឲ្យអង្គបុរេជំនុំជម្រះកែប្រែកំហុសអង្គច្បាប់ និងអង្គហេតុទាំងនោះ។ ជាមួយគ្នានេះដែរ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានស្នើសុំឲ្យអង្គបុរេជំនុំជម្រះបញ្ជូនសំណុំរឿងនេះ ត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញ ដោយណែនាំ

ឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការវាយតម្លៃឡើងវិញ ថាតើ អ៊ឹម ចែម ស្ថិតនៅក្នុងយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬយ៉ាងណា? ឬជាជម្រើសម្យ៉ាងទៀត សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យអង្គបុរេជំនុំជម្រះខ្លួនឯងផ្ទាល់ ធ្វើការវាយតម្លៃរឿងក្ដីនេះឡើងវិញ ដោយពិចារណាលើកំហុសអង្គច្បាប់ និងកំហុសអង្គហេតុទាំងអស់ដែលមាននៅក្នុងបណ្ដឹងឧទ្ធរណ៍នេះ។

នៅពេលនេះតំណាងសហព្រះរាជអាជ្ញាជាតិសូមលើកឡើងអំពីអំណះអំណាងមួយចំនួនទាក់ទងទៅនឹងរឿងក្ដីនេះ ហើយជាបឋម តំណាងសហព្រះរាជអាជ្ញាជាតិ សូមលើកយោងអំពីប្រវត្តិត្រួសៗនៃរឿងក្ដីនេះ ហើយដែលឈានរហូតមកដល់ដំណាក់កាលនាពេលសវនាការនាពេលនេះផងដែរ។ ទាក់ទងទៅនឹងការខ្វែងយោបល់របស់សហព្រះរាជអាជ្ញាលើសំណុំរឿងនេះ ឃើញថា នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ បានពិភាក្សាគ្នាលើបញ្ហាខ្វែងយោបល់គ្នា អំពីការប្ដឹងចោទជនសង្ស័យថ្មីបន្ថែមទៀត ផ្សេងពីជនសង្ស័យដែលមានស្រាប់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលហៅកាត់ថា អ.វ.ត.ក ដើម្បីបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតឲ្យបើកការស៊ើបសួរ។ ក្នុងនោះ ជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺមានបំណងដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរ ឲ្យបើកការស៊ើបអង្កេតលើជនសង្ស័យបន្ថែមសម្រាប់សំណុំរឿងលេខ ០០៣ និងសំណុំរឿងលេខ ០០៤។ បន្ទាប់ពីបានពិចារណាល្អិតល្អន់រួចមក សហព្រះរាជអាជ្ញាជាតិយល់ឃើញថា មិនត្រូវបើកការស៊ើបអង្កេតលើជនសង្ស័យបន្ថែមផ្សេងពីជនសង្ស័យដែលមានស្រាប់នៃសំណុំរឿងលេខ ០០១ និងសំណុំរឿងលេខ ០០២ នោះទេ ប៉ុន្តែករណីនេះ មិនអាចដោះស្រាយ និងឯកភាពគ្នាបានទេ រវាងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ទើបសហព្រះរាជអាជ្ញាអន្តរជាតិបានសម្រេចនាំយកករណីខ្វែងយោបល់គ្នានេះទៅចំពោះមុខអង្គបុរេជំនុំជម្រះដើម្បីចាត់ការបន្តតាមនីតិវិធីជាធរមានតរៀងមក។ ជាបន្ទាប់មកទៀត គឺអង្គបុរេជំនុំជម្រះបានផ្ដល់ឱកាសឲ្យសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ដាក់សេចក្ដីសន្និដ្ឋានផ្សេងៗដើម្បីលើកអំពីអំណះអំណាងតាមការយល់ឃើញរៀងៗខ្លួន ដែលក្នុងនោះសហព្រះរាជអាជ្ញាជាតិ បានលើកឡើងអំពីមូលហេតុនានា ដែលជារួម គឺមិនឯកភាពជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីនោះទេ ពោលគឺស្ថិតក្នុងសំណុំរឿងលេខ ០០៣ និងសំណុំរឿងលេខ ០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិនោះទេ។ ហើយសហព្រះរាជអាជ្ញាជាតិ ក៏បានដាក់ឯកសារយោងមួយចំនួនដែលជាគោលបំណងសំខាន់នៃការបង្កើត អ.វ.ត.ក នេះ ជាពិសេសឯកសារដែលទាក់ទងនឹងកិច្ចពិភាក្សារបស់

រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចពិភាក្សារវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិអំពីការបង្កើត អ.វ.ត.ក នេះផងដែរ។ សហព្រះរាជអាជ្ញាជាតិបានដាក់សេចក្តីសង្កេតនេះ ដោយបានលើកឡើងថា សហព្រះរាជអាជ្ញាជាតិនៅតែរក្សាជំហរថា ជនសង្ស័យដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនោះ ដែលក្នុងនោះរួមមាន អ៊ឹម ចែម ផងដែរនោះ មិនមែនជាបុគ្គលពីរប្រភេទដែលត្រូវនាំមកកាត់ទោសនៅ អ.វ.ត.ក ឡើយ។ ពោលគឺ អ៊ឹម ចែម មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.ត.វ.ក ទេ។ ការលើកឡើងបែបនេះ គឺសហព្រះរាជអាជ្ញាជាតិបានយោងទៅតាមច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក ដែលតម្រូវឲ្យតុលាការនេះធ្វើការវិនិច្ឆ័យទោស និងជំនុំជម្រះលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិ ដែលកម្ពុជាទទួលស្គាល់ ហើយបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

យោងតាមច្បាប់នេះ សហព្រះរាជអាជ្ញាជាតិបានប្រកាន់ជំហរថា ជនត្រូវចោទទាំងអស់ដែលមានឈ្មោះក្នុងសំណុំរឿងលេខ ០០៤ មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះទេ។ លើសពីនេះទៀត បើយើងពិនិត្យទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ក៏បានកំណត់យ៉ាងច្បាស់អំពីគោលបំណងនៃការបង្កើតតុលាការនេះ គឺដើម្បីវិនិច្ឆ័យទោសតែទៅលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដូចមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នេះដែរ។

[១០:៤៨:៥២]

ការណ៍នេះ បង្ហាញឲ្យឃើញថា ទាំងច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀងបានចង្អុលបង្ហាញអំពីតួនាទីរបស់ជនសង្ស័យ ដែលនឹងត្រូវយកមកធ្វើការវិនិច្ឆ័យទោស គឺមានតែពីរប្រភេទដូចបញ្ជាក់ខាងលើនេះ។ ចំណែកតួនាទីរបស់ អ៊ឹម ចែម មិនស្ថិតក្នុងចំណោមជនពីរប្រភេទដែលត្រូវយកមកវិនិច្ឆ័យសេចក្តីនៅ អ.វ.ត.ក នេះទេ។

សូមកត់សម្គាល់ដែរថា នៅក្នុងកិច្ចពិភាក្សាដើម្បីកំណត់ជ្រើសរើសយកជនសង្ស័យដើម្បីផ្តើមការចោទប្រកាន់ពីដំបូងនោះ គឺសហព្រះរាជអាជ្ញាទាំងពីរបានយល់ស្របនិងឯកភាពគ្នា ក្នុងការជ្រើស

រើសជនសង្ស័យចំនួនប្រាំរូបដើម្បីធ្វើការចោទប្រកាន់ដាក់ជូនទៅសហចៅក្រមស៊ើបអង្កេតដើម្បីបើកការស៊ើបសួរ។ ហើយមូលហេតុនៃការជ្រើសរើសជនសង្ស័យទាំងប្រាំរូបនោះ គឺដោយសារជនសង្ស័យទាំងនេះ ត្រូវបានសហព្រះរាជអាជ្ញាកំណត់ថាជាមេដឹកជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ នៅក្នុងពេលនោះ ការកំណត់ជនសង្ស័យប្រាំរូបខាងលើនេះ រួមមានគឺ នួន ជា, ខៀវ សំផន, អៀង សារី , អៀង ធីរិទ្ធ និង កាំង ហ្កេកអ៊ាវ ហៅ ឌុច ថាជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជាជនទាំងឡាយដែលទទួលខ្ពស់បំផុត យោងទៅតាមច្បាប់។

ការកំណត់បែបនេះ គឺសហព្រះរាជអាជ្ញាអន្តរជាតិបានយល់ -- (សូមទោស) ការកំណត់បែបនេះគឺសហព្រះរាជអាជ្ញាជាតិបានយល់ឃើញថា ពួកគាត់មានតួនាទីចម្បងៗដែលរួមមានដូចខាងក្រោម ៖ លោក នួន ជា គឺជាអនុលេខាបក្សនៃបក្សកម្មុយនីស្តកម្ពុជា ជាសមាជិកអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ និងមានតួនាទីផ្សេងៗទៀតផងដែរ។ ចំពោះលោក ខៀវ សំផន គឺជាប្រធានគណៈប្រធានរដ្ឋ និងជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងមានតួនាទីផ្សេងៗទៀតផងដែរ។ ចំពោះលោក អៀង សារី គឺជាសមាជិកអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស ព្រមទាំងមានតួនាទីផ្សេងៗទៀតផងដែរ។ ចំពោះលោកស្រី អៀង ធីរិទ្ធ គឺជាសមាជិកមជ្ឈិមបក្សនៃបក្សកុម្មុយនីស្ត និងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងមានតួនាទីផ្សេងៗទៀតផងដែរ។ ចំពោះឯ កាំង ហ្កេកអ៊ាវ ហៅ ឌុច គឺជាប្រធានមន្ទីរសន្តិសុខស-២១ ដែលជាមន្ទីរសន្តិសុខមានលក្ខណៈពិសេសជាងគេក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនិងមានតួនាទីផ្សេងៗទៀតផងដែរ។

[១០:៥២:០០]

ផ្ទុយទៅវិញ អ៊ឹម ចែម ដែលមានឈ្មោះនៅក្នុងសំណុំរឿងនេះ សហព្រះរាជអាជ្ញាជាតិយល់ឃើញ មិនស្ថិតក្នុងតួនាទីជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងមិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក នោះទេ។

បើយើងក្រឡេកទៅមើលគោលបំណងនៃការបង្កើតច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង គឺមានលក្ខណៈពិសេស ខុសពីច្បាប់ទូទៅ មានន័យថា ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង គឺបានកម្រិតទាំង

យុត្តាធិការពេលវេលា និងយុត្តាធិការបុគ្គល ពោលគឺមិនអនុវត្តដូចគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌទូទៅទេ ព្រោះថា គោលការណ៍ច្បាប់ព្រហ្មទណ្ឌទូទៅ គឺបណ្តឹងអាជ្ញាត្រូវឲ្យមានការអនុវត្តចំពោះបុគ្គលទាំងអស់ដែលបានប្រព្រឹត្តបទល្មើស។ ផ្ទុយទៅវិញ ចំពោះច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង បានកម្រិតឲ្យធ្វើការវិនិច្ឆ័យទោសតែលើជនពីរប្រភេទ ដែលបានប្រព្រឹត្តឧក្រិដ្ឋស្ថិតក្នុងយុត្តាធិការ អ.វ.ត.ក។ លើសពីនេះទៀតច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង គឺមានគោលបំណងធ្វើការកាត់សេចក្តី ដោយមានការផ្សាភ្ជាប់ទៅនឹងការផ្សះផ្សា បង្រួបបង្រួមជាតិ និងជាពិសេស ដើម្បីទុកជាកេរដំណែលឲ្យអ្នកជំនាន់ក្រោយបានដឹងអំពីព្រឹត្តិការណ៍ជូរចត់ និងសាហាវយង់ឃ្នងនៃរបបកម្ពុជាប្រជាធិបតេយ្យ និងដើម្បីចៀសវាងកុំឲ្យមានអំពើបែបនេះកើតមានឡើងតទៀត។

ម្យ៉ាងវិញទៀត ឃើញថា បើសិនជាចាំបាច់ត្រូវធ្វើការវិនិច្ឆ័យសេចក្តីទៅលើជនសង្ស័យចំនួនច្រើននោះ ប្រហែលជាច្បាប់មិនចាំបាច់ត្រូវកំណត់យុត្តាធិការបុគ្គលតែត្រឹមពីរប្រភេទប៉ុណ្ណោះទេ គឺអាចនឹងមានច្រើនប្រភេទទៀត។ ហើយចំពោះយុត្តាធិការពេលវេលា ក៏មិនមែនមានត្រឹមតែរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះដែរ គឺអាចមានតាំងពីជំនាន់មុនៗមកម្ល៉េះ។ ជាតួយ៉ាង យើងមើលទៅឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា មិនមែនមានតែក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ គឺមានតាំងពីសម័យសាធារណរដ្ឋខ្មែរ ដែលដឹកនាំដោយលោក លន់ នល់ មកម្ល៉េះ។ យើងដឹងហើយថា ក្នុងរបបសាធារណរដ្ឋខ្មែរក៏មានការទម្លាក់គ្រាប់បែកយ៉ាងច្រើនសន្ធឹកសន្ធាប់ និងបណ្តាលឲ្យមនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់ ស្លាប់ ពិការភាព និងបណ្តាលឲ្យទ្រព្យសម្បត្តិ ផ្ទះសម្បែងប្រជាជនត្រូវខូចខាតយ៉ាងដំណំជាច្រើនផងដែរ។ ដូច្នេះការកំណត់របស់ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង មិនបានបំពេញទៅតាមគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌទូទៅនោះទេ។ ហើយមូលហេតុសំខាន់នៃការកាត់សេចក្តីនៅ អ.វ.ត.ក នេះ គឺមានផ្សាភ្ជាប់ជាមួយនឹងការព្រួយបារម្ភជាពិសេសរបស់អង្គការសហប្រជាជាតិចំពោះបញ្ហាស្ថិរភាព សន្តិសុខរបស់ប្រទេសកម្ពុជា។ ដោយសារតែការព្រួយបារម្ភជាពិសេសនេះហើយ ទើបសហព្រះរាជអាជ្ញាជាតិប្រកាន់ជំហរគិតគូរដល់ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ មុននឹងធ្វើការប្តឹងចោទប្រកាន់។ ដូច្នេះឃើញថា ជំហររបស់សហព្រះរាជអាជ្ញាជាតិចំពោះការស៊ើបសួរបឋម ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងរហូតដល់បិទកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត គឺសហព្រះរាជអាជ្ញាជាតិយល់ឃើញថា ជនត្រូវចោទដែលមាននៅក្នុងសំណុំរឿងលេខ ០០៤/១ នេះមិនស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ។ តាមរយៈការយល់ឃើញនេះ

ហើយ ទើបសហព្រះរាជអាជ្ញាជាតិ មិនត្រឹមតែមិនចូលរួមក្នុងកិច្ចនីតិវិធីស៊ើបអង្កេតបឋមជាមួយសហព្រះរាជអាជ្ញាអន្តរជាតិប៉ុណ្ណោះទេ គឺថែមទាំងបញ្ជាក់អំពីជំហរខ្វែងយោបល់គ្នាជាមួយសហព្រះរាជអាជ្ញាអន្តរជាតិផងដែរ។

[១០:៥៧:២២]

ទាក់ទងទៅនឹងការខ្វែងយោបល់គ្នានេះគឺថា បន្ទាប់ពីសហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋាន និងអំណះអំណាងនានារួចមក អង្គបុរេជំនុំជម្រះបានធ្វើការពិភាក្សាគ្នាដើម្បីសម្រេចសេចក្តី ក៏ប៉ុន្តែអង្គបុរេជំនុំជម្រះមិនអាចសម្រេចសេចក្តីបានទេ ដោយសារមិនទទួលបាននូវសំលេងគាំទ្រពីចៅក្រមបួនរូបយ៉ាងតិចដើម្បីធ្វើការសម្រេចលើការខ្វែងយោបល់គ្នានេះ។ ដូច្នេះមានន័យថា ការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះដើម្បីបើកការស៊ើបសួរ មិនមែនធ្វើឡើងដោយសេចក្តីសម្រេច ដែលទទួលបានសំលេងគ្រប់គ្រាន់ពីចៅក្រមនៃអង្គបុរេជំនុំជម្រះទេ ពោលគឺធ្វើទៅតាមវិធាន៧១(៤) នៃវិធានផ្ទៃក្នុងតែប៉ុណ្ណោះ។ ថ្វីត្បិតតែមានការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះក៏ដោយ ក៏បន្ទាប់ពីការស៊ើបសួររហូតមកដល់ដំណាក់កាលនេះ សហព្រះរាជអាជ្ញាជាតិនៅតែយល់ឃើញថា ជនជាប់ចោទដែលមានឈ្មោះនៅក្នុងសំណុំរឿងនេះ មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ។ ការយល់ឃើញនេះ គឺមានស្របគ្នាជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបានសម្រេចថា អ៊ឹម ចែម មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ។

[១០:៥៩:១០]

សរុបសេចក្តីមក គឺសហព្រះរាជអាជ្ញាជាតិមានជំហរយ៉ាងច្បាស់ ដោយយោងទៅតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ គឺមានតែជនជាប់ចោទដែលមានស្រាប់នៅ អ.វ.ត.ក តែប៉ុណ្ណោះ ដែលជាមេដឹកនាំជាន់ខ្ពស់ និងជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ តាមរយៈការយល់ឃើញបែបនេះហើយ ទើបសហព្រះរាជអាជ្ញាជាតិមានការខ្វែងយោបល់ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិនៅគ្រប់ដំណាក់កាលចំពោះការកំណត់ជនសង្ស័យបន្ថែមនេះ។ លើសពីនេះទៀត បើយើងឃើញថា យើងពិនិត្យឃើញថា គ្មានគោលការណ៍ច្បាស់លាស់ណាមួយក្នុងការកំណត់អំពីប្រភេទដែលជាមេដឹកនាំជាន់ខ្ពស់ ឬជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ។ តួយ៉ាង បើយើងពិនិត្យទៅមើលសេចក្តីប្រកាសព័ត៌មានរបស់

សហព្រះរាជអាជ្ញាអន្តរជាតិកន្លងមក បានបញ្ជាក់ថាសហព្រះរាជអាជ្ញាអន្តរជាតិនឹងមិនធ្វើការស៊ើបអង្កេតលើជនសង្ស័យបន្ថែមផ្សេងទៀតនោះទេ ហើយក៏បានបញ្ជាក់ថាសំណុំរឿងនេះ គឺជាសំណុំរឿងចុងក្រោយផងដែរ។ តាមរយៈសេចក្ដីប្រកាសព័ត៌មាននេះឃើញថា ការវាយតម្លៃរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការជ្រើសរើសជនសង្ស័យដើម្បីយកមកធ្វើការវិនិច្ឆ័យទោស គឺហាក់ដូចជា មិនមានគោលការណ៍ច្បាស់លាស់ក្នុងការជ្រើសរើសនោះទេ។

ហេតុដូច្នេះហើយ ទើបសហព្រះរាជអាជ្ញាជាតិយល់ឃើញថា អ.វ.ត.ក គួរតែផ្ដល់អាទិភាពទៅលើការវិនិច្ឆ័យទោសជនជាប់ចោទដែលមានស្រាប់ទាំងនេះ ដើម្បីបំពេញឲ្យបានគ្រប់គ្រាន់ចំពោះអាណត្តិរបស់ខ្លួន ព្រោះថាច្បាប់អ.វ.ត.ក និងកិច្ចព្រមព្រៀង បានគិតទុកជាមុនរួចហើយ អំពីការវិនិច្ឆ័យទោសដែលត្រូវធ្វើតែទៅលើបុគ្គលមួយចំនួនតូចប៉ុណ្ណោះ។

[១១:០១:៣២]

ជាពិសេស នៅក្នុងកិច្ចព្រមព្រៀងតាមរយៈបុព្វកថា ដែលបានយោងសេចក្ដីសម្រេចចិត្តលេខ ៥៧/២២៧ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺអង្គការសហប្រជាជាតិបានទទួលស្គាល់ការព្រួយបារម្ភយ៉ាងជាក់លាក់ អំពីការព្រួយបារម្ភពេញច្បាប់របស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ។

ផ្ដើមចេញពីការទទួលស្គាល់នេះហើយ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងបានតម្រូវឲ្យសហព្រះរាជអាជ្ញាជ្រើសរើសយកបុគ្គលតែពីរប្រភេទប៉ុណ្ណោះ មកធ្វើការវិនិច្ឆ័យសេចក្ដី គឺមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវបំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ។ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេកម្ពុជាទទួលស្គាល់ ហើយបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

[១១:០៣:១៧]

ហេតុដូច្នេះ តំណាងសហព្រះរាជអាជ្ញាជាតិយល់ឃើញថា អ៊ឹម ចែម មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលដែលត្រូវយកធ្វើការវិនិច្ឆ័យសេចក្ដីឡើយ។

ដូច្នេះ សូមឯកឧត្តមប្រធានក្រុមប្រឹក្សានៃអង្គបុរេជំនុំជម្រះ និងចៅក្រមនៃអង្គបុរេជំនុំជម្រះទាំងអស់ មេត្តាសម្រេចតម្កល់ការសម្រេចសេចក្តីលើកលែងចោទប្រកាន់ អ៊ឹម ចែម ទៅតាមច្បាប់ដោយអនុគ្រោះ។ បាទសូមអរគុណ។

**ប្រធានអង្គបុរេ៖**

សវនាការនៅព្រឹកនេះ យើងឈានដល់ការសម្រាកជាបណ្តោះអាសន្ន ហើយយើងនឹងបន្តសវនាការនៅម៉ោងដប់បី និងសាមសិបនាទីទៀត។ ដូច្នេះ ប្រកាសសម្រាក។

សូមអរគុណ។

*(សវនាការសម្រាកពីម៉ោង ១១:០៤ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:០១]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គបុរេ៖**

សូមអញ្ជើញអង្គុយចុះ!

សូមចាប់ផ្តើមធ្វើការងារ។

ជាបឋមសូមអញ្ជើញលោកព្រះរាជអាជ្ញាអន្តរជាតិធ្វើសេចក្តីសន្និដ្ឋាន។ សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន ហើយនិងសូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងភាគីមេធាវីការពារក្តី ហើយនិងសហសេវិករបស់ខ្ញុំទាំងអស់នេះនៃការិយាល័យសហព្រះរាជអាជ្ញា។

ឥឡូវនេះខ្ញុំសូមអនុញ្ញាតជម្រាបថា ខ្ញុំជឿជាក់ថា អ៊ឹម ចែម គឺជាបុគ្គលម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃបទឧក្រិដ្ឋរបបកម្ពុជាប្រជាធិបតេយ្យ ហើយនៅក្រោមច្បាប់បង្កើត អ.វ.ត.ក ហើយនិងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ ដោយហេតុថា ភាពធ្ងន់ធ្ងរនៃអំពើ ហើយនិងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់នៃអំពើរបស់គាត់ទាក់ទងទៅនឹងជនរងគ្រោះរាប់ពាន់នាក់នៃបទឧក្រិដ្ឋនោះ។

[១៣:៣០:៥៦]

ហើយខ្ញុំសូមជម្រាបថា គឺថាក្នុងផលប្រយោជន៍នៃយុត្តិធម៌ ហើយនិងក្នុងផលប្រយោជន៍នៃការ

ផ្សះផ្សាជាតិដែលយើងត្រូវទទួលខុសត្រូវ ឲ្យគាត់ទទួលខុសត្រូវចំពោះអ្វីដែលគាត់បានធ្វើ ហើយការបញ្ជូនរឿងគាត់ទៅជំនុំជម្រះ គឺអាចជាការនាំមកនូវយុត្តិធម៌ ដូចជា ករណី នួន ជា, ខៀវ សំផន ហើយ និង ឌុច ដែលថានាំមកនូវយុត្តិធម៌ ហើយនិងនាំឲ្យមានកេរដំណែលតុលាការសម្រាប់កម្ពុជាទៅថ្ងៃអនាគត និងជនជំនាន់ក្រោយផងដែរ។ ដើម្បីនិយាយដោយសង្ខេប គឺថាបទឧក្រិដ្ឋដែលប្រព្រឹត្តដោយរបបឃោរឃៅនេះ មិនអាចនឹងកើតមានឡើងនោះទេ។ ដូចជាបណ្តឹងឧទ្ធរណ៍នេះ ដូចខ្ញុំបានលើកឡើងគឺថាគាត់ជាជនទទួលខុសត្រូវ មិនមែនជាបញ្ហានៅក្នុងបណ្តឹងសាទុក្ខឧទ្ធរណ៍នេះទេ។ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ទាំងសហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសម្រេចតាមទស្សនៈរបស់ពួកគាត់ ហើយ អ៊ឹម ចែម គឺថាមិនស្ថិតនៅក្នុងបុគ្គលដែលទទួលខុសត្រូវ ហើយមិនមែនជាជនមេដឹកនាំជាន់ខ្ពស់ដែលយើងមិនតវ៉ាទេ ប៉ុន្តែគាត់ជាជនដែលទទួលខុសត្រូវខ្ពស់បំផុត ប៉ុន្តែបណ្តឹងឧទ្ធរណ៍នេះ គឺថាមិនមែនផ្អែកលើថា ខ្ញុំមិនយល់ស្របទៅលើសេចក្តីសម្រេចនោះទេ ប៉ុន្តែផ្អែកលើអង្គហេតុដែលថា នៅពេលដីកាដំណោះស្រាយចេញមកដំបូង ដូចដែលលោកស្រីចៅក្រមជ្រាបហើយថា គឺថាមានមូលហេតុ សំអាងហេតុខ្លីៗ ដែលខ្លួនបញ្ជាក់ថា នឹងផ្តល់សំអាងហេតុនៅពេលក្រោយ ហើយនៅពេលដែលយើងបានសួរថា តើយើងអាចប្តឹងឧទ្ធរណ៍បានឬមិនបាន យើងសុំពេលអានឲ្យច្រើនដើម្បីយល់ថា តើអ្វីដែលជាមូលដ្ឋាន? គឺមានតែអានរួចសិននោះទេ ទើបដែលយើងឃើញមូលដ្ឋានដែលមានចែងនៅក្នុងសំអាងហេតុនៃដីកាដំណោះស្រាយ ទើបដែលយើងអាចកំណត់កំហុសអង្គច្បាប់ ហើយនិងកំហុសអង្គហេតុមួយចំនួននោះ ដែលតាមទស្សនៈរបស់យើង ដូចដែលខ្ញុំនឹងពន្យល់ គឺអាចនឹងប៉ះពាល់ទៅដល់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ថាតើ អ៊ឹម ចែម គឺថាស្ថិតនៅក្នុងជនដែលទទួលខុសត្រូវបំផុតដែរឬទេនោះ?

[១៣:៣៣:១៨]

ដូច្នេះយើងច្បាស់ហើយថា ពួកគាត់ផ្អែកទៅលើ -- សេចក្តីសម្រេចរបស់គាត់តែលើតែមួយផ្នែកឬក៏ថា ផ្អែកទៅលើការបកស្រាយច្បាប់ដែលមានកំហុស ហើយនិងផ្អែកលើការរកឃើញខាងអង្គហេតុវិញ គឺមានមុខតំណែងរបស់គាត់មួយចំនួន ដែលថា មិនមានចៅក្រមអង្គជំនុំជម្រះណាដែលអាចសម្រេចបែបនោះបានទេ បើមើលអង្គហេតុពីតួនាទីរបស់គាត់ទៅ គឺប្រាកដជាសម្រេចថា គាត់ទទួលខុសត្រូវហើយ។ ហើយតាមពិតនោះ គឺអ្វីជាស្តង់ដារនៃការពិនិត្យនេះ ពិនិត្យឡើងវិញនោះ គឺថាដែលមេធាវីនិយាយជាញឹកញាប់ គឺថាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា គឺមិនប្រឆាំងទៅនឹងឆន្ទានុសិទ្ធិ

របស់សហចៅក្រមស៊ើបអង្កេតថា តើគាត់ទទួលខុសត្រូវនោះឬទេ? ប៉ុន្តែយើងមានការពិភាក្សារបស់អង្គជំនុំជម្រះតុលាការកំពូលអំពីករណី ឌុច ដែលថាមិនបាន -- ដែលបានបញ្ជាក់ថា វាមិនមានព្រំដែនច្បាស់លាស់ទេ គឺថាអាចនឹងត្រូវប្តឹងឧទ្ធរណ៍បានប្រសិនបើបំពានទៅលើវិជ្ជាជីវៈនៃការជំនុំជម្រះនៃការសម្រេច ហើយក៏មិនមានព្រំដែនច្បាស់លាស់កំណត់នោះដែរ។ ប៉ុន្តែសេចក្តីសម្រេចផ្អែកលើឆន្ទានុសិទ្ធិដែលផ្អែកនៅលើការបកស្រាយច្បាប់មិនត្រឹមត្រូវនោះ គឺថាមិនត្រឹមត្រូវ ក៏ដូចគ្នានឹងអង្គហេតុនោះដែរ ហើយក៏អាចនឹងធ្វើឱ្យសេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេតហ្នឹងទៅជាគ្មានសុពលភាព។ ដូច្នេះហើយទើបបានយើងធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីម្រេចរបស់គាត់ ដើម្បីរកឃើញថា ដោយពួកគាត់បានមិនអើពើនឹងច្បាប់មួយចំនួន ដែលចែងនៅក្នុងច្បាប់អន្តរជាតិ ហើយនិងច្បាប់របស់ខ្លួនឯងដែលខ្លួនទទួលស្គាល់ក្នុងសេចក្តីសម្រេចមុនៗរួចមកហើយនោះដែរ។

ជាមូលដ្ឋាន គឺថាមានលក្ខណៈវិនិច្ឆ័យបីដែលថា សេចក្តីសម្រេចឆន្ទានុសិទ្ធិនេះ អាចនឹងត្រូវបដិសេធចោល គឺថានៅក្នុងរឿងស្វូស៊ីល នៅក្នុង នៅថ្ងៃទី១៧ មេសា ឆ្នាំ២០០៧ នៅតុលាការ អាយ.ស៊ី.ធី.វ៉ាយ កថាខណ្ឌ១៤។ អង្គជំនុំជម្រះនោះសម្រេចថា អាចនឹងបដិសេធចោលការប្រើប្រាស់ឆន្ទានុសិទ្ធិនោះ គឺថាបើសិនជាគេរកឃើញថា បានផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើច្បាប់អភិបាល ហើយនិងផ្អែកលើសេចក្តីសន្និដ្ឋានខុសច្បាស់ក្រឡែតលើអង្គហេតុ។ ហើយតុលាការ អាយ.ស៊ី.ធី.អ័រ ឬតុលាការរវ៉ាន់ដា នៅក្នុងរឿងក្តី អ៊ុនវិនយិនឌី គឺសេចក្តីសម្រេចលើការចោទប្រកាន់ គឺថ្ងៃទី១៦ វិច្ឆិកា ឆ្នាំ២០១១ គឺថាកថាខណ្ឌ៦ តុលាការនោះបញ្ជាក់ថា អង្គជំនុំជម្រះនឹងបដិសេធចោលនូវសេចក្តីសម្រេចរបស់សាលាដំបូង ដោយផ្អែកលើឆន្ទានុសិទ្ធិហ្នឹង បើសិនជាសេចក្តីសម្រេចនោះផ្អែកលើការបកស្រាយខុសទៅលើច្បាប់អភិបាល ហើយផ្អែកទៅលើកំហុសឆ្គងនៃសេចក្តីសន្និដ្ឋានលើអង្គហេតុ។ ហើយទី២ គឺថា ដោយសារសេចក្តីសន្និដ្ឋាននោះគឺមិនត្រឹមត្រូវ គឺថាវាមានភាពខុសគ្នា ត្រូវតែបង្ហាញអំពីកំហុសរបស់តុលាការជាន់ក្រោមដែលយើងពិនិត្យឃើញថា គឺមានតែសេចក្តីសម្រេចដែល អ្នកដែលស្វែងរកការពិតមិនអាចធ្វើសេចក្តីសម្រេចបែបនេះទេ ទើបបានយើងប្រកាសមិនបាន ដូចដែលយើងមានសេចក្តីពន្យល់ការលើកឡើងមូលដ្ឋានខុសអំពីករណីនេះ។

[១៣:៣៧:០៨]

គឺថាចំណុចទី៣គឺថាៗ ទី៣ គឺទាល់តែការសម្រេចនោះគឺមិនសមហេតុផលហួសហេតុ ដែលបង្កើតបានជាការបំពានទៅលើឆន្ទានុសិទ្ធិរបស់សាលាដំបូង។ ដូច្នេះហើយគឺមិនទាក់ទងទៅលើការ

បំពានឆន្ទានុសិទ្ធិទេ គឺបណ្តឹងឧទ្ធរណ៍របស់យើង គឺផ្អែកលើកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ។

នៅក្នុងការឆ្លើយតបរបស់ អ៊ឹម ឆែម គឺថាឆ្លើយបញ្ហាមួយចំនួន ដូចជាស្តង់ដារនៃការបណ្តឹងឧទ្ធរណ៍ នៅក្នុងកថាខណ្ឌ១៣ ដែលពួកគាត់បានដាក់នោះ គាត់បានដកស្រង់សេចក្តីសម្រេចមិនត្រឹមត្រូវ គឺសេចក្តីសម្រេចរបស់តុលាការសាលាដំបូង គឺក្នុងរឿងក្តី០០២ ថ្ងៃទី០២ ១២ គឺ D16/6 នៅក្នុងកថាខណ្ឌ២៦ និយាយថា នៅក្នុងការប្រើនូវបញ្ហាឆន្ទានុសិទ្ធិ បញ្ហាមិនថាតើសាលាឧទ្ធរណ៍ព្រម ឬមិនព្រមនោះ ប៉ុន្តែថាតើអង្គជំនុំជម្រះបានប្រើឆន្ទានុសិទ្ធិត្រឹមត្រូវក្នុងការសម្រេចនោះដែរឬទេ?

ដើម្បីនឹងតវ៉ា នោះគឺថាសេចក្តីសម្រេចបែបនេះ គឺថាអ្នកប្តឹងឧទ្ធរណ៍ត្រូវតែបង្ហាញថាអង្គជំនុំជម្រះ គឺថាបានប្រើគោលការណ៍មិនត្រឹមត្រូវ ឬក៏ច្បាប់ដែលពាក់ព័ន្ធហ្នឹងមិនត្រឹមត្រូវ ដើម្បីប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ឬក៏មិនបានថ្លឹងថ្លែងឲ្យបានគ្រប់គ្រាន់នូវការពិចារណាដែលពាក់ព័ន្ធ ឬក៏បានមានកំហុសឆ្គងលើអង្គហេតុដែលខ្លួនយកមកប្រើសម្រេចឆន្ទានុសិទ្ធិនេះ។ ដូច្នេះគឺថា នេះជាមូលហេតុនៃបណ្តឹងឧទ្ធរណ៍របស់យើងខ្ញុំ គឺកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ។ ហើយយើងនឹងពិនិត្យមើលថាតើកំហុសឆ្គងហ្នឹង គឺថាខុសឆ្គងធ្ងន់ គឺអយុត្តិធម៌ខ្លាំង គឺថាអាចនឹងដែលបង្ហាញថា ខ្លួនមិនប្រើឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យត្រឹមត្រូវទេ។ មួយទៀត គឺថាមិនជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់ទេ យើងនិយាយថានៅក្នុងកំហុសអង្គច្បាប់ ឬក៏កំហុសនៃអង្គហេតុនេះ គឺថាកំហុសទាំងនេះអាចធ្វើឲ្យសេចក្តីសម្រេចរបស់ពួកគាត់ហ្នឹង គឺគ្មានសុពលភាព។ ដូច្នេះយើងពិនិត្យមើលទៅលើ គាត់រៀបរាប់ពីការងាររបស់គាត់ ហើយនិងថាតើវាយតម្លៃពីតួនាទី ហើយនិង អ៊ឹម ឆែម និងអ្នកដទៃទៀត ថាអាចជាជនទទួលខុសត្រូវដែរឬអត់ គឺថាគាត់បានពិនិត្យមើលមួយចំនួន គឺគាត់បានពិភាក្សានៅក្នុងកថាខណ្ឌ៣៨ជាដើមនោះ។ ហើយពិនិត្យមើលអំពើតើអ្វីជាបទឧក្រិដ្ឋនៅក្នុងអំពើរបស់គាត់។ ទី២ ពួកគាត់មើលផលប៉ះពាល់ ផលវិបាកនៃអំពើឧក្រិដ្ឋនេះទៅលើជនរងគ្រោះ។

[១៣:៤០:២៤]

ហើយនៅក្នុងកថាខណ្ឌ៣៩ តាមពិតតួនាទីរបស់គាត់ដែលជនសង្ស័យបានកាន់នោះគឺថា គឺជាបញ្ហាពាក់ព័ន្ធ គឺតំណែងកាន់តែខ្ពស់ គឺថាលទ្ធភាពដែលគាត់អាចនឹងប្រើឥទ្ធិពលលើគោលនយោបាយទាំងឡាយនោះបាន។ ដូច្នេះ យើងយល់ស្របជាមួយនឹងអ្វីដែលចៅក្រមស៊ើបអង្កេតនឹងបានប្រកាន់យកអ្វីដែលគាត់ធ្វើនោះតើជាបទឧក្រិដ្ឋដែលឬទេ?បាទ បើសិនជាដូច្នោះមែនថាតើតួនាទីរបស់គាត់ដូចម្តេច? ថាតើដោយផ្ទាល់ ឬយ៉ាងម៉េច? តើផលវិបាកយ៉ាងដូចម្តេច ថាតើទៅលើជនរងគ្រោះ តើពួកគេឈឺចាប់

ដូចម្ដេច? អ៊ីចឹងគឺថាបើពួកគេទទួលផលវិបាក ការឈឺចាប់រហូតដល់មាននៅក្នុងសង្គមខ្មែរបច្ចុប្បន្នជាដើមហ្នឹង។ ហើយអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា បើការខកខានមិនបានពិនិត្យមើលផលវិបាកនៃការបោសសម្អាតភូមិភាគពាយ័ព្យនោះ គឺថាៗមានកម្មាភិបាល១០០០នាក់ ត្រូវបានបោសសម្អាតនៅក្នុងភូមិភាគពាយ័ព្យ។ នេះជាអ្វីដែលសហចៅក្រមស៊ើបអង្កេតបានអះអាងថា គាត់បានទទួលសំណុំរឿងហ្នឹង គួរតែបានវាយតម្លៃ ហើយនិងរកឲ្យឃើញការទទួលខុសត្រូវចំពោះផលវិបាកនេះ។

[១៣:៤១:៥៣]

បញ្ហាមួយទៀតនោះ ដែលយើងលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់យើង គឺថាអាពាហ៍ពិពាហ៍ដោយបង្ខំ។ សហចៅក្រមស៊ើបអង្កេតបានរកឃើញភស្តុតាងមួយចំនួន ភស្តុតាងដោយផ្ទាល់អំពីសាក្សី អំពីការរៀបការដោយបង្ខំ អំពី អ៊ឹម ចែម ថាបានមានតួនាទីនៅក្នុងការរៀបការដោយបង្ខំ។ ហើយគួរឲ្យចាប់អារម្មណ៍ណាស់ដែលសហចៅក្រមស៊ើបអង្កេតបានរកឃើញថា អ៊ឹម ចែម ទទួលខុសត្រូវ ភស្តុតាងបង្ហាញថាគាត់ទទួលខុសត្រូវ គឺថាអាចនឹងគ្រប់គ្រាន់ដើមបញ្ជូនទៅជម្រះ។ ចំពោះអំពើមួយទៀត គឺដាក់ឲ្យទៅជាទាសករ ដូចជាករណីនៅស្ពានស្រែង។ នៅការដ្ឋានស្ពានស្រែង យើងមានភស្តុតាងផ្ទាល់ពីជនរងគ្រោះនៃការរៀបការដោយបង្ខំ គឺ សែន សុផុន គាត់បានឃើញគេរៀបចំមនុស្សមួយចំនួនឲ្យរៀបការ ហើយ អ៊ឹម ចែម គាត់ជាអ្នករៀបចំនៅក្នុងការដ្ឋាននៅកន្លែង ហើយនិងសាក្សីមួយទៀត ថង ធឿយ ហើយគាត់ក៏ត្រូវបានគេបង្ខំឲ្យរៀបការដែលជាមួយនឹងប្ដីប្រពន្ធ៨៥គូផ្សេងទៀតនៅស្ពានស្រែង ហើយគេគំរាមកំហែងថានឹងសម្លាប់គាត់ បើគាត់មិនព្រមរៀបការ។ ហើយប្រធានកងរបស់គាត់បានប្រាប់គាត់ថា ត្រូវតាមដានគូស្រករថ្មីនោះដើម្បីឲ្យប្រាកដថាគេរួមដំណេកគ្នាដែរឬអត់ បើអត់ទេគេនឹងសម្លាប់ចោល។ ដូច្នេះ ចំពោះខ្ញុំអ្វីដែលជ្រើសរើសប្ដីប្រពន្ធឲ្យគួររៀបចំប្ដីប្រពន្ធនោះ គឺថាហើយឲ្យបង្កើតកូនទៀតនោះ គឺៗជាការបង្ហាញយ៉ាងច្បាស់ណាស់អំពីការដាក់ឲ្យទៅទាសករ គឺច្បាប់នោះបង្ហាញថា ការប្រើអំណាចទៅលើបុគ្គលដោយចាប់បុគ្គលនោះជាកម្មសិទ្ធិរបស់ខ្លួនថាឲ្យរៀបការជាមួយមនុស្សចម្លែក ដើម្បីឲ្យមានកូនជាមួយបុគ្គលដែលខ្លួនមិនស្គាល់នោះ។ នេះជាឧទាហរណ៍ច្បាស់អំពីការធ្វើឲ្យប្រជាជនក្លាយទៅជាទាសកររបស់ខ្មែរក្រហម។ ហើយសហចៅក្រមស៊ើបបានរកឃើញបែបនេះ គឺថា អ៊ឹម ចែម គាត់បានទទួលដំណឹងពីការចោទប្រកាន់បញ្ជាក់ពីរឿងនេះ គឺថា គឺមាន បទឧក្រិដ្ឋនេះកើតឡើងនៅក្នុងទីតាំងដែលគាត់បានធ្វើការ គាត់ទទួលខុសត្រូវ។ ប៉ុន្តែយើងមើលដីកាដំណោះស្រាយ គឺថាយើងធ្វើ *វ៉ិតស៊ើច* គឺថារកពាក្យ "ការរៀបការ" គឺថានៅដីកាដំណោះ

ឯកសារដើម

ស្រាយមិនមានចំណុចណាមួយដែលសហចៅក្រមស៊ើបអង្កេតបានពិចារណាលើអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ ប៉ុន្តែតាមពិត ដូចជា ថង ធឿយ ហើយនិងជនរងគ្រោះម្នាក់ទៀតនៃបទឧក្រិដ្ឋនេះ នេះជាកំហុសឆ្គងនៃអង្គច្បាប់ដែលយើងនិយាយថា ដែលអាចនឹងធ្វើឲ្យសម្រេចពួកគាត់គ្មានសុពលភាព។

[១៣:៤៤:៥៤]

តើដូចម្តេចអំពីតួនាទី តំណែងរបស់គាត់? សហចៅក្រមស៊ើបអង្កេតបានធ្វើកំហុសឆ្គងពីរទាក់ទងទៅនឹងមុខតំណែងរបស់គាត់ គឺថាសហសេវិករបស់ខ្ញុំ គឺនឹងនិយាយបន្ថែមទៀតអំពីបញ្ហានេះ ហើយភស្តុតាងបង្ហាញថា អ៊ឹម ចែម គឺមានតួនាទីជាលេខាស្រុកកោះអណ្តែត ហើយគាត់ជាសមាជិកនៃគណៈតំបន់១៣ ហើយបើយើងពិនិត្យមើល គឺថាបន្ទុកដ៏ធ្ងន់អំពីការបង្ហាញភស្តុតាងរបស់សហចៅក្រមស៊ើបអង្កេតហ្នឹង បង្ហាញថា គឺថាមិនមានចៅក្រម ឬក៏អ្នកវិនិច្ឆ័យអង្គហេតុណាអាចនឹងសម្រេចដូចពួកគាត់ទេ ផ្អែកលើភស្តុតាងដែលមាន។ យើងបានឃើញចម្លើយរបស់គាត់នៅក្នុងខ្សែអាត់សំឡេងដែលគាត់សម្ភាសឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា គាត់និយាយអំពីតួនាទីរបស់គាត់ ហើយគាត់បានថ្លែងបញ្ជាក់ថាគាត់យោងពីរដង គឺថាគាត់ៗជាលេខាស្រុកកោះអណ្តែត ហើយគាត់ជាសមាជិកគណៈស្រុក -- គណៈតំបន់១៣ដែរ គាត់ថា ហើយគាត់ត្រូវបានគេដាក់ជំនួសសមាជិកពីមុនរបស់គាត់។ ដូច្នេះ គឺថាវាគ្រប់គ្រាន់អាចនឹងបញ្ជូនករណីគាត់ទៅទៅជំនុំជម្រះ ដោយសារគាត់មានតំណែងខ្ពស់បែបនេះ។

[១៣:៤៦:៣១]

ដោយសារគាត់ជាអភិបាល ឬក៏លេខាស្រុកកោះអណ្តែត ហើយគាត់និយាយថា តាសាន គឺជាអនុរបស់គាត់ទេ។ ឥឡូវនេះយើងដឹងថា អំពីការស៊ើបអង្កេតទាំងអស់របស់តុលាការនេះគឺថាឋានានុក្រមខ្មែរក្រហម របៀបដែលគេដឹកនាំទូទាំងប្រទេស គណៈរបស់គេហ្នឹង គឺមានមនុស្សបីរូប។ មួយរូបជាលេខា ហើយពីររូបទៀត បើសិនជា បើគាត់ជាមានអនុហើយ គាត់ត្រូវតែជាលេខាហើយ គាត់ជាប្រធានហើយ។ ហើយ អ៊ឹម ចែម គាត់ប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា តាសាន ជាអនុរបស់គាត់។ ការយោងបកស្រាយឲ្យច្បាស់ទៅសម្តីនេះ គឺថាគាត់គឺជាលេខានៅក្នុងគណៈស្រុក ដែលនៅក្នុងនោះមានលេខា នៅក្រោម -- អនុលេខានៅក្រោមលេខានោះឯង។

ជាថ្មីម្តងទៀត គឺមុខតំណែងទាំងអស់នេះ គឺជាមានភាពពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចលើយុត្តាធិការបុគ្គលរបស់គាត់។ ហើយនៅក្នុងកថាខណ្ឌ៣៩ សហចៅក្រមស៊ើបអង្កេតបាននិយាយហើយគឺថាវាមានភាពពាក់ព័ន្ធដែលនាំឲ្យគាត់មានអំណាច ឬមិនមានអំណាចទៅលើការអនុវត្តគោលនយោ-

បាយនោះ។ ខ្ញុំនឹងអានកថាខណ្ឌ៣៩ ប៉ុន្តែខ្ញុំ -- ដូច្នេះ គឺថាតំណែងកាន់តែខ្ពស់នៅក្នុងឋានានុក្រម គឺ សហចៅក្រមស៊ើបអង្កេតត្រូវតែពិចារណា យើងយល់ស្របបញ្ហានេះ។ ដោយហេតុថា កាលណា តំណែងកាន់តែខ្ពស់ គឺថា គឺជាមានភវនីយភាព ដែលថាគាត់មានការទទួលខុសត្រូវដោយសារគាត់នឹង អនុវត្តនូវគោលនយោបាយនៃរបបនោះ។ ដូច្នេះ តើអ្វីជាដំណោះស្រាយ ជាឧបាស្រ័យសម្រាប់កំហុស ឆ្គងអង្គច្បាប់ និងកំហុសអង្គហេតុបែបនេះនោះ? នៅក្នុងរឿងក្ដី ហាឡាល្ងវេគ ជាសេចក្ដីសម្រេចរបស់ តុលាការ អាយ.ស៊ី.ធី.វាយ មានសេចក្ដីការសម្រេចជាច្រើន គឺជាសេចក្ដីសម្រេចលើបណ្ដឹងបន្ទាន់ ទាក់ទងទៅនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយជនជាប់ចោទ គឺថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៥ កថាខណ្ឌ៦៤ សាលាឧទ្ធរណ៍និយាយថា៖ "សាលាឧទ្ធរណ៍អាចជំនួសនូវការប្រើឆន្ទានុសិទ្ធិរបស់ខ្លួនទៅ ជំនួសរបស់សាលាដំបូង ប្រសិនបើខ្លួនគិតថាមានភាពចាំបាច់នឹងធ្វើបែបនោះ" ហើយក្នុងករណីធម្មតា ពាក់ព័ន្ធទៅនឹងភស្តុតាង គឺថាអាចនឹងបញ្ជូនបញ្ហាទៅតុលាការថ្នាក់ក្រោមវិញ ហើយអាចនឹងបញ្ជាក់ថា ឲ្យចាត់ការបន្តសាជាថ្មីឡើងវិញ ឬក៏យ៉ាងណា?

[១៣:៣៩:៤០]

អានេះនៅក្នុងរឿងក្ដី មីឡូស្វូវិច នៅថ្ងៃទី១៨ មេសា ឆ្នាំ២០០២ កថាខណ្ឌ៦ សាលាឧទ្ធរណ៍នៃ អង្គជំនុំជម្រះហ្នឹងនោះ បញ្ជាក់ថា ពេលដែលខ្លួនជឿជាក់លើកំហុសឆ្គងអំពីការប្រើឆន្ទានុសិទ្ធិរបស់ សាលាដំបូង គឺថាអាចនឹងខូចប្រយោជន៍ដល់ភាគីដែលតវ៉ាពីបញ្ហានេះ គឺថា ខ្លួនអាចនឹងដាក់ជំនួស សេចក្ដីសម្រេចឆន្ទានុសិទ្ធិរបស់ខ្លួនទៅតុលាការទៀតនោះបើចាំបាច់។ ករណីយុត្តិសាស្ត្រ គឺថានិយាយ អំពីដំណោះស្រាយ ឬក៏ឧបាស្រ័យពីរ គឺថាបើឃើញកំហុសឆ្គងអង្គច្បាប់ និងអង្គហេតុច្បាប់ហើយ គេ អាចប្រើឆន្ទានុសិទ្ធិជំនួសលើសេចក្ដីសម្រេចមុននោះ។ ហើយផ្អែកទៅលើមូលដ្ឋានដែលសេចក្ដីសម្រេច ចៅក្រមស៊ើបអង្កេតបានធ្វើនោះ គឺថាអង្គបុរេជំនុំជម្រះអាចនឹង អាចសម្រេចដោយខ្លួនឯងថា អ៊ឹម ចែម មានការទទួលខុសត្រូវ ជាជនទទួលខុសត្រូវ គឺថាអាចនឹងសម្រេចផ្អែកទៅលើ ពិនិត្យមើលកំហុសឆ្គង អង្គហេតុ និងអង្គច្បាប់ ឬក៏អាចបញ្ជូនត្រឡប់ទៅចៅក្រមនោះ ដើម្បីឲ្យពិនិត្យឡើងវិញ សាជាថ្មីឡើង វិញ។

[១៣:៥១:១២]

បាទមូលដ្ឋានទី១ នៃបណ្ដឹងឧទ្ធរណ៍របស់ខ្ញុំដែលយើងនិយាយនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់យើង គឺទាក់ទងថាតើនៅក្នុងដីកាដំណោះស្រាយនោះ សហចៅក្រមស៊ើបអង្កេត គប្បីពិនិត្យអង្គហេតុទាំង

អស់ដែលខ្លួនបានទទួល តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបឋម ឬក៏មិនបន្ថែម ឬក៏ខ្លួនអាចមិនអើពើបាន ហើយត្រូវតែចេញសេចក្ដីសម្រេចដែលមានសំអាងហេតុផង។ ហើយក្នុងករណីដែលខ្លួនមិនអាចចោទប្រកាន់ជនសង្ស័យដោយអង្គហេតុនោះ ត្រូវតែមានសំអាង។ ប៉ុន្តែនៅក្នុងប្រព័ន្ធកម្ពុជា យើងមានចៅក្រមស៊ើបអង្កេត ឬក៏ប្រព័ន្ធចៅក្រមស៊ើបសួរ វាខុសពីអាល្លឺម៉ង់ ខុសពីប្រព័ន្ធខំមិនឡូ នោះគឺថាយើងមានប្រព័ន្ធកម្ពុជា ដែលហាក់ដូចជាស្រដៀងទៅនឹងប្រទេសបារាំង ដែលយើងមានប្រព័ន្ធច្បាប់ស្រដៀងគ្នា។ នេះគឺជាគោលការណ៍ដែលមូលដ្ឋាន ដែលយើងមាននៅក្នុងកម្ពុជារបស់យើង គឺថានៅក្នុងប្រព័ន្ធចៅក្រមស៊ើបសួរ គឺចៅក្រមស៊ើបអង្កេត ទទួលនូវអង្គហេតុពីព្រះរាជអាជ្ញា ហើយខ្លួនមានកាតព្វកិច្ច ខ្លួនមិនមានឆន្ទានុសិទ្ធិដើម្បីទុកចោលទេ គឺខ្លួនមានកាតព្វកិច្ចនឹងស៊ើបអង្កេត ហើយនិងផ្ដល់សេចក្ដីសម្រេចដោយមានសំអាងហេតុ ហើយនិងបង្ហាញថាតើអង្គហេតុនោះបង្ហាញត្រឹមត្រូវ ដូចការចោទប្រកាន់ ឬចោទដែរឬអត់។ នៅក្នុងវិធាន៥៥ នៃវិធានផ្ទៃក្នុងចែងច្បាស់ថា ការស៊ើបអង្កេតនៅក្នុងសភាស៊ើបសួរ គឺជាករណីចាំបាច់ខានមិនបាន ហើយគឺមិនមានយុត្តិសាស្ត្រមកពីប្រទេសបារាំង ដែលយើងនិយាយពីសេចក្ដីសម្រេចរបស់តុលាការបារាំង ពីតុលាការវិនិច្ឆ័យគឺ *គួឌឺកាតាស្យុង* ហើយគឺយើងនឹងនិយាយ គឺទី១ ដែលយើងដាក់បញ្ចូល គឺរឿងក្ដីដែលឆ្នាំ១៩៦៩ គឺបណ្ដឹងសាទុក្ខលេខ 69/91612 គឺយើងមានកថាខណ្ឌ គឺថាដូចជានៅក្នុង -- ដូចៗគ្នានៅក្នុងសេចក្ដីសម្រេច គឺថារាប់ពីក្រោមទៅគឺ ទី៣ពីក្រោម។

[១៣:៥៣:៥៥]

ខ្ញុំនឹងនិយាយខ្លឹមសាររួមនៅក្នុងកថាខណ្ឌនោះមានន័យដូចម្ដេច មិនអានជាភាសាបារាំងជូនទេ ពិបាក។ និយាយថា “អង្គជំនុំសាលាឧទ្ធរណ៍ ឬក៏អង្គជំនុំជម្រះនៃការចោទប្រកាន់នោះ គឺបាននិយាយថា គឺថាតុលាការសាលាឧទ្ធរណ៍គឺ អាចនឹងបដិសេធចោលនូវសេចក្ដីសម្រេចដែលបានធ្វើ ក្នុងករណីដែលបើមិនបានសម្រេចទៅលើអង្គហេតុដែលភាគីដើមបណ្ដឹងរដ្ឋប្បវេណីបានជំទាស់។ ហើយបន្ទាប់មកបន្តទៅមាត្រាមួយទៀតនៃក្រមនីតិវិធីព្រហ្មទណ្ឌវិញគឺថា អាចនឹងត្រូវបញ្ជូនរឿងក្ដីនេះទៅចៅក្រមស៊ើបអង្កេតវិញ ឬក៏ប្រើមាត្រា២០១, ២០២ និង ២០៤ អាចនឹងធ្វើការស៊ើបអង្កេតដោយខ្លួនឯងនៅលើអង្គហេតុទាំងអស់នោះ។ នេះជាករណីតុលាការសាលាឧទ្ធរណ៍ដែលគេចែងនោះ គឺថាគប្បីតែបញ្ជូនទៅចៅក្រមស៊ើបអង្កេតវិញ កាលណាចៅក្រមអង្កេតនោះមិនបានអង្កេតពិចារណាទាំងអស់ដូចដែលដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើទេ។ ហើយនៅក្នុងចុងឆ្នាំ១៩៩៩ គឺតុលាការ គួឌឺកាតាស្យុង ហ្នឹងនិយាយគឺថា

ស្មើរតែដូចគ្នា គឺថាៗមានន័យដូរ ស្មើរតែដូចគ្នា ខ្ញុំមិនអានឡើងវិញទេ គឺសហចៅក្រម -- ចៅក្រមស៊ើបអង្កេតខកខានមិនបានអង្គហេតុ ដូចដែលដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើង ចោទឡើងទេ គឺជាកំហុសនៃអង្គច្បាប់ ហើយដំណោះស្រាយនោះគឺថាៗ ត្រូវអង្គជំនុំជម្រះសាលាឧទ្ធរណ៍គឺត្រូវបញ្ជូនទៅចៅក្រមស៊ើបអង្កេតដើម្បីឲ្យសម្រេចលើបញ្ហាអង្គហេតុនេះ ស៊ើបអង្កេតឡើងវិញ ឬក៏សាលាឧទ្ធរណ៍ខ្លួនឯងហ្នឹងគឺអាចនឹងបន្ត ផ្ទេរទៅឲ្យចៅក្រមណាមួយបន្តលើស៊ើបអង្គហេតុដែលមិនបានស៊ើបអង្កេតនោះ។ ហើយសេចក្ដីដកស្រង់មួយទៀត ក៏មានខ្លឹមសារដូចគ្នានោះដែរ នៅក្នុងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះនៅក្នុងរឿងក្ដី ខុច ប្រឆាំងនឹង ខុច ០០១នោះ បានបញ្ជាក់ថា សេចក្ដីសម្រេចដែលសន្និដ្ឋានលើកិច្ចស៊ើបសួរទាំងមូលគឺបានប្រកាសថា ដីកាដំណោះស្រាយនោះមានសេចក្ដីសន្និដ្ឋានអំពីអង្គហេតុ និងអង្គច្បាប់ដែលទាក់ទងទៅនឹងអំពី ហើយកម្មវត្ថុទាំងអស់ដែលត្រូវស៊ើបសួរ។

ដូច្នេះកាតព្វកិច្ចរបស់តុលាការកម្ពុជា ក៏ដូចជា អ.វ.ត.ក ដូចជាលោកប្រធានជ្រាបហើយ គឺថាសេចក្ដីសម្រេចមួយនេះ គឺថាត្រូវធ្វើឡើងដោយមានកំហុសឆ្គងដែលថា អ.វ.ត.ក ខ្លួនឯងតែងតែគេចោលភ្នែកមកពីតុលាការជាតិដើម្បីស្វែងរកការណែនាំថាតើតុលាការនេះសម្រេចដូចម្ដេចនៅក្នុងនីតិវិធី ហើយយើងក៏មិនចង់ឲ្យ អ.វ.ត.ក នេះបង្កើតជាករណីយុត្តិសាស្ត្រជាច្បាប់គំរូនៅក្នុងដីកាដំណោះស្រាយដែលថាចៅក្រមអង្កេតអាចទុកចោលអង្គហេតុមួយចំនួន ហើយធ្វើសេចក្ដីសម្រេចដោយមិនផ្ដល់ឱកាសឲ្យភាគីបានតវ៉ា ឬក៏បានដឹងពីមូលដ្ឋានដោយគ្មានសំអាងហេតុនោះឯង។

[១៣:៥៧:៤៩]

យើងគិតថា ការលើកលែងដែលបង្ហាញអំពីវិធាន ដែលថាវិធានតម្រូវឲ្យចៅក្រមមានកាតព្វកិច្ចដែលថាត្រូវគោរពទៅតាមដីកាបញ្ជូនរឿងឲ្យស៊ើបសួរបឋម និងបន្ថែមនោះ គឺថាមិនអាចទុកចោលទេ គឺថា គឺមានវិសោធនកម្មថ្មីៗ គឺថាវិធាន៦៦ស្ទួន។ វិធានគឺថានៅក្នុង ចែងគឺថា ជាលក្ខណៈពិសេសនៃតុលាការនេះ គឺសាលាក្ដីខ្មែរក្រហមយើងនិយាយអំពីបទឧក្រិដ្ឋដែលមានទំហំធំធេង ដែលយើងស៊ើបអង្កេតគ្រប់បទឧក្រិដ្ឋទាំងអស់ដែលខ្មែរក្រហមបានប្រព្រឹត្តនៅក្នុងករណីជាក់លាក់ណាមួយក៏ដោយ ដែលក្នុងដំណើរការនោះគឺថា បើសិនជាយើងត្រូវធ្វើទាំងអស់ យើងពិបាកនឹងបញ្ចប់អាណត្តិការងាររបស់យើង ប៉ុន្តែយើងកាត់បន្ថយ ប៉ុន្តែយើងមើលការការពារ ប៉ុន្តែយើងមានការពិភាក្សាដេញដោលខ្លាំងនៅកិច្ចប្រជុំពេញអង្គ ថាតើគោលការណ៍នៅក្នុងការស៊ើបអង្កេតដោយចៅក្រមស៊ើបថាតើ ត្រូវស៊ើបអង្កេតទាំងអស់ ឬក៏អាចនឹងទុកដោយឡែកហ្នឹងដូចម្ដេចនៅពេលដែលចប់ស៊ើបអង្កេតនោះ ប៉ុន្តែយើង

បានពិនិត្យមើលឃើញថា គឺថាអាចនឹងធ្វើឡើងបន្ទាប់ពីចៅក្រមស៊ើបអង្កេតបានជូនដំណឹងទៅភាគី ហើយបានស្ដាប់ភាគីទាំងអស់ទាក់ទងនឹងអង្គហេតុដែលមិនបានអង្កេតនោះ ហើយអាចនឹងកើតឡើងក្នុងករណីនោះ ហើយបើសិនបើមានជូនដំណឹង គឺភាគីអាចប្ដឹងឧទ្ធរណ៍នឹងសេចក្ដីសម្រេចនោះបាន។ នេះគឺជា *សេហ្វហ្គាត* គឺថាវិធានការការពារដែលយើងបានធ្វើ។ ដូច្នេះគឺថាចៅក្រមស៊ើបអង្កេតមិនបានធ្វើដូច្នោះទេ គឺថា បើសិនជាមិនបានជូនដំណឹងអំពីបទឧក្រិដ្ឋបន្ទាប់ពីខ្លួនបញ្ចប់កិច្ចស៊ើបសួរនោះ គឺថាហើយមិនបានឃើញថាមានពិចារណា ឬក៏បញ្ជាក់នៅក្នុងដីកាដំណោះស្រាយនោះទេ។ នេះគឺជាកំហុសមួយ លទ្ធផលចេញពីកំហុសនេះ គឺថា គឺមានន័យថា សហចៅក្រមស៊ើបអង្កេតមិនបានផ្ដល់ឱកាសឲ្យសហព្រះរាជអាជ្ញាបានស្ដាប់បានតទល់នោះទេ។ ភាគីផ្សេងទៀតក៏ដូចគ្នាដែរ អំពីអង្គហេតុណាដែលខ្លួនទម្លាក់ចោល អង្គហេតុណាដែលខ្លួនមិនយកមកវាយតម្លៃនោះបាទ។

[១៤:០០:២៥]

មេធាវីការពារក្ដីបានបញ្ជាក់ថា សហព្រះរាជអាជ្ញាគួរតែបានប្ដឹងឧទ្ធរណ៍ទៅលើសេចក្ដីជូនដំណឹងពីការចោទប្រកាន់នោះ ពីព្រោះថាអង្គហេតុទាំងនោះ មិនមានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបឋម ឬក៏បន្ថែមនោះទេ ប៉ុន្ដែនេះជាការពិត គឺថាមានការចោទប្រកាន់នោះ គឺថាមិនរាយលម្អិតទាំងអស់នោះគ្រប់អង្គហេតុនោះទេ ប៉ុន្ដែអាចនឹងបន្ថែមជាបន្ដបន្ទាប់នោះទៅតាមដែលករណី។ យើងមើលសេចក្ដីជូនដំណឹងនៅក្នុងករណីនេះ គឺថានៅក្នុងករណី ០០១, ០០២ គឺថាការជូនដំណឹងពីការចោទប្រកាន់នោះ គឺមិនមានសំអាងហេតុទេ។ មិនបានផ្អែកទៅលើភស្ដុតាង ហើយមិនបានបញ្ជាក់ពិភាក្សាថា ចោទប្រកាន់លើបទនេះ មិនចោទប្រកាន់លើបទនោះទេ។ ហើយអ៊ីចឹង គឺថាសេចក្ដីសម្រេចរបស់ចៅក្រម ហាមិនចោទប្រកាន់ អ៊ឹម ចែម កំបាំងមុខហ្នឹង អាហ្នឹងគឺមានសេចក្ដីសម្រេចនេះមែន ហើយយើងមានជាឧបសម្ព័ន្ធនៅក្នុងនេះ គឺយើងមានកម្មវត្ថុអំពីបណ្ដឹងសាទុក្ខ បណ្ដឹងឧទ្ធរណ៍របស់ អ៊ឹម ចែម នេះឯង។

[១៤:០១:៤៧]

ហើយមិន -- នៅក្នុងជូនដំណឹងក្រោយមកនេះ គឺថាមិនមានបញ្ជាក់ពីសំអាងហេតុ។ ហេតុអ្វីបានមិនចោទប្រកាន់លើអង្គហេតុនេះ អំពីការកាប់សម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យ គឺថាមិនបានយោងទៅរកភស្ដុតាង ហើយនៅក្នុងសេចក្ដីជូនដំណឹងរឿងក្ដី ០០១, ០០២ ក្ដី គឺមិនមែនជាសេចក្ដីសម្រេចដែលត្រូវប្ដឹងឧទ្ធរណ៍នោះទេ អ៊ីចឹងគឺថានេះជាករណីដែលសំខាន់បំផុត ដែលថាអាចនឹងចោទជាបញ្ហាឲ្យមានជាកំហុសអង្គច្បាប់នោះ។

ជំហររបស់មេធាវីការពារក្តីដែលថា ឧក្រិដ្ឋកម្មដែលមិនត្រូវបានចោទប្រកាន់ពាក់ព័ន្ធទៅនឹងអង្គហេតុដែលសហចៅក្រមស៊ើបអង្កេត ដែលបានទទួល គឺថាមិនរំលោភបំពានទៅលើគោលការណ៍ជាសារវន្តនោះទេ ប៉ុន្តែត្រូវតែផ្តល់ហេតុផល។ នៅក្នុងដីកាដំណោះស្រាយគ្រាន់តែលើកឡើងនូវមូលហេតុនៃសេចក្តីសម្រេចរបស់ខ្លួន។ នៅក្នុងសេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងសំណុំរឿង ០០១ គឺរឿងក្តី ឌុច អង្គបុរេជំនុំជម្រះបានលើកឡើងថា បាទ ខ្ញុំសូមរំឭកឡើងវិញ នេះគឺជាបទដ្ឋានអន្តរជាតិដែលថារាល់សេចក្តីសម្រេចរបស់ស្ថាប័នតុលាការទាំងអស់តម្រូវឲ្យមាន ត្រូវមានសំអាងហេតុ។

[១៤:០៣:២៤]

នៅក្នុងកថាខណ្ឌ៣៨ គឺថាសហចៅក្រមស៊ើបអង្កេតអាចច្រានចោលបទចោទ ឬក៏អាចនឹងបញ្ជូនរឿង បញ្ជូនជនត្រូវចោទនេះ គឺយកមកជំនុំជម្រះដោយអនុលោមទៅតាមវិធាន៦៧(៤)។ លោកលោកស្រីចៅក្រម ចំណុចមួយទៀតដែលខ្ញុំចង់លើកឡើង គឺថាមេធាវីការពារក្តី គឺថាមិនបាន ត្រូវបានធ្វើអន្តរាយដោយសារសហចៅក្រមស៊ើបអង្កេតនៅពេលដែលសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយក្រោយពីស្តាប់ពីភាគីទាំងអស់រួចមក គឺជាពិសេសក្រោយៗ និងពាក់ព័ន្ធទៅនឹងអង្គហេតុដែលសហចៅក្រមស៊ើបអង្កេតបានទទួល។ មានចំណុចមួយចំនួនដែលត្រូវចងចាំផងដែរ បំណែកនៃភស្តុតាងមួយ នេះគឺជាការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតទេ រហូតដល់ពេលដីកាដំណោះស្រាយត្រូវបានចេញនេះ គឺជា -- បាទ ហើយមេធាវីការពារក្តី គឺជាសិទ្ធិរបស់ខ្លួនក្នុងការពារក្តីរបស់ខ្លួន។

ឯកសារD283 ក្នុងកថាខណ្ឌ២ ដែលពាក់ព័ន្ធទៅនឹងសំណើរបស់មេធាវីការពារក្តីសុំឲ្យបង្ហាញនូវប្រតិចារឹកដែលមិនមានការកោសលុបនូវឈ្មោះសាក្សី ជាពិសេសអ្វីៗទាំងអស់ ឯកសារអ្វីៗទាំងអស់ដែលពាក់ព័ន្ធទៅនឹង អ៊ឹម ចែម នោះ ក្នុងកថាខណ្ឌ២។ ហើយក្នុងកថាខណ្ឌ៣ សំណើសុំនេះគឺថាចាំបាច់ណាស់ដើម្បីធានាទៅដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ អ៊ឹម ចែម ដើម្បីសម្របសម្រួលឲ្យបានគ្រប់គ្រាន់ដល់ការរៀបចំការពារខ្លួនរបស់គាត់ និងពិនិត្យមើលសាក្សីដែលសាក្សីដាក់បន្ទុកទាំងអស់។

បញ្ហានៅការដ្ឋានត្រពាំងថ្ម គឺថាមិនមែនតែជាទីកន្លែងតែមួយទេ ហើយ អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់ពីការដ្ឋានត្រពាំងថ្មនេះទេ។ តាមការពិតគាត់ត្រូវបាន គួរត្រូវបានចោទប្រកាន់អំពីការដ្ឋានត្រពាំងថ្មនេះដែរផងដែរ។ ប៉ុន្តែបែរមិនត្រូវបានចោទប្រកាន់ទៅវិញ។

ពីរខែក្រោយការបិទកិច្ចស៊ើបសួរទៅលើសំណុំរឿងនេះ អ៊ឹម ចែម បានដាក់សំណើសុំទៅសហចៅក្រមស៊ើបអង្កេត សុំឲ្យធ្វើមោឃភាពទៅលើកិច្ចសម្ភាសន៍ពាក់ព័ន្ធទៅនឹងការដ្ឋានត្រពាំងថ្ម ក៏ដូចជាវត្តចំការខ្នុរ មន្ទីរសន្តិសុខវត្តចំការខ្នុរ។ នេះគឺឯកសារ D298.4។ អ៊ឹម ចែម បានជំទាស់តវ៉ាថា កិច្ចសម្ភាសន៍ទាំងអស់នេះគួរត្រូវចាត់ទុកជាមោឃៈ ហើយដកចេញពីសំណុំរឿងទៅ។ គាត់បាននិយាយថា ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា គួរតែលើកយកមកនិយាយផ្នែកណាមួយដែលបានធ្វើមោឃភាពនោះហើយ ឬចាត់ទុកជាមោឃៈ។ ដូច្នេះ អ៊ឹម ចែម រំពឹងថាសហព្រះរាជអាជ្ញាគឺថាមិនចោទប្រកាន់ទៅលើការទីតាំងឧក្រិដ្ឋកម្មទាំងអស់នេះទេ ដោយសារតែគាត់យល់ឃើញថាគាត់អាចនឹងត្រូវបានចោទប្រកាន់ ហើយជាពិសេសមេធាវីការពារក្ដីផ្ដោតការយកចិត្តទុកដាក់ទៅលើការបទចោទសំខាន់ៗទាំងនេះ។

[១៤:០៧:៣៤]

លោក លោកស្រីចៅក្រម ឧទាហរណ៍ដែលល្អបំផុតនោះគឺថា ជនសង្ស័យ ជនត្រូវ ឬក៏ជនត្រូវចោទ អាចត្រូវបានចោទប្រកាន់ឡើងវិញ នេះគឺជាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះបុរេជំនុំជម្រះនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ ឌុច នៅក្នុងកថាខណ្ឌ១០៦ អង្គបុរេជំនុំជម្រះគឺថាបានលើកឡើងអំពីបទល្មើសដែលមិនត្រូវបានចោទប្រកាន់ គឺពាក់ព័ន្ធទៅនឹងច្បាប់ជាតិ ការធ្វើមនុស្សឃាត ហើយនិងអំពើទារុណកម្ម។ ទោះបីជា ឌុច មិនត្រូវបានចោទប្រកាន់នឹងបទល្មើសទាំងនេះក៏ដោយ ក៏ប៉ុន្តែអង្គបុរេជំនុំជម្រះបានវិភាគថា បទល្មើសជាតិគឺថា វាញែកចេញដាច់ពីគ្នារវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយក៏ត្រូវបានសហចៅក្រមស៊ើបអង្កេតយកមកចោទប្រកាន់។ ហើយអង្គបុរេជម្រះនៅពេលនោះ ក៏បានសម្រេចធ្វើការកែប្រែដីកាចោទប្រកាន់ ដោយរាប់បញ្ចូលនូវបទល្មើសទាំងអស់នេះផងដែរ បើទោះបីជាការស៊ើបអង្កេតនោះមិនបានស៊ើបអង្កេតទៅលើបទល្មើសមនុស្សឃាត ហើយនិងការធ្វើទារុណកម្មនេះក៏ដោយ។ ប៉ុន្តែនៅក្នុងកថាខណ្ឌ១០៦ វិធានផ្ទៃក្នុងគឺថាប្រមើលមើលអំពីលទ្ធភាពដែលថាចរិតលក្ខណៈនៃផ្លូវច្បាប់នៃអំពើឧក្រិដ្ឋនោះ គឺថាវាកែប្រែនៅក្នុងអំឡុងសវនាការ ជាពិសេសនៅក្នុងកិច្ចដំណើរការបែបនេះគឺថាវាមិនប៉ះពាល់ទៅដល់សិទ្ធិរបស់ជនត្រូវចោទទេ នៅក្នុងមាត្រា៣៥នៃក្រមនីតិវិធីព្រហ្មទណ្ឌនៅកម្ពុជា ដោយសារថា គាត់មានឱកាសដើម្បីការពារខ្លួនចំពោះបទល្មើសជាក់លាក់ដែលចោទជាថ្មីទាំងនេះនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។

[១៤:០៩:៤៨]

នៅទីនេះ យើងនិយាយគ្នាតែពីដីកាដំណោះស្រាយទេ យើង -- *អ៊ីនដាយមិន* គឺដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះគឺវាពាក់ព័ន្ធទៅនឹងការ មេធាវីនេះ គឺត្រូវតែរៀបចំខ្លួនដើម្បីការពារកូនក្តីរបស់ខ្លួន។ នៅពេលអ្នកណាម្នាក់ត្រូវបានចោទប្រកាន់ អ៊ីចឹងគឺថាគេត្រូវតែតែចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី គេមានសិទ្ធិទទួលបានការជូនដំណឹងអំពីការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ បាទ ដើម្បីចាប់ផ្តើមកិច្ចដំណើរការនីតិវិធីនៅពេលដែលជនជាប់ចោទមានលទ្ធភាពចូលមកសំណុំរឿងបាន ដូចជាករណីអ៊ឹម ចែម ត្រូវបានចោទពេលនេះគឺថា គាត់បានដឹងអំពីដីកាបញ្ជូនរឿងឲ្យស៊ើបសួរបឋម ក៏ដូចជាដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ អ៊ីចឹងចំណុចត្រង់នេះ គឺថាមិនមានការរំលោភសិទ្ធិរបស់ជនជាប់ចោទត្រង់ចំណុចណាមួយនោះទេ។ ដូច្នេះជំហររបស់យើងខ្ញុំគឺថាសហចៅក្រមស៊ើបអង្កេតមិនបានពិចារណាទៅលើឧក្រិដ្ឋកម្មដែលមិនត្រូវបានយកមកចោទប្រកាន់ចំពោះ អ៊ឹម ចែម។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតក៏គួរយកមកសរសេរនៅក្នុងដីកាដំណោះស្រាយដែរ ថាហេតុអីបានជាបទល្មើសទាំងអស់នេះមិនត្រូវបានយកមកចោទប្រកាន់យ៉ាងដូច្នេះ។ អ៊ីចឹងនៅក្នុងដីកាដំណោះស្រាយគាត់អាចសរសេរអ៊ីចឹង។

ខ្ញុំយល់ឃើញថា ចំណុចនេះអនុវត្តទាំងតុលាការអន្តរជាតិ ក៏ដូចនៅក្នុងតុលាការជាតិ ក៏ប៉ុន្តែសហចៅក្រមស៊ើបអង្កេតហាក់បីដូចជាធ្វើមិនដឹងមិនឮចំពោះបទល្មើសទាំងនេះនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររបស់ខ្លួន។ ចំណុចនេះគឺថាវាប៉ះពាល់ទៅដល់យុត្តាធិការបុគ្គលហើយ ហើយយើងក៏និយាយគ្នាអំពីភាពធ្ងន់ធ្ងរនៃអំពើឧក្រិដ្ឋ ក៏ដូចជាការប៉ះពាល់ពីអំពើឧក្រិដ្ឋទាំងអស់នេះទៅលើជនរងគ្រោះ។

សូមអរគុណច្រើនលោកចៅក្រម ខ្ញុំសុំប្រគល់តួនាទីនេះ ទៅឲ្យសហការីរបស់ខ្ញុំ ហើយបើមានសំណួរអី គឺថា ខ្ញុំត្រៀមនឹងឆ្លើយ។

[១៤:១២:៣៨]

**លោក កូមេន ខេននី៖**

ជម្រាបសួរលោកប្រធាន លោកចៅក្រម ក៏ដូចជាអស់លោក លោកស្រីទាំងអស់ ខ្ញុំនឹងលើកឡើងអ្វីដែលនៅសេសសល់ពីការលើករបស់សហព្រះរាជអាជ្ញាអន្តរជាតិ និយាយអំពីកំហុសអង្គច្បាប់ និងអង្គហេតុនៅក្នុងមូលដ្ឋាន នៅក្នុងសំអាងហេតុទី២ និងទី៦ ពាក់ព័ន្ធទៅនឹងការខកខានរបស់ ក.ស.ច .ស ដើម្បីដោះស្រាយការចោទប្រកាន់មួយចំនួននៅក្នុងដីកាសន្និដ្ឋានឲ្យស៊ើបសួរបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ក្នុងនេះរួមទាំងការចោទបន្ថែម ចោទប្រកាន់ទៅលើការទទួលខុសត្រូវរបស់ អ៊ឹម ចែម ការបោសសម្អាតនៅភូមិភាគពាយ័ព្យ ការរៀបការដោយបង្ខំ ហើយនិងការកំណត់

គោលដៅជាក់លាក់ ក៏ដូចជាការធ្វើទុក្ខបុកម្នេញទៅលើជនជាតិភាគតិច និងឧក្រិដ្ឋកម្មដទៃទៀតនៅការដ្ឋានមួយចំនួន។ ឥឡូវខ្ញុំសូមលើកឡើងនិយាយអំពីការបោសសម្អាត និងការរៀបការដោយបង្ខំ។ ចំណុចពីរនេះគឺថាមាននៅក្នុងសារណាជាលាយលក្ខណ៍អក្សររបស់យើង ហើយយើងខ្ញុំក៏លើកឡើងភស្តុតាងលម្អិតដែលគាំទ្រទៅដល់ការចោទប្រកាន់ទៅលើ អ៊ឹម ចែម នោះក៏អាចរកឃើញនៅក្នុងសារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិផងដែរ។ ទី១ ក.ស.ច.ស មិនបានពិចារណាការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះលទ្ធផលនៃការបោសសម្អាតនៅភូមិភាគពាយ័ព្យដែលឈានដល់ការធ្វើសេចក្តីសម្រេចរបស់ខ្លួនថាតើគាត់ស្ថិតនៅក្នុងអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែរឬក៏យ៉ាងណា។ ដីកាដំណោះស្រាយវាមានបង្ហាញនូវការយល់ឃើញមួយចំនួនទាក់ទងទៅនឹងការបោសសម្អាត ហើយនិងនិយាយពាក់ព័ន្ធពិចារណាទៅដល់ការបោសសម្អាតជាលម្អិតនៅពេលដែលបញ្ជូន អ៊ឹម ចែម ពីភូមិភាគនិរតីទៅកាន់ភូមិភាគពាយ័ព្យ។ ក.ស.ច.ស ខកខានមិនបានផ្តល់ទម្ងន់ ហើយក៏មិនបានពិចារណាទៅលើចំណុចសំខាន់ៗនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ជាពិសេសពាក់ព័ន្ធទៅនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនេះ យើងមិនបានប៉ាន់ប្រមាណពីចំនួនប្រជាជនដែរបានសម្លាប់ ហើយដូចជាឧទាហរណ៍ ការប្រើប្រាស់ទារុណកម្មប្រឆាំងមកលើជនរងគ្រោះដោយការបោសសម្អាតនោះក៏មិនបានលើកឡើងយកមកនិយាយផងដែរ។ អ៊ឹម ចែម ទទួលស្គាល់នៅក្នុងកថាខណ្ឌ៥៥នៃចម្លើយតបរបស់គាត់ថា ដីកាដំណោះស្រាយហ្នឹង គឺគាត់បានដឹកនាំកម្មាភិបាលពីភូមិភាគពាយ័ព្យហ្នឹងទៅកាន់ -- ពីនិរតីទៅកាន់ភូមិភាគពាយ័ព្យ។ អ៊ឹម ចែម អះអាងនៅក្នុងកថាខណ្ឌ៥៦ថា "ក.ស.ច.ស បានអះអាងនូវការអះអាងរបស់គាត់ ហើយថាគាត់ដើរតួនាទីយ៉ាងសំខាន់នៅទីនោះ"។ ប៉ុន្តែនៅក្នុងដីកាដំណោះស្រាយសហចៅក្រមស៊ើបអង្កេតមិនបានពិចារណាឧក្រិដ្ឋកម្ម ដែលបណ្តាលមកពីសកម្មភាពរបស់ អ៊ឹម ចែម ហើយនិងកម្មាភិបាលមកពីភូមិភាគនិរតី ដែលគាត់ដឹកនាំទៅទីនោះដែរ។ ការគ្រាន់តែបញ្ជូនប្រជាជនពីភូមិភាគមួយទៅភូមិភាគមួយ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា នៅក្នុងកថាខណ្ឌ១៥៦ នៃដីកាដំណោះស្រាយ អ៊ឹម ចែម បានដឹកនាំក្រុមគ្រួសារ៥០០ ទៅប្រាំមួយគ្រួសារ ហើយនិងទាហាន៣០០ ទៅ៥០០នាក់ពីតាកែវ ទៅកាន់ភូមិភាគពាយ័ព្យ ដោយឈប់នៅភ្នំពេញ ដឹកនាំកម្មាភិបាលទាំងអស់នេះ ដើម្បីទៅជួប ប៉ុល ពត។ អ៊ឹម ចែម នេះគឺក៏បានធ្វើការកិច្ចការសម្ភាសន៍ ហើយលើកឡើងអំពីទំនាក់ទំនងរបស់គាត់ជាមួយ ប៉ុល ពត ដោយលើកថា ប៉ុល ពត បានឲ្យគាត់ទៅជួបផ្ទាល់នៅពេលដែលគាត់មកឈប់សម្រាកនៅភ្នំពេញ។

[១៤:១៦:៣១]

អ៊ីចឹងការលើកឡើងនេះ ដូចជាការអះអាងរបស់ អ៊ឹម ចែម ថា ប៉ុល ពត បានការពារគាត់ហ្នឹង មិនឲ្យគេចាប់ខ្លួនទេ។ ក្រៅពីការអះអាងរបស់ អ៊ឹម ចែម នៅក្នុងចម្លើយតបរបស់គាត់នៅក្នុងកថាខណ្ឌ ៥ និងកថាខណ្ឌ៨៩ គឺថាអ្នកកម្មាភិបាលជាង១០០នាក់ គឺមានឋានៈប្រហាក់ប្រហែលនឹងគ្នាហ្នឹង បាន អះអាងនៅក្នុងចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពរ ដែលនៅទីនោះ គឺថាគាត់កាន់មុខតួនាទី ជាច្រើនមួយចំនួន។ ដីការដំណោះស្រាយហ្នឹង គឺបានបង្ហាញអំពីលទ្ធផលនៃការឡើងកាន់កាប់អំណាច នេះ ក.ស.ច.ស បានរកឃើញនៅក្នុងកថាខណ្ឌ១៥៣ ថាក្រោយពី អ៊ឹម ចែម និងកម្មាភិបាលភូមិភាគ និរតីទៅដល់ថា ទាហាន និងជនស៊ីវិលភូមិពាយ័ព្យត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខនៅ ទូទាំងភូមិភាគពាយ័ព្យតែម្តង និងក៏ដូចជាឃុំខ្លួននៅមន្ទីរសន្តិសុខស-២១ ហើយត្រូវបានចាត់តាំងឲ្យទៅ ធ្វើការនៅតាមការដ្ឋាននានា ក៏ដូចជា ដើម្បីធ្វើការអប់រំកែប្រែ។ ដីកាដំណោះស្រាយបន្តដល់កថាខណ្ឌ ១៨៥ ថា អ៊ឹម ចែម និងកម្មាភិបាលភូមិភាគនិរតីបានត្រួតត្រាទៅលើតំបន់១៥ គឺត្រួតត្រានៅលើសហ-ករណ៍ស្រុក ឃុំ ក៏ដូចជានៅកម្រិតតំបន់ដែរ។

[១៤:១៨:០០]

យើងបានដឹងនូវអ្វីដែលកើតឡើងទៅដល់កម្មាភិបាលដែលត្រូវបានចាប់ខ្លួន នេះដោយសារតែ ឯកសារដែលនៅសេសសល់ពីស-២១។ សហការីបាន ខ្ញុំបានបញ្ជាក់ហើយកម្មាភិបាលភូមិភាគពាយ័ព្យ ដែលបញ្ជូនទៅស-២១ គឺប្រហែលជា១០០០នាក់ ដែលភាគច្រើននៃអ្នកទាំងនេះ គឺថាបាន ត្រូវបានកត់ត្រាថា បានចូលមកស-២១ នៅចន្លោះពីខែមិថុនា ៧៧ ដល់ខែឧសភា ៧៨ ដែលជាអំឡុងពេល អ៊ឹម ចែម នេះដឹកនាំការបោសសម្អាតនៅក្នុងភូមិភាគមួយនេះ។ ញ៉ែម អេន ដែលជាអ្នកថតរូបនៅស-២១ ត្រូវបាន ក.ស.ច.ស សួរថា ហើយគាត់ក៏បានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរថា អ៊ឹម ចែម នេះ បានសម្លាប់មនុស្សរាប់ពាន់នាក់នៅក្នុងខេត្តបាត់ដំបង។ គាត់បានជម្រាបទៅសហចៅក្រមស៊ើបអង្កេត គឺឯកសារ D119/124 ត្រង់ចម្លើយ៣៦ សុំដកស្រង់៖ “ខ្ញុំនិយាយហ្នឹង ដោយសារយាយចែម នេះគឺជា មេដឹកនាំនៅកន្លែងនោះ ហើយប្រជាជនជាច្រើនបានស្លាប់នៅកន្លែងដែលគាត់គ្រប់គ្រង។ នៅស-២១ ខ្ញុំ បានដឹងថា ប្រជាជនជាច្រើនគេបានបញ្ជូនមកពីតំបន់៥ នៅពេលនោះ គឺថាមានការចាប់ខ្លួនកាន់តែច្រើន ឡើងៗ នៅភូមិភាគពាយព្យក៏ដូចគ្នាភូមិភាគបូព៌ា ក៏ដូចជាភូមិភាគដទៃទៀត ដែលកម្មាភិបាលពីភូមិភាគ និរតីហ្នឹង គឺបានទៅជំនួសកម្មាភិបាលនៅភូមិភាគទាំងនោះ។

[១៤:១៩:៣១]

យើងក៏ដឹងពីកំណត់ត្រានៅស-២១ ជាពិសេសនូវអ្វីដែលកើតឡើងមានឡើងទៅដល់បុគ្គលទាំងឡាយដែល អ៊ឹម ចែម បានទៅជំនួសនៅថ្នាក់ស្រុក និងថ្នាក់តំបន់។ នៅថ្នាក់ស្រុកដូចសហចៅក្រមស៊ើបអង្កេតបានរកឃើញក្នុងកថាខណ្ឌ១៥៨នៃដីកាដំណោះស្រាយ។ តាម៉ោង ដែលជាមកពីស្រុកព្រះនេត្រព្រះលេខាស្រុកព្រះនេត្រព្រះត្រូវបានចាប់ខ្លួនបញ្ជូនមកស-២១ ក្រោយពីយាយចែម ទៅដល់។ ហើយនៅក្នុងបញ្ជីនេះ យើងមានចម្លើយសារភាពរបស់ តាម៉ោង។ ហើយនៅក្នុងន័យនេះ សហចៅក្រមស៊ើបអង្កេតបានយោងទៅកថាខណ្ឌ១១០ នៃដីកាដំណោះស្រាយរបស់ខ្លួន ដោយសំអាងថា តាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២ គឺឯកសារ 26/12 គឺសេចក្តីសម្រេចស្តីអំពីការជំទាស់ទៅលើបញ្ជីឯកសារ។ នេះបញ្ជាក់ថា តាម៉ោង ត្រូវបានសម្លាប់នៅក្នុងខែតុលា ឆ្នាំ១៩៧៧ ដែលគាត់រងការឈឺចាប់នោះប្រហែលជា៤ខែនៅស-២១។

[១៤:២០:៤៦]

សហចៅក្រមស៊ើបអង្កេតមិនបានយោងទៅឈ្មោះ សោម អាត ដែលជាលេខាស្រុកព្រះនេត្រព្រះទេ ប៉ុន្តែឯកសារដែលសេសសល់ គឺ សោម អាត ក៏ត្រូវបានបញ្ជូនទៅ ស-២១ ក្រោយពី អ៊ឹម ចែម ទៅដល់។ ហើយរបាយការណ៍សួរចម្លើយនៅស-២១ នេះ សោម អាត ថ្ងៃទី០១ សីហា ឆ្នាំ១៩៧៧ សុំដកស្រង់៖ "ការធ្វើទារុណកម្មនេះគឺថាសាហាវព្រៃផ្សៃណាស់ ហើយធ្វើទារុណកម្មអស់រយៈពេលជាច្រើនអាទិត្យ" ហើយប៉ុន្តែគាត់ទ្រាំហើយមិនឆ្លើយអ្វីទេ មិនឆ្លើយអ្វីទាល់តែសោះអស់ជាច្រើនសប្តាហ៍។ នៅថ្នាក់តំបន់ សហចៅក្រមស៊ើបអង្កេតបានរកឃើញនៅក្នុងកថាខណ្ឌ១៦២ ពាក់ព័ន្ធទៅ -- ដែលបង្ហាញភស្តុតាងថា សមាជិកតំបន់៥ គឺតាហឿង ឬ តាហង្ស ត្រូវបានចាប់ខ្លួនដោយ អ៊ឹម ចែម និងតាម៉ុក។ តាហឿង មានកត់ត្រានៅស-២១ ហើយគាត់បានចូលទៅដល់ស-២១ នៅថ្ងៃទី២២ មិថុនា ១៩៧៧។ សូមកែតម្រូវ តាហ៊ឹង្ស។

[១៤:២២:០៨]

នៅក្នុងកថាខណ្ឌ១៦៣ នៃដីកាដំណោះស្រាយ គឺថា អ៊ឹម ចែម ក្រោយមកក្លាយទៅជាអនុលេខាតំបន់៥។ តាមរយៈកំណត់ត្រាពីស-២១ គឺថា តារិន នេះក៏ត្រូវបានផ្តល់ចម្លើយសារភាព ហើយត្រូវបានគេសម្លាប់ចោលនៅស-២១ដែរ។ ភស្តុតាងបានបង្ហាញថា កម្មាភិបាលភូមិភាគពាយ័ព្យដទៃទៀតនេះបានចាប់ខ្លួន បានបាត់ខ្លួន ឬក៏ត្រូវបានសម្លាប់នៅក្នុងទឹកដីភូមិភាគពាយ័ព្យនោះតែម្តង។ ឧទាហរណ៍

ភុំ ឃោ ដែលជាសមាជិកក្នុងគណៈស្រុកព្រះនេត្រព្រះ ហើយបានជម្រាបជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារ D219/23 ត្រង់ចម្លើយ៤៧ និង៥២ដល់៥៣ និយាយអំពីការចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យ នៅថ្នាក់ភូមិភាគ ថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំ ដោយចោទពួកគាត់ពីអំពើ ពួកអ្នកទាំងនោះពីអំពើក្បត់ជាតិ ហើយនាំខ្លួនយកចេញទៅបាត់ទៅ។

អ៊ីវ ម៉ាវ៉ា ដែលធ្វើការនៅក្នុងកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ គឺបានជម្រាបជូន ក.ស.ច.ស ឯកសារ D119/154 ចម្លើយ៣០ គឺថាកម្មាភិបាលភូមិភាគពាយ័ព្យដែលរស់នៅក្នុងភូមិ និងដែលធ្វើជាប្រធានភូមិ ប្រធានឃុំហ្នឹង ត្រូវបានចាប់ខ្លួនយកទៅសម្លាប់ចោល ដោយពួកកម្មាភិបាលមកពីភូមិភាគនិរតី។ ឡូត សួយ ដែលជាអ្នកធ្វើការនៅក្នុងកងចល័តនៅការដ្ឋានទំនាំងថ្កុក គឺឯកសារ D119/144 ចម្លើយ៣៧ សុំដកស្រង់៖ “អ្នកទាំងអស់នោះត្រូវបានកម្មាភិបាលភូមិភាគនិរតីចាប់ខ្លួនយកទៅសម្លាប់ចោល ក្រោយមកប្រពន្ធនិងកូនរបស់ពួកគាត់ហ្នឹង ក៏ត្រូវបានប្រមូលយកទៅសម្លាប់ចោលដែរ”។

[១៤:២៤:១៧]

លោក លោកស្រីចៅក្រម សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាអំពីភាពធ្ងន់ធ្ងរនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួនទេ។ អ៊ឹម ចែម បានការពារការខកខានរបស់សហចៅក្រមស៊ើបអង្កេតដើម្បីគេចចេញពីការទទួលខុសត្រូវរបស់គាត់។ ហើយជាពិសេសដោយជំទាស់នៅក្នុងកថាខណ្ឌ៥៦ ថាចំណុចលម្អិតនៃឧក្រិដ្ឋកម្មដែលវាផ្ទុយទៅនឹងចរិតលក្ខខណ្ឌសំខាន់ៗ គឺមិនស៊ីចង្វាក់គ្នា ហើយមិនស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការនេះទេ។ អ៊ឹម ចែម មិនបានពន្យល់ថាហេតុអីបានគាត់យល់ថាការចាប់ខ្លួន ការឃុំដោយខុសច្បាប់ ការបាត់ខ្លួនដោយបង្ខំ ការប្រព្រឹត្តដោយអមនុស្សធម៌ ការធ្វើទារុណកម្ម ការសម្លាប់ក្រៅផ្លូវច្បាប់។ នេះគឺ គ្រាន់តែជាភាពលម្អិត ពាក់ព័ន្ធទៅនឹង ត្រួសៗទៅនឹងការទទួលខុសត្រូវរបស់គាត់។ អ៊ឹម ចែម ជំទាស់តវ៉ាថា បើសិនជាអ្នកទទួលស្គាល់ថាការចូលរួមរបស់បុគ្គលណាម្នាក់នៅក្នុងសកម្មភាពឧក្រិដ្ឋ អ្នកមិនត្រូវចូលរួមចំណែកនៅក្នុងលទ្ធផលនៃឧក្រិដ្ឋកម្មចំពោះអ្នកទាំងនោះទេ។ ហើយវាក៏ ជាពិសេសគឺចំណុចពាក់ព័ន្ធទៅនឹងតួនាទី ហើយនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម។

សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា អ៊ឹម ចែម បានចូលរួមនៅក្នុងការបោសសម្អាតប៉ុន្មានលើកដែរ ជាមួយនឹងការខកខានពិចារណាចំពោះ លទ្ធផលឧក្រិដ្ឋនៅពេលដែលវាយតម្លៃទៅលើការទទួលខុសត្រូវរបស់ អ៊ឹម ចែម ក៏ដូចជាគោលបំណងនៃយុត្តាធិការបុគ្គល បើសិនណាយើងពិនិត្យទៅកំហុសនេះតែមួយភ្លែតយើងនឹងឃើញហើយ។

[១៤:២៦:០៦]

បាទ ចំណុចមួយទៀត គឺសហចៅក្រមស៊ើបអង្កេតបានទទួលអង្គហេតុនេះហើយ ប៉ុន្តែមិនបានយកមកសម្រេចនៅក្នុងដីកាដំណោះស្រាយទេ គឺការរៀបការដោយបង្ខំនេះឯង។ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាបាននិយាយអំពីការរៀបការដោយបង្ខំ ប៉ុន្តែដីកាដំណោះស្រាយមិនបាននិយាយចំណុចណាតែមួយម៉ាត់ទាល់តែសោះពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ។ អ៊ឹម ចែម បានលើកឡើងនៅក្នុងកថាខណ្ឌ៦១ នៃចម្លើយតបរបស់គាត់ ខ្ញុំសុំដកស្រង់៖ "ក.ស.ច.ស គឺថាមានឆន្ទានុសិទ្ធិត្រឹមត្រូវដែលត្រូវផ្តល់ការគាំទ្រ ឬមិនផ្តល់តម្លៃភស្តុតាងអ្វីទាល់តែសោះទៅនឹងភស្តុតាងដែលទម្លាក់កំហុសមកលើ អ៊ឹម ចែម ចំពោះការរៀបការដោយបង្ខំនេះ" បញ្ចប់ការដកស្រង់។ ប៉ុន្តែ ក.ស.ច.ស នេះមិនបានធ្វើការសម្រេចទៅលើចំណុចនេះ។ អ៊ឹម ចែម បង្កើតការយល់ឃើញនេះដើម្បីជៀសវាងចំណុចស្នូលនេះដែលនៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា។ ដោយសារតែការខកខានទាំងអស់នេះ ការបកស្រាយដែលអាចធ្វើទៅបាននេះ គឺថាសហចៅក្រមស៊ើបអង្កេតមិនបានយកភស្តុតាងនេះយកមកពិចារណានៅក្នុងយុត្តាធិការរបស់ខ្លួននោះទេ។ ជាពិសេសនៅក្នុងសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងយុត្តាធិការបុគ្គល សាក្សីមួយចំនួនហ្នឹងគឺបានមកផ្តល់រឿងរ៉ាវយ៉ាងច្បាស់ក្រឡែតពាក់ព័ន្ធទៅនឹងការចូលរួមពាក់ព័ន្ធរបស់ អ៊ឹម ចែម នៅក្នុងការរៀបការដោយបង្ខំ។

ថង ធឿយ គឺឯកសារ D119/131 ត្រង់ចម្លើយ៥៦ សុំដកស្រង់៖ "គេបង្ខំខ្ញុំឲ្យរៀបការជាមួយប្តីរបស់ខ្ញុំ ខ្ញុំអត់ធ្លាប់ដែលបានស្គាល់គាត់ទេពីមុន។ មានគូស្រករ៨៥គូ រៀបការនៅក្នុងឆ្នាំ១៩៧៧"។ នៅចម្លើយ៧០នោះ គឺកិច្ចសម្ភាសន៍ជាមួយនឹង ថង ធឿយ ដដែល សុំដកស្រង់៖ "យាយចែម នេះគាត់បានទៅត្រួតពិនិត្យមើលពិធីរៀបការទាំងមូលនេះតែម្តង"បញ្ចប់ការដកស្រង់។ ថង ធឿយ បានប្រាប់ទៅ សហចៅក្រមស៊ើបអង្កេតនៅចម្លើយ៧៣ថា គាត់ត្រូវបានគេគំរាមកំហែងថាយកទៅសម្លាប់ចោលបើបដិសេធមិនព្រមរៀបការ។ ហើយគាត់ក៏បានលើកឡើងនៅក្នុងចម្លើយ៧៧, ៨០ និង ៨១ ថា មេកងរបស់គាត់បានប្រាប់គាត់ថា អ៊ឹម ចែម បានបញ្ជាឲ្យរៀបការប្តីប្រពន្ធ ហើយនិងឲ្យតាមដានដើម្បីធានាថាក្រោយពីរៀបការរួចហ្នឹងគូស្រករហ្នឹង គឺមានការរួមសង្វាសជាមួយនឹងគ្នា បើមិនអ៊ីចឹងទេខ្ញុំយកទៅសម្លាប់ចោលហើយ។ សុំដកស្រង់ គឺថា៖ "មានស្ត្រីពីរបីនាក់ត្រូវបានឈ្លបយកទៅសម្លាប់ចោលដោយសារតែពួកគេមិនបានរួមដំណេកជាមួយគ្នា" បញ្ចប់ការដកស្រង់។

[១៤:២៩:២៩]

ពាក់ព័ន្ធទៅនឹងភស្តុតាងលើជនរងគ្រោះដោយការរៀបការដោយបង្ខំ ដូចជា ថង ធឿយនេះ គឺ ដែលបានលើកឡើងនៅក្នុងនៅក្នុងកថាខណ្ឌ៦០ គឺថា មិនមានតុលាការប្រកបដោយហេតុផលណាមួយ អាចសំអាងទៅលើអង្គហេតុនេះបានទេ។ សហចៅក្រមស៊ើបអង្កេតបានយោងនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួនចំនួនប្រាំដងនៅក្នុងការយល់ឃើញពាក់ព័ន្ធទៅនឹងការដ្ឋានត្រពាំងថ្ម ដែលថាល្អបស្ថិតនៅក្រោមការត្រួតត្រារបស់ អ៊ឹម ចែម ហើយ អ៊ឹម ចែម ជាអ្នកបញ្ជាឲ្យសម្លាប់ ក៏ប៉ុន្តែសហចៅក្រមស៊ើបអង្កេតនេះ គឺថាអត់មានបានលើកយកសម្តីរបស់ ថង ធឿយ នេះមកយកមកសំអាងអ្វីបន្តិចសោះ។ អ៊ឹម ចែម អះអាងនៅក្នុងកថាខណ្ឌ៦១ ថាភស្តុតាងនេះ មិនគ្រប់គ្រាន់ មិនធ្ងន់ធ្ងរគ្រប់គ្រាន់ ឬមិនស៊ីចង្វាក់គ្នា ដើម្បីគាំទ្រទៅដល់ការចោទប្រកាន់មកលើក អ៊ឹម ចែម នេះទេ។ ក៏ប៉ុន្តែ ថង ធឿយ ភស្តុតាងរបស់ ថង ធឿយ នេះ គឺថាមានភាពធ្ងន់ធ្ងរ និង ស៊ីចង្វាក់គ្នាទាំងស្រុង ដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី។ នេះគឺជាលើកដំបូង ដែលរឿងរ៉ាវពាក់ព័ន្ធទៅនឹការរៀបការដោយបង្ខំ និងការរំលោភទៅលើស្ត្រីវ័យក្មេងម្នាក់។ ការចូលរួមពាក់ព័ន្ធរបស់ អ៊ឹម ចែម គឺគេថាសក្ខីកម្មរបស់ជនរងគ្រោះពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនេះ គឺវាស៊ីចង្វាក់គ្នាជាមួយនឹងសាក្សីដទៃទៀត។

[១៤:៣១:១២]

ភស្តុតាងដែលបានមកពីជនរងគ្រោះក៏ដូចសាក្សីដែលបានស្បថនោះ គឺថាវាអាចឆ្លើយតបទៅនឹងបទដ្ឋាននៃការ នៃភវនីយហេតុដែលអាចអនុវត្តបាននៅក្នុងដីកាដំណាក់កាលនៃកិច្ចនីតិវិធីនៃការចោទប្រកាន់នេះ។ សែន សុផុន ដែលធ្វើការនៅក្នុងកងចល័តនៅស្ពានស្រែងនេះ គឺឯកសារ D219/516 ចម្លើយ៥១ គឺអ្នកនៅក្នុងកងរបស់គាត់ហ្នឹង គឺថាត្រូវបានបង្ខំឲ្យរៀបការ និងសុំដកស្រង់៖ “ហើយការរៀបការនេះ កើតមានឡើងនៅក្រោមអធិបតីភាពរបស់ យាយចែម” បញ្ចប់ការដកស្រង់។ ប្រជាជនមិនអាចបដិសេធមិនរៀបការបានទេ ពីព្រោះថា បើថាបដិសេធមិនរៀបការគេនឹងចោទប្រកាន់ថា ពួកគាត់ជាខ្មាំង។ សែន សុផុន នេះក៏បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំនៅឯស្ពានស្រែង ការដ្ឋានស្ពានស្រែង នៅពេលដែលគាត់រៀបរាប់អំពីបុរសស្ត្រីដែលត្រូវបានគេកាត់សក់ ហើយយកទៅរៀបការនោះ។ ហើយ សែន សុផុន ក៏បាននិយាយថា អ៊ឹម ចែម បានទៅពិនិត្យមើលការដ្ឋានស្ពានស្រែងនេះ ជាញឹកញាប់ គឺដើងទំព័រ៣៨១ និង៥៨៩ ហើយក្នុងនោះមានការបាត់ខ្លួនមនុស្សជាច្រើននៅស្ពានស្រែងនេះផងដែរ។ ប៉ុន្តែ ក.ស.ច.ស មិនបានយោងទៅលើភស្តុតាងរបស់ សែន សុផុន ពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំទេ។ នៅក្នុងកថាខណ្ឌ៥៨ នៃចម្លើយរបស់

គាត់ អ៊ឹម ចែម មានបំណងកាត់បន្ថយធ្វើម៉េចឲ្យមានការចុះថយនូវសក្ខីកម្មរបស់សាក្សី សែន សុផុន នៅក្នុងសំណុំរឿង ០០២នេះ។ នេះ គឺជាចេតនាមួយច្បាស់លាស់នៅក្នុងការលាក់កំបាំង ឬក៏ធ្វើម៉េចធ្វើឲ្យភស្តុតាងប្រឆាំងមកលើរូបគាត់ហ្នឹងមានការចុះខ្សោយ។

[១៤:៣៣:៣៣]

សុខ រំ ដែលមកពីភូមិភាគនិរតីដែរ នៅក្នុងឯកសារ D119/108 ចម្លើយ១០៨ ថាស្ត្រីនៅក្នុងកងរបស់គាត់ត្រូវបានចូលរួមប្រជុំ ហើយ អ៊ឹម ចែម ណែនាំស្ត្រីទាំងនោះឲ្យរៀបការ ជាពិសេស គឺថារៀបការជាមួយទាហានដែលពិការជើង។ ហើយនៅក្នុងចម្លើយរបស់ សុខ ព្រំ គឺចម្លើយ១១០ ប្រសិនបើ សុំដកស្រង់៖ "ប្រសិនបើអ្នកណាម្នាក់បដិសេធសំណើសុំរៀបការនេះ គឺថាពួកគេពិតជានឹងត្រូវបានចាប់ខ្លួនហើយ" បញ្ចប់ការដកស្រង់។

សហចៅក្រមស៊ើបអង្កេតបានយោងទៅលើភស្តុតាងរបស់ សុខ ព្រំ ចំនួនពីរដង នៅក្នុងដីកាដំណោះស្រាយដែលថា អ៊ឹម ចែម បានចូលរួមប្រជុំនៅក្នុងភូមិភាគនិរតីពាក់ព័ន្ធទៅនឹងការបង្អង់ការបោសសម្អាតមួយអន្លើ ទុកមួយអន្លើសិននៅក្នុងភូមិភាគ តំបន់៥ ភូមិភាគពាយ័ព្យ ក៏ប៉ុន្តែសហចៅក្រមស៊ើបអង្កេតនេះ គឺមិនបានយោងទៅលើភស្តុតាងរបស់ សុខ រុំ អំពីការរៀបការដោយបង្ខំនេះទេ។ ការអះអាងរបស់ អ៊ឹម ចែម នៅក្នុងកថាខណ្ឌ៥១ នៃចម្លើយរបស់គាត់ គឺថាភស្តុតាងរបស់ សុខ រុំ ហ្នឹងគឺថាមិនមានអត្ថន័យត្រឹមត្រូវ ឬមិនមានតម្លៃជាភស្តុតាងទេ។ ប៉ុន្តែការវាយតម្លៃរបស់ អ៊ឹម ចែម ភស្តុ-តាងនេះ វាមានស្ថានមួយដែលជាការប្រឆាំងទៅនឹងភស្តុតាងប្រឆាំងទៅនឹងរូបគាត់។ អ៊ឹម ចែម ខកខានមិនបានលើកឡើងមកនិយាយអំពីការចូលរួមរបស់គាត់ នៅក្នុងការរៀបការដោយបង្ខំនេះទេ។ សាក្សីបីរូប ព្រឹត្តិការណ៍ចំនួនខុសៗគ្នាបី គឺបានចង្អុលបង្ហាញការចូលរួមពាក់ព័ន្ធរបស់ អ៊ឹម ចែម នៅក្នុងការរៀបការដោយបង្ខំ និងការរួមភេទដោយបង្ខំពីអង្គការដោយផ្ទាល់ទៅលើអ្នកចូលរួមទាំងអស់នោះ។ ការចូលរួមពាក់ព័ន្ធរបស់ អ៊ឹម ចែម នៅក្នុងការរៀបការដោយបង្ខំ គឺជាអំពើអមនុស្សធម៌ គឺត្រូវបានពិចារណា ថាតើ អ៊ឹម ចែម ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់សាលាក្តីនេះដែរឬទេ? សហចៅក្រមស៊ើបអង្កេតមិនបានធ្វើដូច្នេះទេ នេះគឺជាកំហុសអង្គច្បាប់សុទ្ធសាធ។

[១៤:៣៦:១១]

លោក លោកស្រីចៅក្រម សំអាងហេតុទី៣ និងទី៤ ពាក់ព័ន្ធនឹងកំហុសសហចៅក្រមស៊ើបអង្កេតដែលមិនបានកំណត់និយមន័យច្បាប់ឲ្យបានច្បាស់លាស់នៅក្នុងសំអាងហេតុទី៣នេះ និងក៏ដូចជា

នៅក្នុងសំអាងហេតុទី៤។ នៅក្នុងកថាខណ្ឌ២២ នៃចម្លើយរបស់គាត់ អ៊ឹម ចែម បាននិយាយថា សហចៅក្រមស៊ើបអង្កេត នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់សហចៅក្រមស៊ើបអង្កេត គឺពាក់ព័ន្ធទៅនឹងកំហុសរបស់សហចៅក្រមស៊ើបអង្កេតដែលមិនអនុវត្តច្បាប់ដែលបានកំណត់ហើយនេះឲ្យបានត្រឹមត្រូវនោះទេ។

ឥឡូវខ្ញុំសូមនិយាយអំពីសំអាងហេតុទី៣សិន ដែលសហចៅក្រមស៊ើបអង្កេតខកខានមិនបានឲ្យ អ៊ឹម ចែម នេះទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលនៅភ្នំប្រុស។ គឺនៅក្នុងកថាខណ្ឌ២៨៨ គឺថាត្រូវតែបង្ហាញអំពីធាតុចេតនាជាមុន លក្ខខណ្ឌនៃធាតុចេតនាជាមុនសិន មុនសម្រាប់ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល ជាពិសេសពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខភ្នំក្រោម។ ដែលថាវាមិនច្បាស់ទេ សុំដកស្រង់ ៖ “វាមិនច្បាស់ ប្រសិនណាជាការសម្លាប់ហ្នឹងគឺត្រូវបានធ្វើឡើងដោយមានចេតនាជាមុននៅក្នុងឧក្រិដ្ឋកម្មដ៏ទូលំទូលាយនេះ”។

[១៤:៣៧:៥៤]

បាទ នៅក្នុងករណីបណ្ដឹងឧទ្ធរណ៍ នៅក្នុងកថាខណ្ឌ៥៥១, ៥៥២ និង៥៥៤ នៃសាលាកំពូល អ.វ.ត.ក គឺដូចគ្នានឹងតុលាការ អាយ.ស៊ី.ធី.វ៉ាយដែរ សាលាឧទ្ធរណ៍នៅក្នុងរឿងក្ដី ស្តានីស៊ីក ហើយនិង សាំប្រ៊ិនជីណិន គឺសាលាឧទ្ធរណ៍សម្រេចថា គឺថាគោរពគឺថា អាចមូលហេតុនៃការសម្លាប់រង្គាលនោះ គឺថាបង្ហាញភស្តុតាងដោយអង្គហេតុដាច់ដោយឡែកដោយការ ហើយមិនចាំបាច់មានមូលដ្ឋានច្បាប់តម្រូវឲ្យចារីបង្កើតបានជាចេតនាដើម្បីសម្លាប់មនុស្សដោយរង្គាលនោះទេ។

ក.ស.ច.ស ក៏បានប្រើនូវចេតនាជាមុននោះ គឺថាលើកឡើងនូវកថា -- គឺបញ្ជាក់អំពីការផែនការគិតទុកជាមុនដើម្បីឲ្យមានការកាប់សម្លាប់រង្គាលកើតឡើង គឺថាចេតនាដើម្បីការប្ដូរនូវចេតនានេះ គឺផ្ទុយពីគោលបំណងនៃតុលាការនេះ គឺថានៅក្នុងកថាខណ្ឌ៤១៨, ៤១៩ នៅក្នុងសេចក្ដីសាលក្រមសាលាដំបូង គឺតុលាការកំពូលនៅក្នុងបណ្ដឹងសាទុក្ខហ្នឹងបានច្រានចោលទឡ្ហីករណ៍ដែលថា ជនជាប់ចោទបានដឹងថាមានការសម្លាប់ជាផ្នែកនៃការសម្លាប់ក្នុងសហឧក្រិដ្ឋកម្មទ្រង់ទ្រាយធំនោះ។ ហើយមិនមាននៅក្នុងយុត្តិសាស្ត្ររបស់ អ.វ.ត.ក ឬក៏តុលាការអន្តរជាតិទេដែលដាក់បញ្ចូលទាំងលក្ខខណ្ឌតម្រូវនៃចេតនាដែលថាត្រូវតែមានការគ្រោងទុក ទោះបីជាបទប្រល័យពូជសាសន៍នោះក៏ដោយ គឺថា ប៉ុន្តែវាទាក់ទងទៅនឹងចេតនាឧក្រិដ្ឋនោះ តុលាការឧទ្ធរណ៍របស់ អាយ.ស៊ី.ធី.អ័រ នៅកថាខណ្ឌ២៦៦ បានសម្រេចថា ការស៊ើបអង្កេត គឺថាមិនស្វះស្វែងរកចេតនាជាក់លាក់មុនការប្រព្រឹត្តនូវអំពើនោះទេ។ ដូចគ្នានេះដែរ

នៅក្នុងរឿងក្ដី គ្រីស្ទីក នោះគឺថា កថាខណ្ឌនៅក្នុងសេចក្ដីសម្រេច៥៧២ អាយ.ស៊ី.ធី.វ៉ាយ បានសម្រេចថា គឺថាបទឧក្រិដ្ឋនេះគឺថាមិនចាំមានការគ្រោងទុកនោះទេ គឺអាចគេយល់ជាមុនបានថា ទោះបីជាមានចេតនានៅពេលចាប់ផ្ដើមនៃប្រតិបត្តិការនោះ គឺមិនបំផ្លាញក្រុមនោះទេ ប៉ុន្តែនៅក្នុងគោលបំណងពេលក្រោយ គឺអាចនឹងអនុវត្តនូវការប្រតិបត្តិការមានការបំផ្លាញនោះ។ អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្ដី ០០២/០១ នៅក្នុងកថា៥២៥ ថាៈ “ការសម្លាប់រង្គាល គឺជាទូទៅគឺការសម្លាប់ក្នុងទ្រង់ទ្រាយធំ ហើយនេះគឺបានឆ្លុះបញ្ចាំងនៅក្នុងចេតនាអំពើឧក្រិដ្ឋ និងមានចេតនាឧក្រិដ្ឋ។ ការសម្លាប់ត្រូវតែកើតឡើងក្នុងទ្រង់ទ្រាយធំ ហើយចារីត្រូវបានដឹងអំពីការកាប់សម្លាប់ជាទ្រង់ទ្រាយធំនោះ” ចប់សេចក្ដីដកស្រង់។ នេះគឺជាមិនមានលក្ខខណ្ឌតម្រូវដែលថា ត្រូវតែចារីដឹងពីការសម្លាប់ទ្រង់ទ្រាយធំមុនពេលអំពើឧក្រិដ្ឋនោះកើតឡើងនោះទេ។ អ៊ឹម ចែម បានបញ្ជាក់ថា នៅក្នុងកថាខណ្ឌ៨០,៨៤ នៅក្នុងចម្លើយរបស់គាត់ថា ការបទឧក្រិដ្ឋសម្លាប់រង្គាលគឺថាតម្រូវមានចេតនាជាមុន គឺអាស្រ័យទៅលើកាលៈទេសៈនៃរឿងក្ដី ប៉ុន្តែមិនត្រូវបានគាំទ្រដោយយុត្តិសាស្ត្រអ្វីទេ។ ឧក្រិដ្ឋនៅក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិគឺមិនមានធាតុផ្សំខុសៗគ្នាទៅតាមបរិបទនោះទេ ស្ថានភាពមួយចំនួនត្រូវបានបង្កើត គឺថាអាចនឹងមានស្តង់ដារពីរ គឺថាទាក់ទងទៅទម្រង់នៃការទទួលខុសត្រូវហើយ ដូចជា ដោយការអនុវត្តមិនត្រឹមត្រូវស្មើភាពគ្នានូវច្បាប់ដោយ អ.វ.ត.ក។ ដូច្នេះ យើងឃើញច្បាស់ថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តនិយមន័យត្រឹមត្រូវនៃធាតុផ្សំនៃការសម្លាប់រង្គាល ខ្លួនអាចនឹងឃើញថា អ៊ឹម ចែម គឺមានចេតនាសម្លាប់មនុស្សរង្គាលនៅភ្នំត្រយូង មន្ទីរសន្តិសុខភ្នំត្រយូង។ បើយើងមើលដីកាដំណោះស្រាយនោះ គឺជាមានសេចក្ដីសន្និដ្ឋានផ្លូវច្បាប់តែមួយ ដែលសមស្របទៅនឹងការរកឃើញអង្គហេតុរបស់ចៅក្រមស៊ើបអង្កេត។

[១៤:៤២:៣៩]

សហចៅក្រមស៊ើបអង្កេត គឺថាធ្វើការប៉ាន់ប្រមាណដោយមិនច្បាស់លាស់គឺថានៅពាក់កណ្ដាលឆ្នាំ១៩៧៧ និងមករា ១៩៧៩ គឺមានអ្នកទោស២០០០នាក់ត្រូវបានសម្លាប់ ដោយអ្នកយាមរាប់រយនាក់ទៀតស្លាប់ដោយអត់អាហារ និងមានជំងឺ។ ការសម្លាប់បែបនេះគឺថាមិនមែនសម្លាប់ដោយគ្មានទំនាក់ទំនង គឺមិនមែនជាហេតុការណ៍ដាច់ដោយឡែកនោះទេ។ វាកើតឡើងនៅទីកន្លែងមួយ ហើយសហចៅក្រមអង្កេតបានរកឃើញថានៅកថាខណ្ឌ២៨៨របស់ខ្លួនថា មនុស្សជាច្រើនត្រូវបានគេសម្លាប់ដោយមូលហេតុតែមួយដូចគ្នា គឺអាកប្បកិរិយាផ្ទុយទៅនឹងមនោគមន៍វិជ្ជា ហើយនិងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា”ចប់សេចក្ដីដកស្រង់។

[១៤:៤៣:៣៦]

សហចៅក្រមស៊ើបអង្កេតបានរកឃើញថា នៅក្នុងកថាខណ្ឌ២០៨ ថា ការកាប់សម្លាប់នោះ គឺធ្វើឡើងជាប្រចាំ ហើយអ្នកយាមនោះបានអួតអាងដោយខ្លួនឯងថាខ្លួនជាអ្នកបានសម្លាប់អ្នកទោស អ៊ំ! ប្រជាជនទាំងនោះ។ ដីកាដំណោះស្រាយបានបញ្ជាក់យ៉ាងច្បាស់ថាគ្មានអ្វីកើតឡើងនៅភ្នំត្រយ៉ូងដោយគ្មាន អ៊ឹម ចែម នោះទេ។ អនុលោមទៅតាមការរកឃើញរបស់សហចៅក្រមស៊ើបឃើញ អ៊ឹម ចែម មានអំណាចរួមទូទៅលើភ្នំត្រយ៉ូង ហើយនិងបានត្រួតពិនិត្យការប្រព្រឹត្តប្រតិបត្តិនោះផង។ ហើយគាត់បានតែងតាំង ទុំ សឿន ឲ្យធ្វើជាប្រធាននៃមន្ទីរសន្តិសុខភ្នំត្រយ៉ូង ហើយគាត់បានទទួលរបាយការណ៍ ពី ទុំ សឿន ហ្នឹងជាទៀង ប្រចាំដោយផ្ទាល់ខ្លួនថាតើអ្នកណានឹងត្រូវបញ្ជូនទៅមន្ទីរភ្នំត្រយ៉ូងនោះ ហើយ អ៊ឹម ចែម បានរៀបចំកិច្ចប្រជុំដើម្បីសម្រេចពីការចាប់ខ្លួន ហើយនិងការកំណត់ថាអ្នកណាអ្នកទោសធ្ងន់ អ្នកទោសស្រាល ហើយ អ៊ឹម ចែម បានបញ្ជា ទុំ សឿន ឲ្យសម្លាប់អ្នកទោស។ ទុំ សឿន ហើយក៏ទទួលថាគាត់បានទទួលបញ្ជាពី អ៊ឹម ចែម ឲ្យសម្លាប់មនុស្សបួននាក់ ហើយសហចៅក្រមស៊ើបអង្កេតនឹងបញ្ជាក់នៅក្នុងកថាខណ្ឌ២១២ នៅក្នុងដីកាដំណោះស្រាយថា ទុំ សឿន បានសម្លាប់ គឺថាអាចនឹងអនុវត្តនៅការសម្លាប់នៅមន្ទីរសន្តិសុខនេះ ហើយគឺថាយើងច្បាស់ណាស់ថា អំពីភស្តុតាង អំពីអំណាចរបស់ អ៊ឹម ចែម ទូលំទូលាយថា មានតែ អ៊ឹម ចែម ទេជាអ្នកសម្រេចអំពីជោគវាសនាអ្នកជាប់ឃុំទាំងអស់នៅភ្នំត្រយ៉ូងនោះ។

[១៤:៤៥:២៧]

លោក លោកស្រីចៅក្រម សហចៅក្រមស៊ើបអង្កេតបានរកឃើញនៅក្នុងកថាខណ្ឌ២៨៨ នៃដីកាដំណោះស្រាយ គឺថាមានការកាប់សម្លាប់មនុស្សជាង២០០០នាក់នឹងស្លាប់នៅភ្នំត្រយ៉ូង ហើយបានឡើងដល់កម្រិតនៃការសម្លាប់រង្គាលដែលជាធាតុផ្សំនៃការសម្លាប់ បទឧក្រិដ្ឋសម្លាប់។ ដូច្នេះ នេះគឺជាការខុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតក្នុងការសម្រេចថា ត្រូវមានចេតនាជាមុននោះ។ ដូច្នេះ ការរកឃើញខាងអង្គហេតុហ្នឹង គឺបង្ហាញច្បាស់ថា បង្ហាញថា អ៊ឹម ចែម មានការទទួលខុសត្រូវលើការកាប់សម្លាប់រង្គាលនៅមន្ទីរសន្តិសុខភ្នំត្រយ៉ូង។

ចូលទៅដល់មូលដ្ឋានទី៤ សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងអង្គច្បាប់ដោយខកខានមិនបានរកឃើញថា អ៊ឹម ចែម ទទួលខុសត្រូវបទឧក្រិដ្ឋអំពីការបាត់ខ្លួនដោយបង្ខំ ហើយនិងអំពើអមនុស្សធម៌នៅការដ្ឋានទំនប់ស្ពានស្រែង។ គាត់បានអនុវត្តអត្ថន័យ ឬក៏និយមន័យច្បាប់ដោយមិនត្រឹមត្រូវចំពោះ

ធាតុផ្សំនៃបទល្មើស។ បទឧក្រិដ្ឋនៅក្នុងបញ្ហានេះ គឺជាការបាត់ខ្លួនដោយបង្ខំ ជាអំពើអមនុស្សធម៌ គឺជាធាតុផ្សំផ្លូវច្បាប់ដែលស្ថិតនៅក្នុងអំពើអមនុស្សធម៌ គឺជាអំពើ ឬការខកខានដែលបង្កឲ្យមានការរងគ្រោះរាងកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ គឺដែលជាធាតុផ្សំដ៏ធ្ងន់ធ្ងរ ឬតាមធម្មតានៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។ សហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តនិយមន័យនេះទេ ផ្ទុយទៅវិញនៅក្នុងកថាខណ្ឌ៧៥ និង៧៦ នៃដីកាដំណោះស្រាយសហចៅក្រមស៊ើបអង្កេតបានពឹងផ្អែកលើ និយមន័យនៃការបាត់ខ្លួនដោយបង្ខំ ដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី ០០២/០១ នៅក្នុងសាលក្រម ប៉ុន្តែមិនបានពិនិត្យមើលអង្គហេតុដែលថា អង្គជំនុំជម្រះសាលាកំពូល បានរកឃើញថា សាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការសម្រេចបែបនោះ។ ជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យការបាត់ខ្លួនដោយបង្ខំហ្នឹង គឺថាជាបទឧក្រិដ្ឋទំនើបនៃការបង្ខំឲ្យបាត់ខ្លួន ផ្ទុយទៅវិញបានយោងទៅរកធាតុផ្សំនៃអំពីអមនុស្សធម៌ផ្សេងទៀត។

[១៤:៤៧:៥២]

នៅក្នុងនិយមន័យរបស់សាលាដំបូង ប្រភពច្បាប់ត្រូវតែ -- អាជ្ញាធរត្រូវតែមិនព្រមផ្តល់ភស្តុតាងព័ត៌មាន ពីទីកន្លែងអ្នកដែលបាត់ខ្លួន។ សហចៅក្រមស៊ើបអង្កេតអនុវត្តនិយមន័យនេះ នៅក្នុងដីកាដំណោះស្រាយដោយរកឃើញថានៅក្នុងកថាខណ្ឌ៣០២ ថានៅពេលណាមានភស្តុតាងគ្រប់គ្រាន់នៃការបាត់ខ្លួន ហើយមានការផ្តល់បន្តិចបន្តួចថា ក្រុមគ្រួសារនៃអ្នកដែលបាត់ខ្លួនមិនអាចនឹងទទួលព័ត៌មានអំពីអ្នកដែលបាត់ខ្លួនបាន។ ដូច្នេះមិនមានភស្តុតាង មិនចាំបាច់មានការសាកសួរទៅលើអាជ្ញាធរអំពីទីតាំងនៃបទឧក្រិដ្ឋនោះទេ។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ដោយហេតុនេះតែមួយភស្តុតាងមិនអនុញ្ញាតឲ្យយើងសន្និដ្ឋានថា បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយដែលជាបទអមនុស្សធម៌ផ្សេងទៀតត្រូវបានកើតឡើងពីការបាត់ខ្លួនដោយបង្ខំនៅការដ្ឋានស្ពានស្រែងទេ។

[១៤:៤៨:៥៧]

អង្គជំនុំជម្រះសាលាកំពូល នៅក្នុងកថាខណ្ឌ៦៥៣ នៅក្នុងសាលដីការបស់ខ្លួននោះ គឺបានបញ្ជាក់ថា បើអាជ្ញាធរមិនផ្តល់ព័ត៌មានអំពីទីកន្លែងអ្នកបាត់ខ្លួននោះទេ ហើយរកឃើញថា វាមិនមានភាពពាក់ព័ន្ធទៅនឹងធាតុផ្សំនោះថា តើជាធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀត ត្រូវបានបំពេញនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងកថាខណ្ឌ៥៨៩ បានរៀបរាប់ពីវិធីរបស់សាលាដំបូង ដើម្បីកំណត់បទល្មើសនៃការបាត់ខ្លួនដោយបង្ខំនេះ ថាជាវិធីដែលសហចៅក្រមស៊ើបអង្កេតបានអនុវត្តតាម

ហើយជាការអនុវត្តដែលមិនត្រឹមត្រូវទៅតាមច្បាប់។ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកថាខណ្ឌទី១០ នោះ ដីកាដំណោះស្រាយថា ហើយមិនមានទ្រឹស្តី ដែលបញ្ជាក់ឲ្យសម្រេចតាមឬមិនតាមនៅអ.វ.ត.កទេ។ ប៉ុន្តែទាក់ទងទៅនឹងភាពច្បាស់លាស់ និងឯកសណ្ឋានភាពនៃច្បាប់ ដូច្នេះគឺថា បើសិនជាខ្លួនមិនបានគោរពតាមសេចក្តីសម្រេចតុលាការកំពូល លុះត្រាណាតែខ្លួនបានមានឆន្ទានុសិទ្ធិ។ ហើយនៅក្នុងសាលដីការបស់តុលាការកំពូល ទោះបីជាការមិនគោរពទៅតាមនោះដែរ នោះគឺមានន័យថាសហចៅក្រមស៊ើបអង្កេតក៏បានពឹងផ្អែកទៅលើនិយមន័យរបស់អង្គជំនុំជម្រះតុលាការកំពូល គឺនិយាយថា គឺជាការធ្វើការតាម ប៉ុន្តែងាកចេញពីយុត្តិសាស្ត្ររបស់តុលាការអង្គជំនុំជម្រះតុលាការកំពូល។

[១៤:៥០:៤៧]

កំហុសឆ្គងគឺបានអនុវត្តនិយមន័យច្បាប់ដោយមិនត្រឹមត្រូវ ហើយយើងឃើញច្បាស់ថា អាចនឹងឃើញការទទួលខុសត្រូវរបស់ អ៊ឹម ចែម នូវការបាត់ខ្លួនមនុស្សដោយបង្ខំនៅស្ពានស្រែង។ អ៊ឹម ចែម បានបញ្ជាក់នៅក្នុងចម្លើយតបរបស់ខ្លួនក្នុងកថាខណ្ឌ៩៨ថា បើសិនមិនអាចនឹងសន្និដ្ឋានថា ការបាត់ខ្លួនហ្នឹងមានការឈឺចាប់ផ្លូវចិត្តនិងផ្លូវកាយនោះទេ ប៉ុន្តែបើសហចៅក្រមស៊ើបអង្កេតរកឃើញអង្គហេតុថា នៅក្នុងស្ពានស្រែងហ្នឹង បើមានករណីបាត់ខ្លួន គឺថាគឺអាចនឹងទទួលរងនូវការឈឺចាប់យ៉ាងធ្ងន់ធ្ងរ។ ពិនិត្យមើលដីកាដំណោះស្រាយសហចៅក្រមស៊ើបអង្កេត បានរកឃើញដូចខាងក្រោមនេះ ទាក់ទងទៅនឹងការដ្ឋានស្ពានស្រែង។ អ្នកយាមកាន់អាវុធ និងគ្មានអាវុធក្តី គឺមើល ត្រួតមើលអ្នកកម្មករនៅទីនោះ គេបង្ខំឲ្យអ្នកទាំងនោះធ្វើការ បើមិនធ្វើការទេ គេនឹងត្រូវសម្លាប់។ គឺមានបរិយាកាសភ័យខ្លាចនៅការដ្ឋានការងារ ការចាប់ខ្លួន ហើយនិងការបាត់ខ្លួនកម្មករតែងតែកើតឡើងជាទូទៅ។ មូលហេតុនៃការចាប់ខ្លួនរាប់បញ្ចូលទាំងធ្វើការមិនបំពេញផែនការ ឬក៏ទំនាក់ទំនងគ្រួសារ អ្នកដែលត្រូវបាត់ខ្លួន ហើយនិងដែលបាត់ពីទីនោះត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខភ្នំត្រយ៉ូង។ ក្រុមគ្រួសារមិនអាចនឹងកំណត់ពីទីជោគវាសនា ឬទីកន្លែងរបស់ពួកគេបានទេ។

[១៤:៥២:២៨]

**ប្រធានអង្គបុរេ៖**

ខ្ញុំសូមជម្រាប សូមផ្អាកពីរបីនាទីដើម្បីប្តូរឌីសបាទ។ សូមផ្អាកពីរ ឬបីនាទីដើម្បីប្តូរឌីស។

**លោក កូមេន ខេននី៖**

បាទ លោកប្រធាន។

*(សម្រាករយៈពេលខ្លី)*

**ប្រធានអង្គបុរេ៖**

សូមអញ្ជើញបន្តទៀតបាទ!

**លោក កូមេន ខេននី៖**

សូមអរគុណលោកប្រធាន។

លោក លោកស្រីចៅក្រម ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេត គឺថាការបកស្រាយមួយគត់ដែលអាចធ្វើទៅបាន គឺមានការឈឺចាប់រាងកាយផ្លូវចិត្តយ៉ាងធ្ងន់ចំពោះអ្នកដែលបាត់ខ្លួន ក៏ចំពោះសមាជិកក្រុមគ្រួសារដែលទទ្នឹងរង់ចាំដែរ។ បើគ្មានការខុសឆ្គងផ្លូវច្បាប់ ដោយអនុវត្តធាតុផ្សំមិនត្រឹមត្រូវអំពីការបាត់ខ្លួនដោយមិនបង្ខំទេ សហចៅក្រមស៊ើបអង្កេត ការរកឃើញរបស់គាត់បានបង្ហាញថា គឺ អ៊ឹម ចែម ជាអ្នកទទួលខុសត្រូវចំពោះការបាត់ខ្លួនដោយបង្ខំនៅស្ពានស្រែង។ ការវាយតម្លៃដ៏ត្រឹមត្រូវដែលថាតើគាត់មានការទទួលខុសត្រូវបុគ្គល គឺវាត្រូវស្ថិតនៅលើការវាយតម្លៃបទឧក្រិដ្ឋ ដែលគាត់ទទួលខុសត្រូវ ហើយនិងតួនាទីរបស់គាត់ដែលគាត់កាន់នៅពេលនោះ។

[១៤:៥៤:៣៤]

បាទ មូលដ្ឋានប្រាំ និងប្រាំមួយរបស់បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា គឺនិយាយអំពីកំហុសឆ្គងអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេត ដែលមិនបានរកឃើញថា អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្ដែត ដែលតាមពិត ហើយនៅក្នុងមូលដ្ឋានទី៦ គឺ អ៊ឹម ចែម ជាសមាជិកនៃគណៈតំបន់១៣។ ការរកឃើញអង្គហេតុនេះគឺ អ៊ឹម ចែម មានតួនាទី ដោយមិនពាក់ព័ន្ធទៅនឹងភស្តុតាងដែលបុគ្គលដែលអាចដឹង។ នៅក្នុងចម្លើយផ្ទាល់របស់គាត់ ដែលគាត់ឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺនៅក្នុងសំណុំរឿងមាន គឺ អ៊ឹម ចែម បានបញ្ជាក់យ៉ាងច្បាស់ថា គាត់ជាសមាជិកនៃគណៈស្រុកតំបន់ ១៣ ហើយគាត់ក៏មិនបានបញ្ជាក់ពីខ្លឹមសារអំពីការទទួលស្គាល់របស់គាត់នោះនៅក្នុងចម្លើយតបរបស់គាត់ទេ។ ហើយនៅក្នុងបទសម្ភាសន៍ដោយស្ម័គ្រចិត្ត គាត់បានឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយអាចនឹងជាការបំពានទៅលើសិទ្ធិមិនឆ្លើយដាក់បន្ទុកខ្លួនឯង។ ការទទួលស្គាល់របស់ អ៊ឹម ចែម គឺវាស៊ីចង្វាក់ទៅនឹងអ្វីដែលបទសម្ភាសន៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដីកាដំណោះស្រាយបានសន្និដ្ឋានដោយខុសនៅក្នុងកថាខណ្ឌ១៤៣ ថា អ៊ឹម ចែម តួនាទីរបស់គាត់នៅភូមិភាគនិរតិនោះ គឺគ្រាន់តែជាប្រធានសមាគមនារីតំបន់១៣តែប៉ុណ្ណោះ។ ដូច្នេះគឺ អាចនឹងបញ្ហានេះមិនដែលបានពន្យល់ទេ

គឺថាមិនមានបុគ្គលណាអាចមានតំណែងច្រើនជាងមួយក្នុងពេលតែមួយនោះទេ គឺថាមានឧទាហរណ៍ជាច្រើនដែលថាបុគ្គលមួយចំនួននៅក្នុងរបបកម្ពុជាដែលមានតំណែងច្រើនៗ ក្នុងពេលតែមួយនោះដែរ។

សហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណាថាភស្តុតាងនៅពេលដែលវាយតម្លៃទាំងមូលហើយនិងត្រឹមត្រូវគឺថាអាចនឹងសម្របសម្រួលជាមួយអង្គហេតុថា អ៊ឹម ចែម មានតួនាទីច្រើនជាងមួយក្នុងពេលតែមួយ។ មិនមានអ្នកវិនិច្ឆ័យលើអង្គហេតុអាចនឹងសន្និដ្ឋានដូចដែលសហចៅក្រមស៊ើបអង្កេតសន្និដ្ឋានបែបនេះទេ។ ឥឡូវនេះពិនិត្យមើលមូលដ្ឋានទីប្រាំជាមុន សហចៅក្រមស៊ើបអង្កេតបានខុសឆ្គងអង្គហេតុដោយរកឃើញក្នុងអង្គហេតុនោះថា កថាខណ្ឌ១៤៤ ថាភស្តុតាងមិនគាំទ្រការអះអាងថា អ៊ឹម ចែម ជាលេខាស្រុកកោះអណ្តែតនោះ។

លោក លោកស្រីចៅក្រម អ៊ឹម ចែម គាត់និយាយដោយខ្លួនឯងថា គាត់ជាលេខាស្រុកកោះអណ្តែត។ ចំណុចខាងក្រោមនេះគឺជាបទសម្ភាសន៍ទី៣របស់គាត់ជាមួយនឹង ឌី.ស៊ី.ខេម។ សុំអនុញ្ញាតចាក់ខ្សែអាត់ទី១។

លោកប្រធាន លោកចៅក្រមតើមានបានស្តាប់ឮវីដេអូឃ្លីបមួយនេះដែរទេ?

[១៤:៥៨:៣២]

*(ការបង្ហាញឯកសារជាសំឡេង)*

*"សួរ៖ អ្នកគ្រប់គ្រង (ឮមិនច្បាស់) ធ្វើបានគាត់(ឮមិនច្បាស់) ឆ្លើយ៖ អ្នកគ្រប់គ្រងខាងកោះអណ្តែតហ្នឹងវាទំនាស់គ្នាផង ហើយធ្វើការងារអត់ឯកភាពគ្នា។ ដល់ខ្ញុំទៅនៅទៅ ដកប្រធានហ្នឹងទៅគិរីវង់។ សួរ៖ អ៊ីចឹងកាលនៅកោះអណ្តែតពីណាគេ? ឆ្លើយ៖ ទៀង ឥឡូវគាត់ស្លាប់ហើយ។ សួរ៖ ឈ្មោះ ទៀង? ទៀង គាត់ដកទៅនៅគិរីវង់វិញ? ឆ្លើយ៖ ចាស ហើយដល់ខ្ញុំនៅហ្នឹងបីនាក់ តាមួយធ្វើសមាជិក ហើយអនុខ្ញុំហ្នឹង មានប្អូនថ្លៃ តាម៉ុក។ សួរ៖ អនុពីណាគេ? ឆ្លើយ៖ តាសាន ប្អូនថ្លៃតាម៉ុក។ សួរ៖ មានតាសាន។ បើអ៊ីចឹងកាលអ៊ំកោះអណ្តែតមានអ៊ំ មានតាសាន។ ឆ្លើយ៖ មានតាចាន់។ សួរ៖ តាចាន់។ មានបីនាក់ហ្នឹង។ ឆ្លើយ៖ តាចាន់ គាត់ចាស់ហើយ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

[១៤:៥៩:៣២]

នៅក្នុងកិច្ចសម្ភាសន៍ដដែលហ្នឹង អ៊ឹម ចែម គាត់និយាយថា ដំបូងគេបានចាត់តាំងទៅ-- ប៉ុល ពត និងតាម៉ុក បានចាត់តាំងគាត់ទៅស្រុកអង្គរជ័យ។ នៅពេលសួរថា ហេតុអ្វីបានគេបញ្ជូន លោកស្រី

ពីអង្គរជ័យទៅកោះអណ្តែត? អ៊ឹម ចែម បានឆ្លើយ សុំដកស្រង់ "ដោយសារតែខ្ញុំអាចបំពេញផែនការការបាន" បញ្ចប់ការដកស្រង់។ ដីកាដំណោះស្រាយបានយោងទៅលើការទទួលស្គាល់របស់ អ៊ឹម ចែម អំពីតួនាទីរបស់គាត់ជាលេខាស្រុក ត្រង់កថាខណ្ឌ១៤៦ ហើយទោះជាយ៉ាងណាដែរ គឺថាសរុបទៅ គឺ អ៊ឹម ចែម បានធ្វើការនៅក្នុងស្រុកកោះអណ្តែតដែលគាត់ក៏ទទួល -- ហើយក៏ជាប្រធានផ្នែកសមាគមនារីនៅក្នុងតំបន់១៣នោះដែរ។ មិនមានការ -- មិនមានអ្នកវិភាគអង្គហេតុប្រកបដោយហេតុផលណាមួយអាចបកស្រាយចម្លើយរបស់ អ៊ឹម ចែម ក្រៅពីនេះបានទេ។ អ៊ឹម ចែម បានបង្ហាញថា គេបានបញ្ជូនគាត់ ហើយក្នុងនោះ ក៏មានមនុស្សបីនាក់ទៀត។ ទី១ គឺមាន អ៊ឹម ចែម ហើយនិងអនុរបស់គាត់ឈ្មោះ តាសាន និងតាចាន់ ដែលជាសមាជិក។ មិនមានអ្វីគួរឲ្យសង្ស័យទេថា អ៊ឹម ចែម ពិតជាលេខាស្រុកកោះអណ្តែតហើយ។

[១៥:០០:៥១]

អ៊ឹម ចែម បានទទួលស្គាល់អំពីតួនាទីរបស់គាត់ហ្នឹង គឺថាវាចង្វាក់គ្នាទៅនឹងសាក្សី សក្ខីកម្មរបស់សាក្សីមួយចំនួន។ ប៉ុន្តែ ក.ស.ច.ស នេះ ខកខានមិនបានវាយតម្លៃឲ្យបានត្រឹមត្រូវទៅលើភស្តុតាងនេះទេ។ សាក្សី នាង អ៊ួច ហៅ តាសាន គឺជាបុគ្គលម្នាក់ដែល យាយចែម បានលើកយកឈ្មោះនេះមកនិយាយពីរដងនៅក្នុងកិច្ចសម្ភាសន៍របស់គាត់ថា តាសាន នេះ គឺជាអនុប្រធានរបស់គាត់នៅកោះអណ្តែត ហើយយ៉ាងហោចណាស់ សាក្សីបីនាក់បានបញ្ជាក់ជូនសហចៅក្រមស៊ើបអង្កេតថា នាង អ៊ួច ហៅ តាសាន នេះ គឺស្ថិតនៅក្នុងគណៈស្រុកកោះអណ្តែត។ អ៊ឹម ចែម បានប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជាថា "ពូសាន អានុរបស់ខ្ញុំហ្នឹង គាត់ទទួលខាងស្រុកបឹង នៅជិតទឹកដីវៀតណាមទៅវិញទេ"។ ហើយនៅពេលដែលសួរ តាសាន នេះ តាសាន មិនបានបដិសេធថាគាត់ជាអនុប្រធានរបស់ អ៊ឹម ចែម នោះទេ។ គាត់បានប្រាប់ទៅ ក.ស.ច.ស ក្នុងឯកសារ D119/82 ចម្លើយ៤៨ ថាសុំដកស្រង់៖ "បាទ ត្រឹមត្រូវហើយ។ ខ្ញុំទៅធ្វើការនៅបឹងព្រៃល្ពៅ និងទង់លាច ដើម្បីកសាង -- ដើម្បីជីកប្រឡាយ"។

[១៥:០២:២៣]

នាង អ៊ួច ហៅ តាសាន នេះ បានឆ្លើយថា គាត់ៗ មិនដឹងតួនាទីរបស់គាត់ជាអ្វីផង។ គឺដើម្បីធ្វើម៉េចគេចចេញពីការចោទប្រកាន់ការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ ជាពិសេស នៅពេលដែលគាត់ផ្តល់សក្ខីកម្មក្នុងសំណុំរឿង០២/០១ ពាក់ព័ន្ធទៅនឹងគណៈកម្មាធិការស្រុកត្រាំកក់។ នៅពេលដែលគាត់មិនអាចបដិសេធអំពីតួនាទីរបស់គាត់ក្នុងគណៈកម្មាធិការស្រុកត្រាំកក់បាន។ នាង អ៊ួច ហៅ តាសាន ក៏

បានជម្រាបទៅ ក.ស.ច.ស ត្រង់ចម្លើយ២៧ ថា៖ “តាចាន់ បុគ្គលនេះ គឺថា អ៊ឹម ចែម ជាអ្នកលើកឈ្មោះមកនិយាយថា ជាសមាជិកវ័យចាស់ម្នាក់នៅក្នុងគណៈស្រុកកោះអណ្តែត”។ ហ្នឹងអ្វីដែលតាសានបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតថា តាសាន គឺជាសមាជិកស្រុកកោះអណ្តែត។ នៅពេលតាសានខ្លួនគាត់ហ្នឹង គាត់ដឹងថាគាត់នៅឯស្រុកកោះអណ្តែត។

[១៥:០៣:២៥]

ចំណុចនេះ វាកាន់តែស៊ីគ្នា ស៊ីចង្វាក់គ្នាបន្ថែមទៀត ទៅលើការទទួលស្គាល់របស់ អ៊ឹម ចែម។ ទោះបីជាមានភស្តុតាងបែបនេះក្តី ក.ស.ច.ស ការសំអាងទៅលើភស្តុតាងរបស់ អ៊ួច នាង ដែលថា អ៊ឹម ចែម គឺជាប្រធានសមាគមនារីតំបន់១៣។ ក.ស.ច.ស ដែលបានភស្តុតាង -- ដែលបានប្រព្រឹត្តមកលើភស្តុតាងនេះ មិនមានន័យអ្វីទាល់តែសោះ។ ក.ស.ច.ស មិនបានដោះស្រាយអំពីភាពមិនស៊ីចង្វាក់គ្នាដែលថា នាង អ៊ួច ហៅ តាសាន នេះ គឺពិតជាអនុប្រធានសមាគមនារីនៅតំបន់១៣។ ពេជ្រ ជឹម ដែលជាអនុលេខាស្រុកត្រាំកក់បានជម្រាបជូន ក.ស.ច.ស នៅឯកសារ D118/259 ត្រង់ចម្លើយ៤១ថា៖ “មានស្ត្រីបីនាក់ដែលទទួលបន្ទុកសមាគមនារីនៅតំបន់១៣។ ក្នុងនោះមាន អ៊ឹម ចែម, យាយប៊ូ និងយាយផន”។ បន្ថែម*លើស* នេះទៅទៀត ក.ស.ច.ស ខកខានមិនបានពិចារណាទៅលើភស្តុតាងរបស់ សុខ រុន ដែលជាអ្នកធ្វើការនៅក្នុងស្រុកកោះអណ្តែតក្នុងឆ្នាំ១៩៧៦ ដែលបានជម្រាបទៅ ក.ស.ច.ស គឺឯកសារ D119/108 ត្រង់ចម្លើយ១០៥ ថា៖ “អ៊ឹម ចែម គឺជាលេខាស្រុកកោះអណ្តែត ហើយគាត់បានបើកអង្គប្រជុំដែលមានស្ត្រីបុរសជាច្រើនចូលរួមប្រជុំនៅស្រុកកោះអណ្តែត។ មិនមានការបញ្ជាក់ណាមួយនៅក្នុងដីកាដំណោះស្រាយដែលលើកយកភស្តុតាងពាក់ព័ន្ធនេះ យកមកពិចារណានោះទេ តាមពិតទៅ ក.ស.ច.ស បានយោងទៅលើភស្តុតាងរបស់ សុខ រុំ នៅត្រង់កន្លែងផ្សេងទៅវិញទេ ដែលបង្ហាញឲ្យឃើញថា សហចៅក្រមស៊ើបអង្កេតពិចារណាថាកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ហ្នឹង គឺថាអាចជឿជាក់បាន។ អ៊ឹម ចែម អះអាងនៅក្នុងកថាខណ្ឌ១១៧ នៃចម្លើយតបរបស់គាត់ ថាវាមិនចាំបាច់ដែលសហចៅក្រមស៊ើបអង្កេតត្រូវដាក់បញ្ចូលចម្លើយរបស់ សុខ រុំ នោះទេ ដោយសារថាយើងត្រូវតែយោងទៅលើបំណែកនៃភស្តុតាងទាំងអស់នៅក្នុងកំណត់ត្រានោះ។ ប៉ុន្តែ គឺថាវាមិនត្រឹមត្រូវទាល់តែសោះដែលថាអ្នកស្វែងរកអង្គហេតុណាមួយនោះអាចដកហូតចេញ ដោយមិនពិចារណាទៅលើភស្តុតាងដែលគួរឲ្យជឿជាក់បាន គឺថាដកចេញទាំងស្រុង ហើយមិនពិចារណានៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនទេ។

[១៥:០៦:១១]

ក.ស.ច.ស ក៏ខកខានមិនពិចារណាទៅលើភស្តុតាងរបស់ វៀល សន ហើយនិង កៅ ឆេង នោះដែរ។ សាក្សីទាំងបីនេះបានផ្តល់នូវភស្តុតាងស៊ីចង្វាក់គ្នាដែលថា អ៊ឹម ចែម គឺជាលេខាស្រុកនៅក្នុងតំបន់១៣ហើយ។ អ៊ឹម ចែម អះអាងនៅក្នុងចម្លើយតបរបស់គាត់ត្រង់កថាខណ្ឌ១១០ ថា ក.ស.ព គឺថាដើម្បីចៀសវាងការសំអាងទៅលើភស្តុតាងរបស់ ប៊ុន ធឿន ហើយនិង ពេជ្រ ជឹម ប៉ុន្តែមិនមានអ្វីដែលអាចគេចចេញពីការពិតបាននោះទេ។ ទី១ ប៊ុន សួន បានជម្រាបទៅ ក.ស.ច.ស ឯកសារ D119/149 ត្រង់ចម្លើយ៣០ថា គាត់មិនធ្លាប់ដែលបានទៅស្រុកកោះអណ្តែតទេ។ អ៊ឹម ចែម អះអាងនៅក្នុងកថាខណ្ឌ ១១០ ថា ប៊ុន ធឿន បានលើកឡើងថា អ៊ឹម ចែម មិនបានចូលរួមនៅអង្គរជ័យ ក្នុងនាមលេខាស្រុកហ្នឹងគឺថានេះមិនត្រឹមត្រូវទេ។ ប៊ុន ធឿន បានជម្រាបជូន ក.ស.ច.ស ថាគាត់បានចូលរួមប្រជុំកិច្ចប្រជុំនៅថ្នាក់តំបន់ នៅអង្គរជ័យ ដែល អ៊ឹម ចែម មានវត្តមាននៅទីនោះ ហើយលេខាឃុំទាំងអស់ត្រូវបានចាប់ខ្លួន។ គាត់បានជម្រាបទៅ ក.ស.ច.ស ឯកសារ D6.1.688, ERN ជាភាសាអង់គ្លេស 00384406។ សូមដកស្រង់៖ "យាយចែម និយាយជាមួយសមមិត្តរបស់គាត់អំពីការចាប់ខ្លួនលេខាឃុំទាំងអស់នោះ គាត់បាននិយាយថា ពួកនេះគឺថាជាប់ពាក់ព័ន្ធជាមួយនឹងយួន" បញ្ចប់ការដកស្រង់។

[១៥:០៨:០០]

ភស្តុតាងរបស់ ប៊ុន ធឿន ដូច្នេះគឺថាវាពាក់ព័ន្ធទៅនឹងតួនាទីរបស់ អ៊ឹម ចែម នៅថ្នាក់តំបន់ ហើយនិងការកំណត់គោលដៅរបស់គាត់ទៅលើជនជាតិវៀតណាមនៅក្នុងតំបន់ដែលគាត់ត្រួតត្រា។ ក៏ប៉ុន្តែវាហាក់បីដូចជាគាត់មិនបាននិយាយ។ ប៉ុន្តែមានចំណុចដែលមិនបាននិយាយអំពីតួនាទីជាលេខាស្រុកនោះទេ។ ទី២ ពេជ្រ ជឹម បានប្រាប់ទៅ ក.ស.ច.ស ឯកសារ D118/259 ចម្លើយ៣៩ថា គណៈកម្មាធិការស្រុកកោះអណ្តែតមានឈ្មោះ សៀង ជាលេខាស្រុក, តាសាន ជាអនុ។ ដូច្នេះភស្តុតាងរបស់ ពេជ្រ ជឹម គឺថាវាមិនស៊ីចង្វាក់គ្នា ប៉ុន្តែអ៊ីចឹងៗភស្តុតាងរបស់ ពេជ្រ ជឹម គឺស៊ីចង្វាក់គ្នាហើយ ក្រោយពី សៀង បញ្ជូនចេញទៅ គឺថា អ៊ឹម ចែម នេះក៏បានឡើងទៅជាលេខាស្រុកកោះអណ្តែត។ ពេជ្រ ជឹម ក៏បានបញ្ជាក់ផងដែរ នាង អ៊ូច ហៅ តាសាន នេះគឺជាអនុលេខាស្រុកកោះអណ្តែតនេះ គឺថាវាស៊ីចង្វាក់គ្នាទៅនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម អំពីតួនាទីរបស់គាត់ផ្ទាល់នៅក្នុងស្រុកកោះអណ្តែត។ នៅពេលដែលយើងបានវាយតម្លៃឲ្យបានត្រឹមត្រូវ និងជារួមទៅ គឺថាភស្តុតាងបង្ហាញយ៉ាងច្បាស់ហើយថា អ៊ឹម ចែម ពិតជាលេខាស្រុកកោះអណ្តែត ហើយមិនមានគឺថា អ្នកវិនិច្ឆ័យអង្គហេតុប្រកបដោយហេតុផលណាមួយ អាចយល់ឃើញផ្សេងពីនេះបានទេ។

ឥឡូវនេះយើង សំអាងហេតុទី៦ ដែលជាសំអាងហេតុរបស់ ក.ស.ព។ ក.ស.ច.ស មានកំហុសនៅក្នុងការយល់ឃើញនៅក្នុងកថាខណ្ឌ១៤៤ថា អ៊ឹម ចែម មិនមានជាសមាជិកគណៈតំបន់១៣នោះ។ បាទ ជាថ្មីម្តងទៀត អ៊ឹម ចែម បានទទួលថា គាត់ជាសមាជិកគណៈតំបន់១៣។ អ៊ឹម ចែម បានប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជាដូចតទៅ សូមចាក់នូវឃ្លីបទី២។

[១៥:១០:១៧]

*(ការបង្ហាញឯកសារជាសំឡេង)*

*"ឆ្លើយ៖ តាស៊ាង ខ្ញុំនោះ ពូសោម នោះ គាត់ថា ស៊ីទៅ បានគេដំឡើងខ្ញុំ ប្រគល់ឲ្យខ្ញុំធ្វើ។ សួរ៖ (ឮមិនច្បាស់)។ ឆ្លើយ៖ ប៉ុនខ្ញុំធ្វើហ្នឹងតិចដែរ មួយឆ្នាំអីហ្នឹង។ តាគាត់ដកឲ្យមកនៅបាត់ដំបង។ សួរ៖ (ឮមិនច្បាស់)។ ឆ្លើយ៖ ចាស នៅជាមួយខ្ញុំ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

**លោក កូមេន** ខេននី៖

អ៊ឹម ចែម នេះ គាត់បាននិយាយអំពីការដំឡើងបុណ្យស័ក្តិនេះ ដោយប្រើពាក្យពេចន៍ដូចទៅ សូមចាក់នូវឃ្លីបទី៣។

*(ការបង្ហាញឯកសារជាសំឡេង)*

*"ទេ ខ្ញុំធ្វើជំនួសប្រធានខ្ញុំហ្នឹង បានតែចូលជាសមាជិកទេណា។ សួរ៖ សមាជិកតំបន់? ឆ្លើយ៖ ចាស។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

[១៥:១១:២៥]

**លោក កូមេន** ខេននី៖

អ៊ឹម ចែម ក៏បាននិយាយផងដែរ ថាតាម៉ុក ជាអ្នកបញ្ជូនគាត់ពីតាកែវទៅឲ្យធ្វើ -- ទៅធ្វើការនៅគណៈតំបន់។ អ៊ឹម ចែម បានទទួលស្គាល់ថា គាត់បាន -- គេបានដំឡើងបុណ្យស័ក្តិឲ្យទៅជាសមាជិកតំបន់១៣ ហើយគាត់កាន់តួនាទីនេះប្រហែលជាមួយឆ្នាំ មុននឹងគេបញ្ជូនទៅកាន់ភូមិភាគពាយ័ព្យ ដែលសហចៅក្រមស៊ើបអង្កេតបានឃើញ គឺថា តាម៉ុក បានបញ្ជូនគាត់ទៅភូមិភាគពាយ័ព្យនោះ ដើម្បីធ្វើការបោសសម្អាតនៅទីនោះ។

វិធីសាស្ត្រដែលចោទឡើងជាបញ្ហា លើឡើងជាបញ្ហាដោយសហចៅក្រមស៊ើបអង្កេតនេះ គឺថា

អ៊ឹម ចែម នេះ បានបំផ្លើសចំពោះតួនាទីរបស់គាត់ ជាពិសេសនៅក្នុងកថាខណ្ឌ១៤៧ មិនមានការយោង ហើយខកខានមិនបានពន្យល់ ថាហេតុអ្វីក៏មិនយកចំណុចនេះយកមករៀបរាប់ផង។

[១៥:១២:២៦]

ចំពោះសំអាងហេតុទី៥វិញ ក.ស.ច.ស មានកំហុស មិនមែនថាដោយសារថាមិនវាយតម្លៃទៅលើការទទួលស្គាល់របស់ អ៊ឹម ចែម ដោយផ្ទាល់នោះទេ ប៉ុន្តែក៏មិនស៊ីចង្វាក់គ្នាទៅនឹងចម្លើយរបស់សាក្សីផងដែរ។ ក.ស.ច.ស បានសន្និដ្ឋានថា សន្និដ្ឋានត្រង់កថាខណ្ឌ១៤៤ នៃដីកាដំណោះស្រាយថា សាក្សីយ៉ាងច្រើនបានផ្តល់នូវភស្តុតាងជាក់លាក់ថា អ៊ឹម ចែម គឺជាប្រធានសមាគមនារី ជាជាងសមាជិកគណៈតំបន់១៣។ ប៉ុន្តែមិនមានផលហេតុណាមួយ ថាតួនាទីមួយនេះ វា -- ការកាន់តួនាទីមួយវាអាចលុបចោល ឬឲ្យគេដកតួនាទីរបស់គាត់ផ្សេងនោះទេ។ គឺថាទី១ គឺអ៊ឹម ចែម គាត់ដឹកនាំស្ត្រីនៅក្នុងតំបន់ក្នុងពេលតែមួយ ដែលគាត់ក៏ជាសមាជិកគណៈតំបន់១៣ដែរ។ ឧទាហរណ៍ មៀង វ៉េត នេះដែលជាកម្មាភិបាលម្នាក់នៅក្នុងតំបន់១៣ បានប្រាប់ ក.ស.ច.ស ឯកសារ D119/83 ត្រង់ចម្លើយ១៨ សូមដកស្រង់៖ “យាយចែម គឺជាអនុគណៈតំបន់១៣ ហើយទទួលបន្ទុកខាងផ្នែកស្ត្រីនៅក្នុងតំបន់នេះ។ យើងអាចនិយាយបានថា គាត់គឺជាសមាជិកគណៈអចិន្ត្រៃយ៍តំបន់១៣ក៏បានដែរ” បញ្ចប់ការដកស្រង់។

[១៥:១៣:៤៩]

មៀង វ៉េត នេះ ក៏បានលើកឡើងផងដែរ ត្រង់ចម្លើយ២០។ នៅពេលដែលគាត់ចូលរួមប្រជុំនៅគណៈតំបន់១៣ គឺថាគាត់តែងតែសរសេរនៅខ្នងសំបុត្រ ដែលថាតាសឿន ផ្ញើជូនទៅ យាយចែម ដែលថាជូនសមមិត្តនារី ចែម សមាជិកគណៈអចិន្ត្រៃយ៍តំបន់១៣។ ពេជ្រ ជឹម ដែលជាអនុលេខាស្រុកត្រាំកក់បានប្រាប់ទៅ ក.ស.ច.ស ត្រង់ឯកសារ D118/259 ចម្លើយ៤០ ថា ពេជ្រ ជឹម បានគិតថា អ៊ឹម ចែម សូមដកស្រង់៖ “គឺថាគាត់គឺជាសមាជិកគណៈតំបន់ ហើយក៏ទទួលខុសត្រូវផ្នែកស្ត្រី ពីព្រោះគាត់តែងតែទៅធ្វើការនៅតាមស្រុកនានាក្នុងតំបន់១៣”។ អ៊ឹម ចែម ព្យាយាមធ្វើឲ្យអន្តរាយទៅដល់ភស្តុតាងរបស់ ពេជ្រ ជឹម ដែលលើកឡើងត្រង់កថាខណ្ឌ១២៧ ថា ពេជ្រ ជឹម បានប្រាប់ទៅ ក.ស.ច.ស ថា អ៊ឹម ចែម មិនមែនជាលេខាតំបន់ទេ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាអន្តរជាតិមិនបានអះអាងថា អ៊ឹម ចែម គឺជាលេខាតំបន់នោះទេ។ ប៉ុន្តែបានអះអាងថា គាត់គឺជាសមាជិកគណៈតំបន់ ហើយភស្តុតាងរបស់ ពេជ្រ ជឹម នេះ គឺថាវាស៊ីចង្វាក់គ្នាតែម្តង។ ប៊ុន ធឿន ដែលជាសមាជិកគណៈកម្មការឃុំសន្លុងបានជម្រាបជូន ក.ស.ច.ស ឯកសារ D118/274 ចម្លើយ២៩។ សូមដកស្រង់៖ “នៅពេលនោះ អ្វីៗទាំងអស់ គឺថាជា

សម្ងាត់ ខ្ញុំគ្រាន់តែឮថា តាសូវែន ការដក តាសូវែន នេះ គឺយាយថែម ប្រហែលជាដោយសារគាត់ជាសមាជិកតំបន់។ មានបញ្ហាពីរ ទី១ ច្បាស់ហើយពាក់ព័ន្ធទៅនឹងសំណួរនិងចម្លើយ។ នៅពេលដែលគាត់និយាយពីថា តំបន់១៤ហ្នឹង គឺការពិតតំបន់១៣ទេ។ នៅក្នុងសម័យនោះ អត់មានតំបន់១៤ ទេ។ ហើយតាសឿន ហ្នឹង គឺជាលេខាតំបន់១៣។ ទី២ ចម្លើយនេះផ្ទុះបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា អ៊ឹម ចែម ខ្លួនគាត់បានទទួលស្គាល់ថា នៅពេលដែល តាសឿន ចាកចេញពីតំណែងនោះ គឺថាគាត់ក៏ឡើងទៅជាជំនួសជាសមាជិកតំបន់។ អ៊ុន សុភាព ដែលជាកងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានប្រាប់ ក.ស.ច.ស នៅក្នុងឯកសារ D118/78 ចម្លើយ៨។ សូមដកស្រង់៖ "ខ្ញុំដឹង អ៊ឹម ចែម គឺជាសមាជិកគណៈតំបន់១៣ ដោយសារខ្ញុំឃើញរូបថតរបស់គាត់ហ្នឹងនៅក្នុងទស្សនាវដ្តី នៅក្នុងរបបខ្មែរក្រហម។ នៅក្នុងរូបថតហ្នឹង គឺគាត់ស្លៀកពាក់ខោអាវខ្មៅធម្មតា ហើយឈរតែម្នាក់ឯង។ នៅក្នុងរូបថតហ្នឹងមានសរសេរថា អ៊ឹម ចែម គណៈតំបន់១៣។

[១៥:១៧:០២]

ស្នួន មុត ដែលជាកម្មាភិបាលភូមិភាគនិរតីបានជម្រាបជូនទៅសហចៅក្រមស៊ើបអង្កេតនៅត្រង់ឯកសារ D219/37 ចម្លើយ១៧ ថា អ៊ឹម ចែម គឺជាសមាជិកនៃគណៈតំបន់១៣។ ស្នួន មុត ក៏បានឆ្លើយប្រាប់សហចៅក្រមស៊ើបអង្កេតត្រង់ចម្លើយ១៨ សូមដកស្រង់៖ "ខ្ញុំដឹង ហើយខ្ញុំឃើញគាត់ដោយសារថាគាត់ហ្នឹងមកបើកអង្គប្រជុំ ហើយធ្វើការនៅកន្លែងដែលខ្ញុំរស់នៅ" សូមដកបញ្ចប់។ ស្នួន មុត ហ្នឹងក៏បានបន្ថែមត្រង់ចម្លើយ២៥ ថា "អ៊ឹម ចែម ត្រួតត្រាទៅលើតំបន់តូច ផ្នែកតូចមួយទេ នៅក្នុងតំបន់ហ្នឹង ដូចជា ផ្នែកខាងកសាងប្រឡាយ ផ្នែកខាងជីក ផ្នែកខាងលើកទំនប់ ជីកប្រឡាយជាដើម ហើយនិងផ្នែកខាងសេដ្ឋកិច្ច។ ជឹម ជ្រាវ ដែលនៅកង ធ្វើការនៅកងចល័តនោះ បានប្រាប់ទៅសហចៅក្រមស៊ើបអង្កេតនៅត្រង់ឯកសារ D119/13 ចម្លើយ៦ ថា អ៊ឹម ចែម -- សូមដកស្រង់៖ "មានតួនាទីនៅក្នុងគណៈខេត្តតាកែវ" បញ្ចប់ការដកស្រង់។ ជឹម ជ្រាវ បានដឹងនេះ ដោយសារថា អ៊ឹម ចែម សូមដកស្រង់៖ "តែងតែឲ្យខ្ញុំទៅហៅប្រជាជននៅក្នុងភូមិ និងឃុំ ដើម្បីមកប្រជុំនៅតាមការដ្ឋានកងចល័ត។

[១៥:១៨:៣០]

អ៊ុល ហឿន ដែលធ្វើការនៅក្នុងស្រុកត្រាំកក់ បានប្រាប់ទៅសហចៅក្រមស៊ើបអង្កេត នៅឯកសារ D193/8.2 ចម្លើយ១០ សូមដកស្រង់៖ "យាយថែម គឺថាមានឋានៈលេខ៣ នៅក្នុងតំបន់១៣ តាសឿន គឺលេខ១, តាមុត លេខ២, តាកឺ លេខ៣ ហើយយាយថែម ហ្នឹងមកជំនួស តាកឺ" បញ្ចប់ការ

ដកស្រង់។ គឺថាសហចៅក្រមស៊ើបអង្កេតមិនបានពិចារណាឲ្យបានល្អិតល្អន់ទៅលើភស្តុតាងទាំងអស់នេះទេ។ សហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណាទៅលើភស្តុតាងរបស់ មុល អេង ដែលជាលេខាស្រុកបវេលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មុល អេង បានជម្រាបជូនសហចៅក្រមស៊ើបអង្កេតក្នុងឯកសារ D219/294 ចម្លើយ១២៧ សូមដកស្រង់៖ "ខ្ញុំស្គាល់យាយចែម មកពីតាកែវ ហើយគាត់ជាសមាជិកតំបន់១៣" បញ្ចប់ការដកស្រង់។

ក.ស.ច.ស ក៏បាន -- ក៏ខកខានមិនបានពិចារណាភស្តុតាងរបស់ សុខ រុំ និង ខឹម វ៉ៃ។ សុខ រុំ ដែលធ្វើការនៅកោះអណ្តែតនោះ បានជម្រាបជូន ក.ស.ច.ស ក្នុងឯកសារ D119/108 ចម្លើយ៤៥ សូមដកស្រង់៖ "យាយចែម គឺជាគណៈតំបន់១៣ យាយចែម ទទួលខុសត្រូវកុមារៗ ស្ត្រីកងកុមារ កងស្ត្រី ក៏ដូចជាកងបុរសៗតំបន់១៣ដែរ" បញ្ចប់លោកស្រី។ ខឹម វ៉ៃ គឺជានីរសារតំបន់នៅក្នុងខេត្តតាកែវ បានជម្រាបជូន ក.ស.ច.ស ត្រង់ឯកសារ D219/636 ចម្លើយ៣៨ សូមដកស្រង់៖ "តាទិត្យ និងយាយចែម ទាំងអស់ហ្នឹងគឺនៅថ្នាក់តំបន់ហើយ"។ សូម្បីតែ អ៊ឹម ចែម ខ្លួនឯងនៅក្នុងកថាខណ្ឌ១៣០ ទទួលស្គាល់ថា ខឹម វ៉ៃ នេះបានផ្តល់ភស្តុតាងដោយផ្ទាល់ដែលមានតម្លៃទាក់ទងទៅនឹងតួនាទីរបស់ អ៊ឹម ចែម ជាសមាជិករបស់គណៈតំបន់១៣។ ប៉ុន្តែ ក.ស.ច.ស នៅតែច្រានចោលភស្តុតាងទាំងនេះដោយមិនមានការពន្យល់ហេតុផលណាឡើយ។

[១៥:២១:០៦]

ដើម្បីឈានដល់សេចក្តីសន្និដ្ឋានរបស់ ក.ស.ច.ស ថា អ៊ឹម ចែម មិនមែនជាសមាជិកគណៈតំបន់១៣នោះ យើងត្រូវតែបដិសេធការទទួលស្គាល់របស់ អ៊ឹម ចែម ខ្លួនឯងផ្ទាល់សិន អំពីតួនាទីរបស់គាត់ ហើយនិងបដិសេធចម្លើយរបស់សាក្សី១០នាក់ដែលថា អ៊ឹម ចែម នេះគឺមានតួនាទីជាសមាជិកគណៈតំបន់១៣ ដែលជាតួនាទីមួយដាច់ដោយឡែកពីតួនាទីរបស់គាត់ជាប្រធានសមាគមនារី។ ហើយតើរឿងរ៉ាវអ្វីដែលជាចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ យើងអាចយកមកធ្វើម៉េចឲ្យវាស៊ីគ្នា ថា អ៊ឹម ចែម គឺពិតជាសមាជិកតំបន់១៣។

ពាក់ព័ន្ធទៅនឹងគុណភាពនៃភរនីយភាព ដែលថា អ៊ឹម ចែម គឺថាបានលាក់លៀមអំពីតួនាទីរបស់គាត់ក្នុងសម័យខ្មែរក្រហមថា គាត់មិនមែនជាសមាជិកតំបន់១៣ ប៉ុន្តែគាត់គ្រាន់តែនិយាយថា គាត់ជាប្រធានសមាគមនារីក្នុងតំបន់តែប៉ុណ្ណោះ ត្រឹមត្រូវហើយ ឬក៏ថា អ៊ឹម ចែម ដឹងអំពីតួនាទីរបស់គាត់ហើយទទួលស្គាល់ប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា គាត់គឺស្ថិតនៅក្នុងតំបន់១៣ ដែលវាដាច់ពីតួនាទី

របស់គាត់ជាប្រធានសមាគមនារី។ មិនមានអ្នកស្វែងរកអង្គហេតុប្រកបដោយហេតុផលណាមួយអាចវាយតម្លៃទៅលើភស្តុតាងឲ្យបានត្រឹមត្រូវ ហើយអាចឈានដល់ការធ្វើសេចក្ដីសន្និដ្ឋាន ដូចការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតនោះទេ។ បាទចំណុចនេះ គឺថាយើងខ្ញុំសូមបញ្ចប់ការលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ទៅលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

ហើយបើសិនណាមានសំណួរអ្វី គឺថាខ្ញុំត្រៀមរួចរាល់ដើម្បីឆ្លើយទៅនឹងសំណួរទាំងនោះ។ ហើយយើងខ្ញុំក៏សុំប្រតិចារឹកដែលនូវ -- ប្រតិចារឹកនូវអ្វីដែលខ្ញុំបានលើកឡើងអម្បាញ់មិញយកទៅមើលផងដែរ។

[១៥:២៤:១៣]

**ប្រធានអង្គបុរេ៖**

លោកព្រះរាជអាជ្ញា ចប់ហើយសេចក្ដីសន្និដ្ឋានរបស់លោក? អ៊ីចឹង--

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំបានបញ្ចប់នូវសារណាររបស់យើងខ្ញុំហើយ បើសិនជាលោកប្រធាន លោកចៅក្រមមានសំណួរអី ខ្ញុំអាចនឹងឆ្លើយបាន។

**ប្រធានអង្គបុរេ៖**

សួរដេញដោលអីតទៅទៀតទេ ក្រោយពីបានបញ្ចប់សេចក្ដីសន្និដ្ឋាន។ អ៊ីចឹងសូមអរគុណបាទ។

អ៊ីចឹងមិនមានអ្វីថែមទៀតទេ ហើយខ្ញុំប្រកាសនៅពេលហ្នឹងតែម្ដង សវនាការនៅថ្ងៃនេះ គឺបញ្ចប់នៅពេលនេះ ហើយយើងបន្តសវនាការនៅព្រឹកស្អែកតទៅទៀតនៅម៉ោងដប់បាទ៕

*(សវនាការផ្អាកនៅម៉ោង ១៥:២៥ នាទី)*